៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៤២ ខែ មីនា

ព.ស. ២៥១៣ គ.ស. ១៩៧០

-ភ្នំពេញ-

៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : លាង ហ័បអាន

និពន្ធនាយក-អ្នករៀបចំ : លើ ផាមតែង

គណៈកម្មការនិពន្ធ :

ព្រះឧទ្ទីកោសល សូរ-ហាយ

លោក លឹម-ឈាងផិន លោក ឌីក-គាម

លោក ជល-ធិត លោក ព្រួច-កុម

អ្នកស្រី ពេជ-សល់

# បញ្ជីរឿង

| អត្ថបទ | ទំព័រ |
| --- | --- |

## ផ្នែកសាសនា


១– កើតទៀតឬទេ ? (ត) ព្រះមហាវីរិយបណ្ឌិតោ ប៉ាង-ខាត់ រៀបរៀង . . ២៤៣

២– រឿងភិក្ខុប្រាំរយរូប លោក ប៊ូ-ប៊ូ ប្រែរៀបរៀង . . . . . ២៦៣


## ផ្នែកអក្សរសាស្ត្រ


៣– រឿងសាមកុក លោក ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . ២៦៨

៤– រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ អ្នកស្រីពេជ-សល់ ប្រែរៀបរៀង . . ២៧៩

៥– រឿងខ្លី ៗ មានន័យវែង សហ. ផល-ទិត នៅក្រុមជំនុំព្រះត្រៃបិដករៀបរៀង ២៩៦

៦– ការសង្កេតស្រាវជ្រាវចំពោះរឿងវរវង្ស-សូរវង្ស សហ លី-ធាមតេង រៀបរៀង . . . . . . . . . . ៣១៥

៧– រឿងវរវង្សសូរវង្ស ចម្លងចេញពីសាស្ត្រាស្លឹករឹត . . . . . ៣២៣


## តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ។

អាណត្តិសូមដាក់ថាៈ លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

| | |
|---|---|
| ពាក្យឃាត់មិនឲ្យ | ធ្វើការអាក្រក់ |
| ជាការណាមក់ | ឲ្យធ្វើល្អទៅ, |
| ឲ្យជុសខាត់ចិត្ត | កុំឲ្យហ្មងសៅ |
| បីនេះលោកហៅ | ពុទ្ធសាសនា ។ |

ប. ព

# កើតទៀតឬទេ ?

ព្រះមហាវីរិយបណ្ឌិតោ ប៉ាង់-ខាត់ រៀបរៀង

[ ក ]

## បទទីពីរ

## បុព្វហេតុនៃការកើតស្លាប់

ក្នុងការត្រិះរិះរកបុព្វហេតុនៃការកើតស្លាប់ ពុទ្ធសាសនិកជនមិនយកអ្វីដទៃមកនិយាយទេ យកមនុស្សសត្វនេះឯង មកទុកជាគោលចាប់ផ្ដើមនិយាយ រួចហើយ ទើបនិយាយពីកម្មដែលនាំឲ្យកើតជាមនុស្សសត្វតទៅទៀត ។

តាមទស្សនៈពុទ្ធសាសនា មនុស្សសត្វកើតឡើងដោយការផ្សំធាតុ គឺការផ្សំគ្នាដោយចិត្តនិងរូប ដែលជាធាតុ ហើយដែលលោកហៅថា

នាមរូប ពោលគឺមនុស្សសត្វជាគីមីផ្សំធាតុ ទឹក ដី ភ្លើង ខ្យល់ ។ មនុស្សសត្វទាំងអស់ ទោះយោបី មានធម៌ពីរប្រការនេះរួមជាមួយគ្នាក៏ដោយ ក៏នៅតែមិនដូចគ្នាសុទ្ធសាធដែរ តែងតែមានភាពផ្សេងៗគ្នាពិតប្រាកដ ។ ឯភាពផ្សេងគ្នានេះ ជាធម៌តែងតែកើតមានទៅតាមលក្ខណៈចិត្តបុគ្គលម្នាក់ៗ រៀងៗខ្លួន ។

ភាពផ្សេងគ្នានេះ តើយើងគិតនិយាយដូចម្ដេច ឲ្យស្ដាប់បានយើងនិយាយថា កើតតាមធម្មជាតិខ្លួនឯង ឬតាមវង្សត្រកូល ឬក៏តាមវត្ថុដែលនៅជុំវិញខ្លួនយើង? បើពិតជាដូចយើងនិយាយនេះមែន ចុះកូនភ្លោះម្ដេចឡើយ ក៏មានរូបដូចគ្នាស្ទើរបេះបិទម៉្លេះ? ហើយថែមទាំងបានទទួលបុព្វសិទ្ធិគឺការរស់នៅដូចគ្នាទៀត? ចុះពាក្យដែលយើងនិយាយថា មានភាពផ្សេងៗគ្នានោះ វាមិនខុសស្រឡះអស់ទៅហើយ? សេចក្ដីអស់ទាំងនេះ គួរតែយើងនិយាយបង្ហាញហេតុផលឲ្យឃើញច្បាស់លាស់ដែរ ទើបសមរម្យ ។

ពិបាកយល់បន្តិចមែនហើយ! ប៉ុន្តែមិនជាអ្វីទេ យើងនៅតែអាចយល់បាន ។ នាមរូបនេះឯងហើយ ជាកត្តារួមគ្នា ជាចំណែកមួយសំខាន់ណាស់ ក្នុងការកកើតឡើង បានទៅជាលក្ខណៈរូបកាយរបស់មនុស្សសត្វ ពោលគឺធម៌ទាំងពីរប្រការនេះ ជាឧបករណ៍មួយចំណែកដ៏ពិតប្រាកដ ប៉ុន្តែធម៌ទាំងពីរប្រការនេះ ពុំមែនជាធម៌ទទួលខុសត្រូវតែ

ឯកឯងចំពោះភាពផ្សេង ៗ គ្នាដោយល្អិត ដែលតែងតែកើតមានឡើងដល់ មនុស្សសត្វពល់គ្នានោះទេ ។

ឯទ្រឹស្ដីបិតាគត ដែលស្ដីថា អ្វី ៗ សុទ្ធតែជាប់តមកពីបុព្វបុរសនុ៎ះ មិនត្រូវលើកយកមកនិយាយ ក្នុងករណីយ៍កំណើតអ្នកប្រព្រឹត្តបទឧក្រិដ្ឋ តគ្នាវែងឆ្ងាយពីបុព្វបុរសខ្លួនដ៏ប្រសើរ ឬពីកំណើតកល្យាណជន ឬក៏ពី កំណើតព្រះអរិយបុគ្គលនៅក្នុងវង្សត្រកូលខ្លួននោះដែរ ហើយប្រសិនជាដើម ឈើទៅក៏ នុ៎ះក៏គួរយើងយកទ្រឹស្ដីបិតាគតនោះមកនិយាយបាន ។

ឥឡូវ យើងនិយាយចំពោះរូបមនុស្សម្នាក់ៗ ចាប់ផ្ដើមពីគភ៌ដែល តាំងនៅក្នុងផ្ទៃមាតា មើលឲ្យឃើញថា តើមានអ្វីជាបុព្វហេតុ? យើង មិនឃើញមានអ្វីដទៃទេ ឃើញមានតែធម៌ ២ ប្រការ គឺ នាមនិងរូប ហើយក្នុងនាមនិងរូប ដែលជាគភ៌សំខាន់នេះទៀត ក៏មិនឃើញមានអ្វី ក្រៅពី សុក្កកោសិកា និង អណ្ឌកោសិកា នេះដែរ ។

បើមានគេចោទសួរថា ធម៌ពីរប្រការដែលយើងពោលអាងខាងលើ នេះ គ្រាន់តែជាធាតុផ្សំឲ្យកើតជាគភ៌ប៉ុណ្ណោះ បើមានតែប៉ុណ្ណឹង គេ មិនអាចយល់បានទេ ថា ហេតុដូចម្ដេចបានជាអ្នក "ក" មានវាសនាក្ដី មិនមានវាសនាក្ដី កើតមកពីសុក្កកោសិកា និងអណ្ឌកោសិ-កា ពិសេស ឯអ្នក "ខ" ម្ដេចឡើយ ក៏មិនបានទទួលការពិសេសដូច គេផង? ហេតុដូចម្ដេច បានជាមនុស្សម្នាក់មានសម្បទាដូចមនុស្សម្នាក់

ទៀតដែរ ?

ពុទ្ធសាសនា បង្អុលប្រាប់ឲ្យដោះស្រាយប្រស្នានេះ ដោយការពន្យល់ឲ្យទាញយកកោសិកាជាធាតុនេះឯង ជាជាធម៌នាំឲ្យកើតមានធម៌ទីបីទៀត ដែលជា កត្តាសារវត្ត កឲ្យកើតបានជាទារកនៅក្នុងផ្ទៃមាតា[1]ឡើង ។

សេចក្តីនេះ យើងមានហេតុផលគ្រប់គ្រាន់នឹងនិយាយបានថា គភ៌នេះ ដោយពិត ពុំមែនកើតឡើងដោយអាស្រ័យតែការផ្សំសុក្កកោ-សិកា និង អណ្ឌកោសិកា តែប៉ុណ្ណោះទេ ព្រោះថា កោសិកាទាំងអស់ ដែលតាំងនៅក្នុងផ្ទៃនោះ នឹងត្រូវវិនាសទៅវិញពុំខានឡើយ ប្រសិនណាបើមិនមានការផ្សំធម៌ទីបី ដែលជាកត្តាសំខាន់នេះទេ គឺធម៌ទីបីនេះឯងហើយ ដែលទទួលបន្ទុកខុសត្រូវចំពោះភាពផ្សេងៗគ្នា និងចំពោះភាពប្រសើរខ្ពង់ខ្ពស់ឬភាពថោកទាបជាដើម ដែលតែងតែកើតមានក្នុងពពួកសត្វលោក ដូចពុទ្ធភាសិតដែលអង្គព្រះសម្ពុទ្ធទ្រង់ត្រាស់ទុកថា[2] :

"ភិក្ខុទាំងឡាយ ! ការចុះចាប់បដិសន្ធិ របស់សត្វដែលកើតក្នុងផ្ទៃ ព្រោះប្រជុំហេតុ ៣ ប្រការ ។ ក្នុងសត្វលោកនេះ មាតាបិតាមកប្រជុំ

---

១- D.P Dahlke, Buddhism and Science.

២- សុត្តន្តបិដក ភាគ ២២ មជ្ឈិមនិកាយ មូលបណ្ណាសក មហាតណ្ហាសង្ខយសូត្រ ទំព័រ ១៨០ ។

គ្នាហើយ តែមាតាជាស្ត្រីមិនមានរដូវផង សត្វដែលគួរកើតក្នុងផ្ទៃនោះ មិនមានប្រាកដក្នុងឱកាសនោះផង ការចុះចាប់បដិសន្ធិរបស់សត្វដែលកើតក្នុងផ្ទៃក៏មិនទាន់មាននៅឡើយ ។ ក្នុងសត្វលោកនេះ មាតាបិតាមកប្រជុំគ្នាហើយផង មាតាជាស្ត្រីមានរដូវផង តែសត្វដែលគួរកើតមិនមានប្រាកដក្នុងឱកាសនោះ ការចុះចាប់បដិសន្ធិរបស់សត្វដែលកើតក្នុងផ្ទៃក៏មិនទាន់មាននៅឡើយ ។

ភិក្ខុទាំងឡាយ ! លុះតែកាលណា

១- មាតាបិតាមកប្រជុំគ្នាផង

២- មាតាជាស្ត្រីមានរដូវផង

៣- សត្វដែលគួរកើត ក៏មានប្រាកដក្នុងឱកាសនោះផង លុះប្រជុំហេតុទាំង ៣ ប្រការនេះឯង ទើបសត្វចុះចាប់បដិសន្ធិក្នុងផ្ទៃនៃមាតាបាន " ។

ពាក្យថា " សត្វដែលគួរកើត " នេះ បានសេចក្តីថា " មានអ្នកស្លាប់ណាមួយ " ។ ការកើតនៃមនុស្សសត្វក្នុងជាតិនេះ ប្រែថា ការស្លាប់នៃមនុស្សសត្វណាមួយក្នុងអតីតជាតិ ។ រីការកើតនិងការស្លាប់នេះ ដោយពិត គ្រាន់តែជាបាតុភាព ឬ ឧប្បាទធម៌ នៃកម្មទាំងពីរប្រការ ដែលជាកម្មវិធី ឬ ដំណើរតែមួយនៃមនុស្សសត្វដដែលនេះឯង ។ ដូច្នេះ គួរគប្បីយល់ថា " ការកើត មានការស្លាប់នៅជាខាងដើម ឯការស្លាប់

ក៏មានការកើតនៅជាខាងដើមដែរ" ។ ការកើតនិងការស្លាប់រឿយៗ មិនដាច់នេះឯង ជាសន្តតិ ឬ ដំណើរជីវិតដែលបន្តការកើតរហូតទៅដោយអំណាចតណ្ហា ដូចខ្សែទឹកដែលហូរចុះខ្លាំងពីលើកំពូលភ្នំ ហើយកើតទៅជាពាក្យបច្ចេកទេសមួយហៅថា "សង្ខារ(១)" ការអន្ទោលកើតស្លាប់ ។

ចុះធម៌ទីបី ដែលយើងនិយាយខាងដើមនោះគឺអ្វី ? ធម៌នេះ អង្គព្រះសម្ពុទ្ធទ្រង់រកឃើញថ្មី ឬ ទ្រង់ត្រាស់ដឹងថ្មី ជាធម៌ដែលអ្នកមុនព្រះអង្គរកមិនឃើញទេ ហៅពាក្យនេះតាមគម្ពីរព្រះអភិធម្មថា បដិសន្ធិ-វិញ្ញាណ គឺវិញ្ញាណដែលកើតបន្តទៅភ្ជាប់នឹងខន្ធបញ្ចកៈថ្មីមួយទៀត ។

ឥឡូវ ពាក្យបឋមដែលជាឈ្មោះធម៌បន្តជីវិតទៅមុខទៀត យើងបានឃើញតាមពុទ្ធវចនៈហើយ តែការចេះដឹងរបស់យើង មានកម្រិតតិចពេក មិនធ្ងន់ល្មមឲ្យយើងចេះដឹង រហូតទៅដល់យល់បុព្វហេតុនៃបដិសន្ធិ-វិញ្ញាណ ដែលជាកត្តាសារវន្ត ហើយដែលនាំសត្វឲ្យកើតបានឡើយ ។ ឯអង្គព្រះសម្ពុទ្ធ ទ្រង់មានព្រះបញ្ញាញាណគម្ភីរភាពសុខុម ទ្រង់យល់ច្បាស់ចាក់ធ្លុះរហូតដល់ធម៌ពិត ផុតកន្លងវិស័យសត្វធម្មតា ហើយទ្រង់បានយល់ច្បាស់លាស់នូវឫសគល់នៃធម៌ទីបីនេះទៀត បានជាទ្រង់ត្រាស់

---

១- ការអន្ទោលស្លាប់កើត អ្វីអន្ទោលទៅ ? គឺក្រសែនៃអង្គអាយតនៈ, ធាតុ ( ទឹក-ដី-ភ្លើង-ខ្យល់ ), ខន្ធបញ្ចកៈដែលជាប់តគ្នារពឹកមិនចេះដាច់នេះ ។ ធម៌ទាំងនេះរួមគ្នា ហៅថា "សង្ខារ" ។

ទេសនាទុកថា "ការកើតឡើងនៃបដិសន្ធិវិញ្ញាណនេះ អាស្រ័យដោយការរលត់ចុតិវិញ្ញាណនៃមនុស្សសត្វណាមួយក្នុងអតីតជាតិ" ។ ឯវិធីនៃការកើតទៀតនិងការរលត់ទៅវិញ ជាធម៌កើតឡើងដោយវិបាករបស់កម្ម ហើយជាធម៌សម្រេចកិច្ចចុតិនិងបដិសន្ធិនេះ ឬ បើនិយាយពាក្យមួយម៉ាត់ទៀតឲ្យចំតែម្ដង និយាយថា មិនតឹអ្វីទេ គឺកម្មប្រកបដោយចេតនា (តណ្ហា) នេះឯង ។ សេចក្ដីពិត កម្មដែលយើងធ្វើខ្លួនយើងនេះ ជារបស់ខ្លួនយើង ជាមត៌ករបស់យើង ជាកំណើតរបស់យើង ជាផៅពង្សរបស់យើង ជាតំនាក់របស់យើង ។ កម្មនេះហើយ ចែកសត្វឲ្យទៅទាប ឲ្យទៅខ្ពស់ = (កម្មស្សកា កម្មទាយា កម្ម-យោនី កម្មពន្ធូ កម្មប្បដិសរណា កម្មំ សត្តេ វិភ-ជតិ យទិទំ ហីនប្បណីតតាយ) ។

# បទទីបី

## ហេតុផលដែលគួរជឿថាមានអតីតជាតិ

ដូចម្ដេចក៏យើងជឿថា "មានអតីតជាតិ"? សក្ខីភាពដ៏មានតម្លៃគួរទុកជាបានការប្រសើរបំផុត របស់ពុទ្ធសាសនិកជនទាំងឡាយ ដែលតែងតែពោលអាងថា "មានកំណើតថ្មីទៀត=(បុនព្ភវោ)" នោះ គឺអង្គព្រះសម្ពុទ្ធ ព្រះអង្គទ្រង់មានព្រះបញ្ញាញាណដ៏វិសេស ធ្វើឲ្យព្រះអង្គជ្រាបច្បាស់ថា "មានអតីតជាតិនិងអនាគតជាតិ" ។ ទ្រង់ត្រាស់ថា[១]

ក—រាជកុមារ! កាលនោះ តថាគតបរិភោគអាហារគ្រោតគ្រាតធ្វើឲ្យមានកម្លាំងកាយហើយ ស្ងប់ស្ងាត់ចាកកាមនិងអកុសលធម៌ទាំងឡាយ បានលុះឈានទីមួយ ទីពីរ ទីបី ទីបួន មានសតិបរិសុទ្ធ តាំងនៅក្នុងឧបេក្ខា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។

រាជកុមារ! តថាគតមានចិត្តតាំងនៅមាំ មានចិត្តបរិសុទ្ធ ផូរផង់ មិនមានទួលគឺកិលេស អស់ឧបក្កិលេសហើយ ជាចិត្តទន់ គួរដល់ការងារ មិនញាប់ញ័រទៅតាមអារម្មណ៍ ហើយបង្អោនចិត្តទៅកាន់បុព្វេនិវាសានុស្សតិញ្ញាណ "ញាណៈមើលទៅឃើញបុព្វជាតិ" តថាគតរលឹកឃើញបុព្វេនិវាសច្រើនអនេក គឺរលឹកបានមួយជាតិ ពីរជាតិ បីជាតិៗលៗ

១ — សុត្តន្តបិដក ភាគ ៤៤ មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក រាជវគ្គ ពោធិរាជកុមារសូត្រ ទំព័រ៣៨៦... ។ មហាសីហនាទសូត្រ សគារវសូត្រ មានដូច្នេះដែរ ។

មួយសែនជាតិ ច្រើនកប្ប ថាកាលនោះ តថាគតបានកើតក្នុងភពនោះ ឈ្មោះដូច្នេះ គោត្រត្រកូល ពណ៌សម្បុរ អាហារបរិភោគ សុខ ឬទុក្ខដូច្នេះ មានអាយុប៉ុណ្ណោះ លុះច្យុតពីភពនោះហើយ បានទៅកើតក្នុងភពនោះទៀត ឈ្មោះនេះ គោត្រត្រកូល ពណ៌សម្បុរ អាហារបរិភោគ សុខឬទុក្ខ អាយុប៉ុណ្ណោះ លុះច្យុតពីភពនោះៗ ហើយបានទៅកើតក្នុងភពនោះៗ ទៀតៗ តថាគតបានរលឹកឃើញខន្ធដែលធ្លាប់អាស្រ័យនៅក្នុងអតីតភព ច្រើនណាស់ ព្រមទាំងអាការៈនិងលក្ខណៈ (សឧទ្ទេស) ទៀតៗ

រាជកុមារ! នេះជាវិជ្ជាទីមួយ ដែលតថាគតបានត្រាស់ដឹងក្នុងបឋម-យាមនៃរាត្រីកាល ។ អវិជ្ជាបាត់ទៅ វិជ្ជាកើតឡើង ងងឹតបាត់ទៅ ពន្លឺកើតឡើង ដល់តថាគត ដែលជាអ្នកមិនប្រមាទ ព្យាយាមដុតកិ-លេស មានចិត្តបញ្ជូនទៅកាន់និព្វាន ។

២–" រាជកុមារ! តថាគត មានចិត្តតាំងនៅមាំ មានចិត្តបរិសុទ្ធ ផូរផង់ មិនមានធូលីគឺកិលេស អស់ឧបក្កិលេសហើយ ជាចិត្តទន់ គួរដល់ការងារ មិនញាប់ញ័រទៅតាមអារម្មណ៍ ហើយបង្អោនចិត្តទៅកាន់ ចុតូបបាតញ្ញាណ "ញាណមើលឃើញសត្វច្យុត" ។ កាលនោះ តថាគតមានចក្ខុទិព្វគន្ធផុតហួសវិស័យចក្ខុមនុស្សធម្មតា បានឃើញនូវពពួកសត្វ ដែលច្យុត ដែលកើត ជាសត្វថោកទាបឬប្រសើរ មានពណ៌សម្បុរល្អឬអាក្រក់ មានសុគតិ ឬទុគ្គតិ ។ល។ តថាគតបាន

ឃើញច្បាស់នូវពពួកសត្វ ដែលកើតទៅតាមយថាកម្មរបស់ខ្លួន ។

រាជកុមារ ! នេះជាវិជ្ជាទីពីរ ដែលតថាគតបានត្រាស់ដឹង ក្នុងមជ្ឈិមយាមនៃរាត្រីកាល ។ អវិជ្ជាបាត់ទៅ វិជ្ជាកើតឡើង ងងឹតបាត់ទៅ ពន្លឺកើតឡើង ដល់តថាគត ដែលជាអ្នកមិនប្រមាទ ព្យាយាមដុតកិលេសមានចិត្តបញ្ជូនទៅកាន់និព្វាន ។

គ– " រាជកុមារ ! តថាគតមានចិត្តតាំងនៅមាំ មានចិត្តបរិសុទ្ធផូរផង់ មិនមានទួលគឺកិលេស អស់ឧបក្កិលេសហើយ ជាចិត្តទន់ គួរដល់ការងារ មិនញាប់ញ័រទៅតាមអារម្មណ៍ ហើយបង្អោនចិត្តទៅកាន់អាសវក្ខយញ្ញាណ "ញាណធ្វើឲ្យអស់អាសវធម៌" ។ កាលនោះតថាគតបានដឹងច្បាស់តាមពិតថា "នេះទុក្ខ នេះធម៌ជាហេតុនាំឲ្យកើតទុក្ខ នេះធម៌ជាគ្រឿងរលត់ទុក្ខ នេះបដិបទាជាហេតុនាំរលត់ទុក្ខ" ។

ពុទ្ធសាសនិកជន ជាសាវ័កព្រះអង្គ បានប្រតិបត្តិតាមធម្មវិន័យព្រះអង្គ បានចម្រើនបញ្ញាឲ្យកើតមានឡើង ហើយបានមើលឃើញច្បាស់នូវបុព្វជាតិរបស់ខ្លួនតាមពិត ហើយច្រើនអនេកទៀត ។ ការបានសម្រេចបញ្ញាដ៏ប្រសើរបែបនេះ ពុំមែនមានខេត្តខណ្ឌចំពោះតែសាវ័កព្រះសម្ពុទ្ធទេ អ្នកណាមួយក៏ដោយ ទោះជាសាវ័កព្រះសម្ពុទ្ធក្តី ទោះជាអ្នកដទៃក្តី ក៏អាចធ្វើឲ្យកើតមានឥទ្ធានុភាពប្រសើរបែបនេះបានដូចគ្នា ។ នៅប្រទេសឥណ្ឌា ពីសម័យព្រេងនាយ មានតាបសឫសីច្រើននាក់ បាន

សម្រេចវិជ្ជានេះ មានតាបសកាលទេវិល ឬ អសិតជាដើម ដែលបាន ព្យាករទុកថា ព្រះសិទ្ធត្ថ រាជកុមារ នឹងបានត្រាស់ដឹងជាអង្គព្រះសម្ពុទ្ធ ហើយពុំមែនដឹងត្រឹមតែប៉ុណ្ណឹងទេ អាចមើលទៅខាងអតីតយ៉ាងឆ្ងាយឆ្ងាយទៀតផង ។ យើងក្នុងបច្ចុប្បន្នកាលនេះ បើយើងបាន ប្រតិបត្តិតាមគន្លងធម៌ត្រឹមត្រូវ យើងអាចសម្រេចឥទ្ធានុភាពនេះបានដែរ ការសម្រេចបែបនេះ ពុំមែនបានតែមនុស្សបរមបូកណានោះទេ ។

តាមធម្មតា យើងសព្វថ្ងៃនេះ តែងមានក្តីសង្ស័យថា តើគេអាចធ្វើឲ្យកើតមានញាណជាគ្រឿងរលឹកជាតិ បានដែរឬអ្វី ? ក្រែងធម៌នេះហួសវិស័យមនុស្សទេដឹង ?

ទេ ! ពុំមែនហួសទេ មនុស្សមានសមត្ថភាពបរិបូណ៌ ការបានភាពជាមនុស្សនេះ ប្រសើរណាស់ ក្នុងមនុស្សភាព " មានភាពអាចបានគ្រប់ " មនុស្សជាកល្បព្រឹក្ស ឬ កែវមណីជោតិ បើគេបានខ្ចានខ្លួនគេល្អហើយ ។ ចូរក្រឡេកមើលវត្ថុអស្ចារ្យ ដែលកើតឡើងដោយដៃមនុស្សនៅក្នុងលោកនេះចុះ ! សព្វថ្ងៃនេះ អ្នកវិទ្យាសាស្ត្របានសាងវត្ថុប្រើប្រាស់ឲ្យកើតមានយ៉ាងសម្បើមអស្ចារ្យ ។ ដូច្នេះ ពុំគួរនឹងមានក្តីសន្ទិះសង្ស័យចំពោះការចម្រើនការនាំឲ្យកើតបញ្ញាញាណ ដែលជាធម៌ធ្វើឲ្យរលឹកជាតិបាននោះទេ ។ យើងទាំងអស់គ្នា គួរតែអរគុណយ៉ាងក្រៃ-លែងចំពោះអ្នកវិទ្យាសាស្ត្រ ដែលមានព្យាយាមល្អ បានបង្កើតគ្រឿង

ឧបភោគបរិបូណ៌ហូរហៀរ នាំឲ្យកើតជាសុខដល់យើងជាមនុស្សលោកគ្រប់គ្នា ៗ សព្វថ្ងៃ យើងគ្រាន់តែអង្គុយនៅក្នុងផ្ទះយើង យើងអាចស្តាប់សម្លេង មើលរូបដែលផ្សាយចេញមកពីគ្រប់ទិសយ៉ាងសប្បាយ ៗ ដោយវិទ្យាសាស្ត្រ គេទៅដល់លោកព្រះចន្ទអស់ទៅហើយ ! ចុះវត្ថុទាំងអស់នេះ តើកើតមកពីណា ? មិនគឺជាស្នាដៃរបស់មនុស្សទេឬ ? បើយើងឃើញប្រត្យក្សនឹងភ្នែកយើងដូច្នេះហើយ ម្តេចឡើយក៏យើងមិនចេះយល់ថា "ចិត្តយើងនេះ បើយើងទូន្មានល្អហើយ នឹងអាចឲ្យលើកជាតិកំណើតយើងបានផង ? ៗ ចិត្តនេះប្រសើរណាស់ បើបានទូន្មានល្អហើយ អាចធ្វើឲ្យសម្រេចអ្វីគ្រប់យ៉ាងបាន ហើយមិនចាំបាច់ប្រើអ្វីជាឧបករណ៍ សម្រាប់ជាជំនួយដូចអ្នកវិទ្យាសាស្ត្រទៀតផង ដូចពុទ្ធភាសិតថា " មានចិត្តដល់មុន សម្រេចហើយដោយចិត្ត មានចិត្តប្រសើរ= មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា ។

ចម្លើយនេះ ពីរោះស្តាប់ដែរ តែហេតុដូចម្តេច សព្វថ្ងៃនេះក៏មិនឃើញមានមនុស្សមានញាណអាចលើកជាតិបានផង ? ឆ្លើយម្តងទៀតមកមើល បើគ្រាន់បើណាស់ !

យើងដែលឃើញអង្គព្រះសម្ពុទ្ធ ឬព្រះអរហន្តដែរឬទេ ? ចុះព្រះនារាយណ៍ចេះអវតារ ឬព្រះយេស៊ូគ្រិស្តចេះទទួលឈើឆ្កាង សព្វថ្ងៃអស់លោកទាំងនេះ នៅជាមួយយើងដែរឬអ្វី ? ពុំនោះ លោកបាត់ង់

(Platon) ណោកសេកស្ពៀរ (Shekspear) នៅឯណាឥឡូវនេះ? នេះជាចម្ងល់ត្រង់ទៅត្រង់មក ពុំមែនជាការឆ្លើយងាយទេ ។

សេចក្ដីពិត មហាបុរសដ៏ប្រសើរទាំងនេះ មិនមាននៅក្នុងកាលបច្ចុប្បន្ននេះទេ បើដូច្នេះ តើយើងមិនត្រូវមានហេតុផលគួរនឹងជឿថា មហាបុរសទាំងនោះ មិនមាននៅក្នុងអតីតកាលនោះទៅឬអ្វី ?

មានមនុស្សច្រើននាក់ណាស់ បានទូន្មានខ្លួន បានចម្រើនភាវនា ហើយកើតបុទ្ធិ បានបញ្ចេញញាណរបស់ខ្លួនឲ្យរលឹកឃើញជាតិក្នុងអតីតកាលបាន ។ ករណីពិសេសនេះ កើតមានខ្លះទៅ នៅឥណ្ឌា ក្ដីមាក៏មាន នៅទ្វីបអឺរ៉ុប ដូចប្រទេសអាល្លឺម៉ង់ អង់គ្លេសក៏មានដែរ(១) ។

ក្នុងសម័យពុទ្ធកាល(២) មានព្រាហ្មណ៍ម្នាក់ឈ្មោះវង្គីស បានចេះជំនាញជាមើលឃើញមនុស្សស្លាប់ ទៅកើតនៅទីឋានផ្សេងៗ អ្នកណាមួយចង់ដឹងមនុស្សស្លាប់ថា ទៅកើតនៅទីឋានណា យកលលាដ៍ក្បាលទៅឲ្យព្រាហ្មណ៍នោះគោះ ព្រាហ្មណ៍នេះនឹងដឹងបាន ។ កាលនោះព្រះសម្មាសម្ពុទ្ធ យកព្រះកេសព្រះអរហន្តទៅឲ្យព្រាហ្មណ៍គោះ តែព្រាហ្មណ៍នោះ កាលគោះព្រះកេសព្រះអរហន្ត គាត់មិនដឹងថា ព្រះអរហន្តអង្គនោះទៅកើតនៅឯណាទេ ។ ហេតុដែលព្រាហ្មណ៍នោះមិនដឹង ព្រោះ

---

១-The christian Doctrine of Rebirth, by Dr. . WT. Evans Wentz p. 36

២-ថេរគាថា ។

ព្រះអរហន្ត និព្វាន មិនមានជាតិកំណើតទៀតទេ ។

ដទៃពីនេះទៀត គួរលើកយកឧទាហរណ៍អ្នកចិត្តសាស្ត្រសម័យថ្មីខ្លះដែលគួរជឿបាន និងរឿងប្លែកៗខ្លះ ព្រមទាំងបុគ្គលជាន់ខ្ពស់មកនិយាយផងដែរ ព្រោះអស់លោកទាំងនេះ បានព្យាយាមធ្វើខ្លួនឲ្យជាប្រទីបតុជ្រោលបំភ្លឺឲ្យមានជំនឿថា "មានភពថ្មីទៀត(បុនព្ភវៈ)" ។

ព្រឹត្តិការណ៍ជាប្រវត្តិអស់លោកទាំងនោះជាការបន្ទាប់បន្សំទេ បានគ្រាន់តែជាឧទាហរណ៍ជាគ្រឿងពន្យល់ប្រាប់ប៉ុណ្ណោះថា "នេះជាការចេះដឹងរបស់មនុស្សម្នាក់ៗ ដែលមិនចេះស្លាប់ ហើយដែលមានសល់នៅឬជារបស់មនុស្សដែលតែងតែកើតមានឡើង" ។

រឿងទាំងនេះ យើងបានទទួលដំណឹងពីការចេះដឹងប្លែកអស្ចារ្យខ្លះដែរ តែនឹងយកមកពន្យល់ពុំបាន បើនឹងពន្យល់បាន លុះត្រាតែយក "ការកើតទៀត" (Rebirth) នេះឯង មកពន្យល់ទើបបាន ។ រឿងបែបនេះ នៅប្រទេសកាន់ពុទ្ធសាសនាមានច្រើនណាស់ ព្រោះមានពុទ្ធសាសនិកជនច្រើននាក់ដែលបានបំពេញសមាធិភាវនា ហើយបានអប់រំបន្ទុំចិត្ត ចិត្តដែលអប់រំហាត់នេះ តែងធ្វើឲ្យបានឃើញការអ្វីប្លែកៗនៅក្នុងជីវិតរបស់គេ ។ តែគុណធម៌វិសេសបែបនេះ ពុទ្ធសាសនិកជន មិនត្រូវសម្តែងចេញជាការបរិហារទេ ។

តើយើងបានជួបមនុស្ស ដែលយើងមិនធ្លាប់បានជួបកាលពីដើមតែម្ដង ក៏ជិតអង្គឹសោះ ហើយយើងមកនឹកតែកង់ចិត្តថា មនុស្សនេះ ជាទីស្និទ្ធស្នាលបំផុតរបស់យើង ? តើយើងបានទៅមើលទីឋានបុន្មានកន្លែងរបស់គេ យើងមកចាប់អារម្មណ៍ ហើយពោលថា យើងបានស្គាល់ទីឋានរបស់គេពិតប្រាកដច្បាស់លាស់ណាស់ ព្រមទាំងទីជាបរិវេណដែលនៅជុំវិញទៀតផង ? ។

កង់គម្ពីរធម្មបទ ជាអដ្ឋកថាគម្ពីរខុទ្ទកនិកាយ មានរឿងវត្ថ-និទានមួយស្ដីពីព្រាហ្មណ៍ស្វាមីភរិយា ដែលបានជួបគង្គព្រះសម្ពុទ្ធ ហើយក្រាបចុះទៀបបាទមូល នមស្ការដោយគោរព ហើយហាមាត់និយាយថា:

«កូនមាសថ្លៃសម្លាញ់អើយ ! មិនមែនជាករណីយកិច្ចនៃកូនទេឬ ដែលត្រូវថែរក្សាមាតាបិតា កង់ពេលដែលមាតាបិតាចាស់ជរាទៅហើយ? យូរលង់ណាស់ហើយ ដែលយើងមិនបានជួបមុខកូន ? ហេតុអ្វីក៏កូនមិនដែលមកបង្ហាញមុខដល់មាតាបិតាសោះ ណាមាសថ្លៃ ! ម្ដងនេះ ជាគ្រាតម្បូងហើយ ដែលមាតាបិតាបានជួបមុខកូនសំឡាញ់ ។

រំពេចនោះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ក្លាយពីក្ដីស្នេហា ដែលផុះបើកចេញមកពីដួងចិត្តនៃមាតាបិតាចំពោះបុត្រ ដោយព្រះតម្រាស់សួរក្រាំងក្រអៅថា «ព្រាហ្មណ៍ស្វាមីភរិយានេះ ធ្លាប់ជាមាតាបិតាតថាគតអស់កាលច្រើនជាតិណាស់មកហើយ» ហើយទ្រង់ត្រាស់តទៅទៀតថា :

" អាស្រ័យដោយវាសនាអំពីអតីតជាតិ និងដោយហេតុការណ៍បច្ចុប្បន្ន ទើបបុគ្គលស្នេហារីកស្គុះស្គាយ ហើយផុសចេញមកពីមាត់មាតាបិតា ដូចផ្កាឈូក ដែលរីកផុះចេញមកពីទឹក " ។

ព្រះអរហន្តទាំងឡាយប្រាកដដូចអង្គព្រះសម្ពុទ្ធ ដែលបានកើតឡើងក្នុងលោក ហើយដែលប្រកបដោយបុគ្គលិកលក្ខណៈ ជាមហាបុរសដ៏ខ្ពង់ខ្ពស់យ៉ាងនេះ តើព្រះអរហន្តទាំងនោះ លោកកសាងបុគ្គលិកលក្ខណៈប្រពៃនេះបានភ្លាម ៗ ទៅឬអ្វី ? ពុំនោះ មហាបុរសលក្ខណៈប្រាកដដូច្នេះ ជាផលដែលកើតឡើងតែក្នុងបច្ចុប្បន្នកាលមួយនេះទេឬអ្វី ? ចុះឥឡូវ ម្តេចឡើយ យើងចេះពណ៌នាបុគ្គលិកលក្ខណៈលោកហូមែរ ( Homer ) និងលោកបាតុង ថាជាបុគ្គលសម្បើមអស្ចារ្យ ឬបុគ្គលិកលក្ខណៈប្រសើរ លោកសេកស្ពៀរ ថាជាបុគ្គលមានទេពកោសល្យដ៏អស្ចារ្យ ឬក៏លោកប៉ាស្កាល់ ( Pascal ) លោកម៉ូសា ( Mozart ), លោកបេតូវេន ( Beethoven ) លោករ៉ាហ្វាអែល ( Raphael ) ។ល។ ថាជាអ្នកប្រាជ្ញមានប្រាជ្ញាដើមកើត ?

ធម៌បិតាគត មួយនេះ ពុំគួរនឹងលើកយកមកនិយាយប្រដូចចំពោះព្រះអរហន្តបានទេ ចាំបាច់និយាយថ្វីចំពោះព្រះអរហន្តនុ៎ះ សូម្បីតែអ្នកប្រាជ្ញដូចយើងបានចេញឈ្មោះមកហើយ ក៏ពុំគួរដែរ ដូចជាថាបុគ្គលប្រុសខ្ពស់យ៉ាងណា ខ្ពស់ក៏យ៉ាងនោះដែរ បញ្ចាជនតមក សូម្បីមានចំនួន

ច្រើនយ៉ាងណាក៏ដោយ ក៏ពុំដូចបុព្វបុរសខ្លួនដែរ ។

ធម៌បិតាគត បើថាជាធម៌ពិត បញ្ចេញប្រាជ្ញមកមើល ! តើគេអាចឡើងដល់ភាពខ្ពង់ខ្ពស់ ដូចមហាបុរសទាំងនោះបានឬទេ? ប្រសិនបើគេមិនបានកសាងខ្លួនគេ ឬមិនបានទូន្មានខ្លួនគេឲ្យត្រឹមត្រូវតាមគន្លងធម៌ពីអតីតកាលទេ តើគេអាចកើតពីមាតាបិតា ដែលមានបុគ្គលិកលក្ខណៈខ្ពង់ខ្ពស់ដោយចៃដន្យ ហើយខ្លួនយើងក៏បានភាពខ្ពង់ខ្ពស់តាមកាលៈទេសៈនេះបានឬទេ ? ទៅពុំបានទេ !

"ឯទ្រឹស្ដីបិតាគតនេះ បើថាទីងត្រូវកើតមាន ក៏ត្រូវតែយកទ្រឹស្ដី "កម្ម" និង "ការកើតទៀត = (ជាតិ) ទៅនិយាយផងដែរ ទើបអាចដោះស្រាយប្រស្នាពាក់ស្រេះនេះបានល្អ ។ អ្នកនិពន្ធបស្ចិមច្រើននាក់បានសរសេរទុកថា :

"ទោះយោបើយើងជឿក្ដី មិនជឿក្ដី ចំពោះធម៌ដែលថាមាន "អតីតគត" នេះក៏ដោយ តែការនេះ គ្រាន់តែជាសម្មតិកម្មសមហេតុផលមួយទុកជាស្ពានសម្រាប់ឆ្លងទៅដល់មនុស្សវិទ្យា ដែលជាវិជ្ជាការកសាងជីវភាពៈយើងកាលនៅតែប៉ុណ្ណោះ ។ តែហេតុផលក៏បានបញ្ជាក់ប្រាប់យើងដែរថា ឧត្តមគតិ ដែលស្ដីពីអតីតជាតិ គឺ "កម្ម" តែមួយនេះទេ ដែលអាចពន្យល់ភាពផ្សេង ៗ គ្នា រវាងមនុស្សពាក់ដូចគូនក្ដោះនេះបាន ។ មួយទៀត គ្មាគិតមើលដែរ មនុស្សដូចពេកក សេកស្ទីរ នេះ ម្ដេចក៏

មានលក្ខណៈពិសេសប្លែកអ្វីម្ល៉េះ? ចេះកម្រិតការធ្វើរបស់ខ្លួនឲ្យបានត្រឹមត្រូវបំផុត ចេះធ្វើគ្រាប់មនុស្សដែលមានចរិតផ្សេងគ្នាច្រើនអនេក ធ្វើឲ្យដូចពិតប្រាកដអស្ចារ្យ សម្តែងគួរលោភ ឬធ្វើអ្វីបានប្រសើរបំផុត ហើយសម័យនោះ ការសិក្សា ពុំទាន់បានទូលាយ ដូចកាលបច្ចុប្បន្ននេះផង ហេតុអ្វី ក៏បានជាស្នាដៃរបស់លោក មានទេពកោសល្យប្រសើរវិសេស លើសអ្នកដែលបានទទួលការសិក្សាទៅទៀត? ហេតុអ្វីក៏លោកកើតមានបុញ្ញាសនាចប្លែកដូច្នេះ? ឯនានាភាពដ៏ធំទូលាយ ក៏មានពិតប្រាកដនៅក្នុងចិត្តនិងគំនិតលោក ក្នុងខួរក្បាលនិងកាយរបស់លោក ក្នុងលក្ខណៈគ្រប់បែប គ្រប់កាលៈទេសៈ នៅជុំវិញខ្លួនលោក ។ លោកចេះពិនិត្យសង្កេតៈ ស្វារ្យទួទៅពេញសកលលោក ។ល។ រឿងនេះ មានហេតុផលគ្រប់គ្រាន់ គួរជឿថា "ខណៈចិត្តដ៏ខ្លីមួយនៃជីវិតលោកក្នុងបច្ចុប្បន្នកាលនេះ គឺជាតំណនៃជីវិតមួយនៅក្នុងអតីតកាល ដែលមាននិត្យធម៌ពីរប្រការ គឺ សុខនិងទុក្ខ" ដែរឬទេ ?

យើងអាចរស់នៅក្នុងលោកនេះ ត្រឹមតែ ៤០ ឬ ៣០ ឆ្នាំប៉ុណ្ណោះ បើយើងមិនចេះបរិហារកាយៈយើងតាមអាយុស្សធម៌ទេ តែបើចេះប្រតិបត្តិតាមធម៌នេះត្រឹមត្រូវ នឹងអាចរស់នៅបានដល់ ១០០ ឆ្នាំ ដែលជាអាយុក្ស័យរបស់មនុស្សលោក ។ បើជឿថា មានបច្ចុប្បន្នជាតិនិងអនាគតជាតិ ក៏គួរតែជឿថា មានអតីតជាតិដែរ មែនឬទេ ? បើយើងជឿ

ថា យើងធ្លាប់មានជីវិតរស់នៅក្នុងអតីតកាលហើយ យើងក៏ត្រូវជឿថា យើងនឹងត្រូវកើតតទៅទៀត បន្ទាប់ពីការបែកធ្លាយកាយក្នុងបច្ចុប្បន្នជាតិនេះទៅ បើនៅមានធម៌ជាបច្ច័យ ។

មួយទៀត មានអ្នកខ្លះ ពោលអួតអាងម៉ឺងម៉ាត់ដោយជឿជាក់ថា: "មានអតីតជាតិ និងអនាគតជាតិ" តែដោយមានការយល់មិនសព្វគ្រប់ ទៅជានិយាយថា "ក្នុងលោកនេះ អ្នកធ្វើល្អ មិនបានទទួលភ័ព្វសំណាប្រសើរទេ ឯអ្នកធ្វើអាក្រក់ ច្រើនបានទទួលភ័ព្វសំណាប្រសើរទៅវិញ ។ ដរាបណា ការចេះដឹងយើងនៅទន់ខ្សោយ ដរាបនោះ ការយល់របស់យើង តែងតែមិនសព្វគ្រប់ជាធម្មតា ។

ហេតុពិត កុសលកម្ម តែងឲ្យផលល្អ អកុសលកម្ម តែងឲ្យផលអាក្រក់ ។ អ្នកធ្វើល្អ មិនបានទទួលភ័ព្វសំណាប្រសើរ ព្រោះអកុសលកម្មរបស់ខ្លួនឲ្យផល មិនមែនជាកុសលកម្មទេ អ្នកធ្វើអាក្រក់បានទទួលភ័ព្វសំណាប្រសើរ ព្រោះកុសលកម្មរបស់ខ្លួនឲ្យផល មិនមែនជាអកុសលកម្មទេ ។ ក្នុងលោកដែលសត្វអន្ទោលស្លាប់កើតនេះ មនុស្សម្នាក់ៗ ធ្វើល្អក៏មាន ធ្វើអាក្រក់ក៏មាន ផលកម្មឲ្យផលផ្លាស់ប្ដូរតាមយថាកម្មរបស់ខ្លួន ។ ដរាបណា អ្នកធ្វើល្អ មិនទាន់ទទួលផលល្អ ដរាបនោះ អ្នកធ្វើល្អ ត្រូវតែទទួលនូវអកុសលកម្មរបស់ខ្លួន ។ ដរាបណា អ្នកធ្វើអាក្រក់ មិនទាន់បានទទួលផលអាក្រក់ ដរាបនោះ អ្នកធ្វើអាក្រក់

នោះ ត្រូវតែទទួលផលកុសលកម្មរបស់ខ្លួន ៗ ដោយកម្មជាច្បាប់ធម្មជាតិ ជាច្បាប់យុត្តិធម៌ មិនមែនជាច្បាប់តុលាការ កុសលកម្មក្តី អកុសលកម្មក្តី ប្រាកដជាឲ្យផលវិបាករបស់កម្ម ក្នុងឱកាសណាមួយពុំខានឡើយ ៗ

# រឿងភិក្ខុប្រាំរយរូប

## អដ្ឋកថាធម្មបទ បណ្ឌិតវគ្គទី ៦ ភាគទី ៤

លោក ប៊ូ - ប៊ូ ប្រែរៀបរៀង

---

កាលព្រះបរមសាស្តាគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនឹងភិក្ខុប្រាំរយរូប ទ្រង់សម្តែងធម៌ដោយបទគាថាថា សព្វត្ថ វេ សប្បុរិសា វជន្តិ ដូច្នេះជាដើម ។

ធម្មទេសនានេះ ចាប់ផ្តើមកើតឡើងក្នុងស្រុកវេរញ្ជា ។ សេចក្តីពិស្តារថា កាលព្រះមានព្រះភាគទើបនឹងបានត្រាស់ដឹងជាតម្បូង ស្តេចធ្វើពុទ្ធដំណើរទៅឯស្រុកវេរញ្ជា ហើយវេរញ្ជព្រាហ្មណ៍ ក៏បាននិមន្តព្រះអង្គ ព្រមទាំងភិក្ខុប្រាំរយរូប ឲ្យគង់ចាំវស្សានៅស្រុកនោះ ។ ថ្ងៃមួយ វេរញ្ជព្រាហ្មណ៍ ត្រូវមារបញ្ចូលចិត្ត ឲ្យប្រែឡប់ភ្លេចស្មារតី ពុំបាននឹករឭកឃើញព្រះសាស្តាសោះ ។ ពេលនោះ ជួនជាស្រុកវេរញ្ជាកើតទុភិក្សខ្សត់ខ្សាយ ។ ពួកភិក្ខុ និមន្តទៅស្ទើរកបិណ្ឌបាតក្នុងស្រុកវេរញ្ជា សព្វច្រកល្ហក ទាំងខាងក្នុងស្រុកខាងក្រៅស្រុក ពុំបានបង្ហាន់បិណ្ឌបាតសោះ ក៏នឿយព្រួយលំបាក ។ ពួកឈ្មួញសេះបាននាំគ្នាប្រគេនបាយមួយពំនូតៗដល់ភិក្ខុទាំងនោះ ។ ព្រះមហាមោគ្គល្លានត្ថេរ បានឃើញភិក្ខុទាំងនោះលំបាកដូច្នោះ ក៏នឹកចង់ឲ្យភិក្ខុទាំងនោះឆាន់នូវជាសេ

នៃផែនដី ហើយទិនបំណាន់ចង់ឲ្យភិក្ខុទាំងនោះចូលទៅយកបិណ្ឌបាតនៅ ឧត្តរកុរុទ្វីប ។ ប៉ុន្តែ ព្រះបរមសាស្តាទ្រង់ហាមឃាត់មិនឲ្យព្រះមហា-មោគ្គល្លានត្ថេរ ធ្វើតាមគំនិតនោះទេ ។ ភិក្ខុទាំងឡាយ ក៏ពុំមានសេចក្តីតក់ស្លុត ចំពោះការអត់បិណ្ឌបាត សូម្បីតែក្នុងថ្ងៃណាមួយឡើយ ហើយនៅតែខំប្រឹងលះបង់ឥច្ឆាចារគឺការប្រព្រឹត្តខុស ជារៀងមក ។ ព្រះបរមសាស្តា គង់ចាំវស្សាក្នុងស្រុកវេរញ្ជានោះគ្រប់ត្រៃមាសហើយ ទ្រង់លាវេរញ្ជព្រាហ្មណ៍ ។ ក៏ធ្វើសក្ការបូជាព្រះអង្គ ។ ឲ្យវេរញ្ជព្រាហ្មណ៍ស្ថិតនៅក្នុងសរណគមន៍ រួចទើបស្តេចចេញពីស្រុកនោះ ធ្វើពុទ្ធដំណើរទៅកាន់ចារិកតាមលំដាប់ ក្នុងសម័យមួយ ទ្រង់បានទៅដល់នគរសាវត្ថី គង់នៅក្នុងវត្តជេតពន ។ ពួកអ្នកនគរសាវត្ថី ក៏នាំគ្នាថ្វាយអាគន្តុកទានចំពោះព្រះសាស្តា ។ ក្នុងគ្រានោះ មានមនុស្សប្រមាណប្រាំរយនាក់សម្នាក់នៅក្នុងវត្តជេតពន ជាអ្នកបរិភោគបាយសេសសល់ដែលអំពីភិក្ខុទាំងឡាយដែលឆាន់រួច , អ្នកទាំងនោះ កាលបានបរិភោគភោជនដ៏ប្រណីតថ្លៃថ្លា ដែលសេសសល់អំពីភិក្ខុទាំងពួងឆាន់ ឆ្អែតហើយ ក៏នាំគ្នាដេកលក់ទៅ លុះភ្ញាក់ពីដេក ក៏ទៅឯទន្លេស្ទឹង ស្រែកហ៊ោកញ្ជ្រៀវចែកគ្នាជាពួក ជល់គ្នា ច្បាំងគ្នាលេង ធ្វើអំពើមិនសមគួរក្នុងវត្តផងក្រៅវត្តផង ។ ភិក្ខុទាំងឡាយ ក៏ប្រជុំគ្នានិយាយក្នុងរោងធម៌ថា ម្នាលអាវុសោ ទាំងឡាយ ! អស់លោក ចូរមើល ! អ្នកបរិភោគបាយ

សល់ដែលទាំងនេះ មិនបញ្ចេញអាការដ៏ថ្លៃកអ៊ើសោះ ក្នុងស្រុកវេរញ្ជា កាលគ្រាកើតទុរ្ភិក្ស, ដល់មកឥឡូវនេះ បានបរិភោគភោជនដ៏ថ្លៃថ្លា បែបនេះ ស្រាប់តែបញ្ចេញអាការប្លែកៗ ជាច្រើនប្រការ, ចំណែកពួកភិក្ខុវិញ កាលនៅក្នុងស្រុកវេរញ្ជា ក៏ស្ងប់ស្ងៀម, ដល់មកឥឡូវនេះ ក៏ស្ងប់ស្ងៀមដែរ ។

ព្រះបរមសាស្តា ស្តេចមកដល់រោងធម៌ ទ្រង់ត្រាស់សួរភិក្ខុទាំងនោះ លុះបានជ្រាបសេចក្តីនោះហើយ ក៏ត្រាស់ថា កាលពីជាតិមុន អ្នកស៊ីដែលទាំងនោះ កើតក្នុងកំណើតជាសត្វលាប្រមាណប្រាំរយ បានផឹកទឹកមានរសជាតិ ដ៏តិចតួចថោកទាប ជាទឹកដែលគេត្រងចុងក្រោយបំផុត គឺគេយកផ្លែចិនស្រស់ មកច្របាច់យករសជាតិផ្អែមឆ្ងាញ់ឲ្យសេះសិន្ធពអាជានេយ្យប្រាំរយផឹក ទឹកអស់ទៅ នៅសល់តែកាក ហើយគេយកកាកនោះគ្របាច់លាយនឹងទឹកសាប រួចយកសំពត់ត្រោលត្រង យកទឹកសាបនោះឲ្យលាទាំងប្រាំរយផឹក, លាទាំងនោះ ក៏ស្រែកកញ្ជ្រៀវស្រវឹងទឹកផ្អែមដូចជាមេឃ្ញុំ ដែលហៅថាឃ្លុំក្រហាយទឹក ។ គ្រានោះព្រះកពាគុះឮសម្លេងលាទាំងនោះ ក៏ទ្រង់ត្រាស់សួរពោធិសត្វ ។ ក្រោះទូលអំពីកិរិយារបស់លាថា :

"ពួកណានោះ បានផឹកទឹកសាប ឥតរសជាតិ ដែលគេត្រងចុងក្រោយបំផុត ជាទឹកថោកទាប ក៏ទៅជាស្រវឹងដែរ, ឯពួកសេះសិន្ធព

បានផឹកទឹកមានរសជាតិថ្លៃថ្លា ហើយមិនបេះស្រវឹងសោះ, មនុស្សមានជាតិកំណើតថោកទាប សូម្បីផឹកទឹកសាប ឥតរសជាតិ ក៏ទៅជាស្រវឹងដែរ ដោយសារតែទឹកនោះចូលទៅក្នុងពោះ, បពិត្រព្រះអង្គជាធំជាងនរជន! រីលោកជាអ្នកមានសីល ជម្រះសីលស្អាតបរិសុទ្ធល្អ ហើយបានកើតក្នុងត្រកូលខ្ពស់ បើទុកជាបានក្រេបផឹកទឹកមានគុណរសខ្ពង់ខ្ពស់ ក៏លោកមិនបេះស្រវឹងដែរ» ។ កាលព្រះបរមសាស្ដាទេសនានូវវាលោទកជាតក នេះ ដោយពិស្ដារចប់ចុះហើយ ទ្រង់ត្រាស់ថា «ម្នាលភិក្ខុទាំងឡាយ! ពួកអ្នកសប្បុរស តែងលះបង់នូវធម៌លោកចេញ ក្នុងកាលដែលខ្លួនបានសុខក្ដី បានទុក្ខក្ដី ក៏មិនបញ្ចេញអាការឲ្យប្លែកពីប្រក្រតីឡើយ» ហើយព្រះអង្គសម្ដែងធម៌តទៅទៀតដោយបទគាថាថា៖

សព្វត្ថ វេ សប្បុរិសា វជន្តិ
ន កាមកាមា លបយន្តិ សន្តោ
សុខេន ផុដ្ឋា អថ វា ទុខេន
ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។

ពួកសប្បុរស តែងលះបង់(នូវឆន្ទរាគ)ក្នុងធម៌ទាំងពួង, ពួកលោកអ្នកស្ងប់ រមែងមិនរអែរអូរ ព្រោះសេចក្ដីប្រាថ្នាកាម, ពួកបណ្ឌិតបើសេចក្ដីសុខឬទុក្ខពាល់ត្រូវហើយ រមែងមិនសម្ដែងនូវអាការៈឡើងចុះឡើយ ។

សេចក្ដីសង្ខេបក្នុងរឿងភិក្ខុប្រាំរយរូប ៖

ព្រះសាស្ដាស្ដេចចូលទៅក្នុងក្រុងវេរញ្ជា ទ្រង់គង់ចាំវស្សាជាមួយនឹងភិក្ខុប្រាំរយរូប រកអាហារបន្តិចបន្តួចបានដោយលំបាក ព្រោះស្រុកកើតទុរ្ភិក្ស លុះស្ដេចចេញចាកក្រុងវេរញ្ជាមកឯក្រុងសាវត្ថីវិញ ក៏មានអាហារល្អសម្បូរហូរហៀរ ។ ឯពួកអ្នកស៊ីបាយដែល ត្រឡប់ទៅជាមនុស្សគ្រេកគ្រអាលក្អើតក្អើនវិញ ។

រឿងភិក្ខុប្រាំរយរូប ចប់ ។

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា

## នូ - កន

## ប្រែ - រៀបរៀង

## (៣)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ

យូរ-អ៊ិន

អង់ឡូង ឮដូច្នោះ ក៏បរសេះចូលទៅដល់មុខរទេះខុងបេង, ទាំងពីរប្រាណក៏ឱនគំនាប់គ្នាតាមទំនៀម, ហើយអង់ឡូងនិយាយនឹងខុងបេងថា : ខ្ញុំបានឮកិត្តិស័ព្ទល្បីល្បាញឈ្មោះអ្នកយូរណាស់មកហើយ, អ្នកអើយ ថ្ងៃនេះ ទើបប្រទះជួបឃើញមុខគ្នាជាក័ព្ទគាប់ប្រៃពៃណាស់, ខ្ញុំ អ្នកជាមនុស្សមានវិជ្ជាជ្រៅជ្រះ ដឹងច្បាស់នូវទំនៀមទម្លាប់ច្បាប់រាជការផែនដី, ហេតុអ្វី ទៅចូលគប់ប្រសព្វនឹងអាមនុស្សពាលក្រកូលអាបថោក ហើយលើករេហ៍ពលមកទល់តនឹងយើងដូច្នេះ ? ។

ខុងបេងឆ្លើយតបថា: អ្នកឯងមិនគួរនឹងហ៊ានមកបរិហារដូច្នេះសោះ, ព្រោះព្រះចៅឡៅពី ជាម្ចាស់ខ្ញុំនោះ ប្រាកដជាពូជព្រះរាជវង្សព្រះចៅហៀនតេមែនពិត, ព្រះអង្គទ្រង់រិះគិតចំនុកបម្រុងផែនដីឲ្យសុខ ត្រាស់

បង្គាប់យើងទុកឲ្យចាំកម្ចាត់អាចោរក្បត់ សត្រូវរាជសម្បត្តិចេញឲ្យបាន , បានជាយើងលើកទាហានទន្ទ្រានចូលមក ។ អង្គឡង់ឆ្លើយថា: "បុរាណ-រាជប្រវេណីពីដើមមក លោកថា ផែនដីនោះនឹងចំពោះកាន់យកជាទៀងពុំបាន, នរណាក្លាហានមានចេស្តានុភាព អាចក្រោបបច្ចាមិត្រយករាជ-សម្បត្តិបានដោយពលការ, ត្រូវហៅថា អ្នកនោះ ជាក្សត្រិយ៍ដ៏ប្រពៃ, ឯផែនដីនៃវង្សព្រះចៅហៀនគេនោះ ចុះរៀវរេយដោយសេចក្តីអន្តរាយគ្រប់ខែត្រ, មានកើតហេតុជាចលាចលរាល់ឆ្នាំរៀងមក ពុំដាច់, កាលព្រះចៅលេនគេ នៅសោយរាជ្យជាស្តេច, ក៏កើតពួកចោរដួតឈ្មួតក្បាលលឿងបះបោរឡើងពេញស្រុក, បណ្តារាស្ត្រ ក៏កើតកលយុគជាទុក្ខក្តៅក្រហាយណាស់, លុះព្រះចៅហៀនគេបានសោយរាជ្យជាម្ចាស់, តាំង-តុ ប្រព្រឹត្តអាក្រក់ផ្សេងៗ កើតចលាចលរាល់កន្លែងទូទាំងព្រះរាជធានី, ក្រោយទៀត លីឈុយ-គុយតឹកញីញក់, ធ្វើឲ្យស្តេចនិងរាស្ត្រកើតទុក្ខ, នោះអស់ពួកចៅហ្វាយស្រុកគឺ អ៊ូនសុត , អ៊ូនសៀវ , ឡេវពៀវ , លីប៉ោជាក្បត់ តាំងខ្លួនជាស្តេចដោយសន្មតតែគ្នាឯង, ប្រវែងដណ្តើមស្រុកមិនចំណុះអ្នកណា, រាស្ត្រប្រជាក៏កើតក្តៅក្រហាយពន់ប្រមាណ ។ គ្រានោះ, ព្រះចៅហៀនគេក៏បានខ្លួនទុក្ខទុរន់ដូចពងមាន់តាំងនៅលើថ្មសិលាហាក់តែបានព្រះចៅរ៉ុយអងមានបុណ្យវាសនាជាម្ចាស់យើង ជួយឧបត្ថម្ភគាំពារ , ក្តុំពលយោធា កម្ចាត់សត្រូវទាំងនោះឲ្យវិនាសប្រាសទៅបាន ,

ទើបព្រះចៅហៀនគេ នូវអស់អាណាប្រជានុរាស្ត្រសព្វឋាន បានធ្លេចភ្ញែកដេកលក់សុខមកដល់សព្វថ្ងៃនេះ, ហេតុដូច្នេះ ទើបបណ្តាលឲ្យមានភ្លៀងបង្អុរជោរជនពល់ដូវ, ពស្ត្រ បានធ្វើស្រែស្រូវ នូវសារពើដំណាំដាំចម្ការ, ស្បៀងអាហារគឺបរិបូណ៌ពេញលេញ, ឈ្មួញជួញប្រែកំរៃមានចំណេញ មិនខ្វះខាតសព្វទីឋាន ។

ពាក្យចាស់បុរាណមានពោលទុកថា : កើតជាមនុស្ស នៅលើផែនដី, គប្បីឲ្យចេះពិគ្រោះពិចារណាមើលការសម្ងាយ, បើនឹងរើសរកចៅហ្វាយរកនាយ ត្រូវឲ្យរកអ្នកមានបុណ្យសម្ភារបារមី, ទើបគប្បីឲ្យចូលទៅលំឱកលំពោន ជ្រកកោនខ្លួននៅនឹងអ្នកនោះ, ទើបនឹងមានកេរ្តិ៍ឈ្មោះខ្ពស់ថ្លៃ បានសេចក្ដីសុខវែងឆ្ងាយ, បើចោលពាក្យបុរាណចាំង-ឆ្ងាយកាលណា, អាត្មាក៏គង់នឹងវិនាសសោះសូន្យដល់ជីវិត, ឥឡូវព្រះចៅចូយ៉យបរមបពិត្រ មានព្រះតម្រាស់ឲ្យយើងនាំទាហានឯក ១.០០០ ក្នុងទាហាន ២០ មុឺន លើកមកវាយដាន់ពួកអ្នក ។ គប្បីសម្លឹងមើលឲ្យជាក់ចុះ, ចំពោះទ័ពយើង ដូចជាភ្លើងឆេះព្រៃព្រឹក្សា, យើងគន់មើលពលយោធារបស់អ្នក ហាក់បីដូចអំពិលអំពែកតូចហើរក្លួចទៅជាប់នៅចុងស្មៅដើងក្រាស, បើនឹងខំប្រឹងឡាស ចេញមុខមកតស៊ូនឹងយើង ចំទើងទីងបរាជ័យក្ស័យវិនាសអស់ជីវិតលើង, ខ្លួនអ្នកឯងជាមនុស្សមានសតិបញ្ញាស្រៀវស្រួចណាស់ បានដឹងច្បាស់ នូវទម្លាប់ទំនៀមតាមក្រសែបុរាណ,

ម្តេចក៏គ្មានស្គាល់កំហុស ជាទោសមហន្ត ដែលខ្ញុំគតពគាន់ទៅនៅទីង ទៀតពីនោះសោះឡើយ, នេះអ្នកអើយ! អ្នកឯងចូរមកតុកទលន់គួរយើង ដោយស្រួលចុះ; យើងនឹងអនុគ្រោះនាំយកសេចក្តីទៅក្រាបទូលព្រះចៅ ចូយឲ្យគ្រាប្រណីអភ័យទោស; សូមឲ្យទ្រង់ប្រោសតាំងឲ្យអ្នកធ្វើជា នាម៉ឺនធំតទៅទៀត ឃើញថាល្អជាជាងនៅទីងឡើសៀនច្រើនប្រការ; សូម្បីតាំងពលសេនា ក៏នឹងបានសេចក្តីសុខតាមអ្នកផង" ។

ខុនបេងតាំងស្តាប់ចប់សព្វគ្រប់ ក៏អស់សំណើចហើយថា: ឃើ! អ្នកឯងនេះ ជានាម៉ឺនចាស់ទុំ បានធ្វើជាធំក្នុងរាជការព្រះចៅហៀនគេទ្រង់ ប្រោសប្រាណ, គួរតែប្រមាណនាំយក ពះគេជ:ព្រះគុណដែលមានលើ ខ្លួនពោះមកពពេ ឲ្យបានជាបែបច្បាប់ទម្លាប់ទំនៀមទៅខ្លះ, ម្តេចក៏គ្រឡប់ រមិលគុណម្ចាស់សោះសូន្យដូច្នេះ, ចូរអ្នកឯង ទប់បង្ហៀរសេះឲ្យទីងប្រុង ស្តាប់យើងនិយាយតែមួយម៉ាត់ឲ្យដឹងខ្លួនសិន:

"កាលពីគ្រាព្រះចៅលេនគេបានសោយរាជសម្បត្តិនោះ, បំពោះមាន ពួកខ្ទើពញាំញីញុះញង់ ឲ្យស្តេចទ្រង់វង្វេងព្រះទ័យ, បានជារាជការផែន ដីកាន់ប្រែជាចលាចល, កើតពួកអាចោរកំណាចកំហាល់ជួតក្បាលលៀង ពេញស្រុក, គ្រាក្រោយ ដោយតាំងគុជាពជសត្រូវពញាំញី, កន្ទ្រមក លីលុយ គុយតី ប្រែចិត្តក្បត់ប្រព្រឹត្តទុច្ចរិតនឹងផែនដី, ទាល់តែព្រះចៅ ហៀនគេ មានព្រះទ័យក្តៅក្រហាយរាយមាយដោយទុក្ខទោមនស្ស, ចាត់

ការឲ្យខុសពាស់នឹងព្រះរាជកំណត់បទព្រះអយ្យការ ដោយសារតែមនុស្ស
ជោគពាល, ស្តេចមិនបានជ្រាប យកមកតាំងជាមុន ឲ្យទំនុកបម្រុងរាជ-
ការ, ខ្លួនអ្នកឯង យើងក៏យល់ស្គាល់ផរយោ គឺជាអំបូរត្រកូលហីនជាតិ
កើតនៅក្នុងស្រុកតាំងហៃ, អាស្រ័យដោយមានសតិបញ្ញា ទើបមានគេ
ស្នេហាស្រឡាញ់រាប់អាន, ហើយជាអ្នកមានកតញ្ញូនឹងមាតាបិតា, ព្រះ
ចៅហៀនតេ ក៏ទ្រង់ព្រះមេត្តាតាំងឲ្យអ្នកឯងមានតំណែងយសជាធំ, គួរ
តែអ្នកឯងនឹងគួរសម គិតធ្វើការថ្វាយធ្ងន់ព្រះតេជៈគុណព្រះចៅហៀនតេ
ដោយសុចរិត, ជួយយកចិត្តឈឺឆ្អាលដល់ត្រសែព្រះរាជវង្ស ទំនុកទ្រទ្រង់
លើកតម្កើងឲ្យដល់ទៅរាជសម្បត្តិ ទើបពិតជាមនុស្ស, ដែលអ្នកឯងមកត្រ-
ឡប់ជាមិត្រទ្រុស្ត ទៅចុះចិត្តស្និទ្ធស្រឡាញ់អាចោរកំណាច អាចដណ្តើម
យករាជសម្បត្តិរបស់ព្រះមហាក្សត្រិយ៍វិញដូច្នេះ, តោសអ្នកឯង ត្រង់នេះ
មិនទម្ងន់លើសអាចោរកំណាចទេឬ? មនុស្សត្រង់ល្អ គេដឹងឮកេរ្តិ៍ឈ្មោះ
អ្នកឯងអាក្រក់យ៉ាងនេះ, គេក៏ឈឺឆេះពុះក្តៅខ្លួទៅពេញនគរ, ទើបនាំគ្នា
វែកវែរមកប្រឡេះសាច់អ្នកឯងស៊ីទាំងរស់ឲ្យបាន, សូម្បីទេពតា អារក្ស ស្ថិត
នៅលើមេឃអាកាសសព្វឋាន ក៏មានចិត្តពុះក្តៅមួម៉ៅខ្លាំងណាស់, មុខជា
នឹងចុះមកវះពន្ធុះសាច់ផ្តាច់ជីវិតអ្នកឯងឥឡូវនេះពុំខានទេ, យើងក៏បានគិត
ត្នះឃើញថា បុណ្យបារមីនៃពូជព្រះរាជវង្សព្រះចៅហៀនតេនោះ នៅ
មានច្រើនអនេកណាស់, ព្រះចៅឡៅពីជាម្ចាស់ ក៏ទើបបានជាន់ពិភព

គ្រប់គ្រងប្រជាជននៅមណ្ឌលស្រុកសៃឈូង តព្រះរាជវង្សមក, ខ្ញុំយើង ក៏បានកាន់យកនូវព្រះតម្រាស់ នៃព្រះចៅឡៅសៀន ឲ្យលើកសេហ៍ពល សកលយោធាមកប្រហារបំផ្លាញអាចោរសត្រូវរាជសម្បត្តិ ឲ្យខ្ចាត់វិនាស ឥឡូវនេះ អ្នកឯង គង់នឹងធ្លាក់របេះក្បាលពីលើស្មា , បើខ្លាចស្លាយ អាយុសង្ខារ គួរតែមុជជ្រកសិកលាក់ខ្លួនពួនឲ្យបាត់ទៅ, កុំបីមកនៅ បង្ហាញមុខជាឧកជាទុក្ខប្រោះពួកពីរាជការផែនដីនោះឡើយ, ឲ្យថយទៅគិត ឲ្យហើយថា ខ្ញុំនៅតាស់ជក អស់ការគេនឹងប្រស្រ័យប្រើប្រាស់, បីដូច គោកញ្ចាស់ឈរនៅមាត់ទ្វារក្រោល, បើនឹងដួលស្លាប់ទៅមើលមុខពួកព្រះ រាជវង្សព្រះចៅហៀនគេដូចគេម្ដេចបាន, នែ! អាចោរកញ្ចាស់សាមាន្យ អាឯងចូរវិលត្រឡប់ទៅប្រាប់ចៅហ្វាយអាឯង ជាមេចោរក្បត់រាជសម្បត្តិ ឲ្យតាត់លើកកងទ័ពមកច្បាំងគ្នាឲ្យឆាប់ នឹងបានឃើញថ្វីដៃចំណាប់ទៅ ខាងណាជាឈ្នះឬចាញ់" ។

អងឡុងឮហើយ ក៏ឲ្យក្ដៅខ្ញាញ់ពេញកម្លាំងណាស់, ដោយអាការ ជាមនុស្សចាស់ទន់ពលាការ ក៏ស្រែកដោយសម្លេងខ្លាំងអស្ចារ្យលើសប្រ- មាណ ទាល់តែភ្ញាក់ខ្លួនព្រាណធ្លាក់ពីលើខ្នងសេះ របេះបោកទៅលើព្រះ ធរណី ដូចគេបត់កបាក់ជា ២ ក្ស័យជីវិតក្នុងខណៈនោះ ។ ខុងបេងឃើញ ដូច្នោះ ក៏លើកសេចក្ដីលមុខចូជិនហើយស្រែកថា នែ ! ចូជិន អ្នកឯង ត្រូវតាត់តែងសេនាទាហានសេសសុទ្ធតែដៃឯក, ព្រឹកស្អែក យើងនឹងលើក

ចេញមកច្បាំងគ្នា, ថាហើយខុនបេងក៏លើកពលយោធាចូលបន្ទាយ ។

ឯចូជិន ក៏ចាត់ចែងតែងសំស្ការសពអង់ឡេង តាមទំនងយសជាមន្ត្រីធំ, ហើយឲ្យហែនាំចូលទៅស្រុកក្រុង ។ គុយហួយនិយាយនឹងចូជិនថា: ខុនបេងឃើញថាយើងកំពុងជ្រួលច្របល់រវល់នឹងសពអង់ឡេងដូច្នេះ, មុខជាយប់នេះ ខុនបេងនឹងឲ្យលើកមកលុកបន្ទាយយើង ពុំខាន, សុំឲ្យលោកចាត់ទាហាន ឲ្យទៅបង្កប់សព្វច្រកផ្លូវ នៅខាងក្រោយភ្នំគីសាន, បើឃើញទាហានខុនបេងលើកមកហើយ ត្រូវចេញដណ្ដើមយកបន្ទាយវាឲ្យបាន, ឯយើងខាងណេះ ត្រូវនាំទាហានចេញទៅពួនបង្កប់នៅក្រៅបន្ទាយ មុខជាយើងនឹងទម្លាយទ័ពខុនបេងឲ្យបរាជ័យបាន ។

ចូជិន បានស្ដាប់ ក៏យល់ឃើញត្រូវ ទើបថា: «គំនិតដែលអ្នកគិតដូច្នេះ ត្រូវដូចគំនិតយើងគិតទុកគ្រប់ប្រការ», ហើយក៏ចាត់ចូជុននិងចូបានឲ្យលើកពលយោធាទៅបោះនៅក្រោយភ្នំគីសាន, បំបែកទាហានពួនបង្កប់តាមបង្គាប់គុយហួយសព្វគ្រប់, លុះដល់ពេលយប់ ចូជិន ក៏ឲ្យទាហាននៅរក្សាបន្ទាយប្រហែល ១០ នាក់ រួចឲ្យជញ្ជូនសំកមនិងអុសទៅដាក់គររាយពេញភាគបន្ទាយ រួចក៏និយាយប្រាប់ថា បើខុនបេងលើកមកដល់ឲ្យដុតភ្លើងនេះឡើងជាសញ្ញា ។ ឯចូជិននិងគុយហួយ ក៏នាំគ្នាលើកទាហានចេញទៅពួនបង្កប់ក្រៅបន្ទាយ ។

ខណៈកាលខុនបេង វិលចូលទៅក្នុងបន្ទាយនោះ, លុះដល់ពេលយប់

កំឲ្យហៅជួឡុងទៅប្រាប់ជាមួយនឹងអ៊ុយអៀនថា: ពេលយប់នេះ ត្រូវឲ្យអ្នកទាំង ២ លើកទាហានទៅលុកបន្ទាយប៊ូជិនឲ្យបាន ។ អ៊ុយអៀនជម្រាបខុងបេងថា: ឯប៊ូជិនជាមនុស្សមានសតិបញ្ញា ធ្លាប់ធ្វើការណរង្គសង្គ្រាម, ដែលយើងនឹងធ្វើតាមគំនិតគិតមើលឆាយថា ប៊ូជិនកំពុងរវល់នឹងសំស្ការសពអងឡុង ហើយប៉ងលើកទាហានទៅលុកបន្ទាយឲ្យបាននោះ, ខ្ញុំបាទយល់ឃើញថាមុខជាមិនស្រួលទេ, ព្រោះប៊ូជិនគេបម្រុងប្រយ័ត្នការអស់ហើយ ។ ខុងបេងអស់សំណើច ហើយថា: យើងចូលចិត្តឲ្យប៊ូជិនដឹងខ្លួនរៀបពួនបង្កប់ទ័ពឲ្យស្រេចទៅចុះ, បើមែនដូច្នោះ ទើបយើងធ្វើការបានស្រួលទាំងអស់, យើង កំបានពិគ្រោះស្គាល់គំនិតប៊ូជិនអស់ហើយ មុខជាលើកទាហានទៅពួនបង្កប់ក្រោយក្គីសាន ចាំដណ្តើមយកបន្ទាយយើងជាប្រាកដ, បានជាយើងដាក់កំណត់ឲ្យអ្នកទាំង ២ លើកទ័ពទៅឲ្យគ្រាន់តែប៊ូជិនឃើញប៉ុណ្ណោះ, បើឃើញបន្ទាយច្បាស់ ត្រូវឲ្យបោះទ័ពបង្កប់នៅពីឆ្ងាយ, កាលណា បើឃើញយើងដុតភ្លើងជាសម្គាល់ហើយ, អ្នកឯងត្រូវលើកទាហានចេញទៅស្ទាក់ផ្លូវឲ្យជាប់, បើឃើញទ័ពប៊ូជិនបែករត់ពីយើងទៅ, ត្រូវឲ្យបើកផ្លូវហើយដេញតាមកាប់សម្លាប់ពួកវាគ្រាតែដល់បន្ទាយ, ប៊ូជិន កំគង់នឹងបែកបាក់ព្រាត់ព្រាយនឹងពួកយើងប្រាកដ ។

ខុងបេង ឲ្យគួនហ៊ិននិងតៀវប៉ៅនាំទាហានទៅតាំងបង្កប់នៅក្រោយ

ភ្នំគីសានហើយបង្គាប់ថា: បើឃើញចូជិនបែកទ័ពត្រឡប់តទៅ ត្រូវឲ្យដេញតាមត្រាតែដល់បន្ទាយ; គួនហ៊ុន, តៀវប៉ៅ ក៏លើកទាហានទៅធ្វើតាមខុងបេងបង្គាប់គ្រប់ប្រការ, ខុងបេងទើបចាត់ប្រើម៉ាតាយ, តៀវអេក, តៀវងី ទិងអងបេង ៤ នាយឲ្យនាំទាហានទៅពួនបង្កប់នៅក្រៅបន្ទាយ, ហើយបង្គាប់ថា: « បើឃើញភ្លើងឆេះឡើងជាសញ្ញា ត្រូវឲ្យបោមព័ទ្ធប្រជិតចូលមក», ហើយខុងបេងប្រើទាហានឲ្យជញ្ជូនអុសនិងសំរាមទៅគរទុកក្នុងបន្ទាយជាច្រើន, រួចនាំទាហានពួនពីក្រោយបន្ទាយ ។

ឯចូជុនទិងចូពាន ដែលលើកទាហានទៅពួនបង្កប់នៅក្រោយភ្នំគី-សាននោះ, លុះពេលយាម ២ យប់, ក៏ចាត់ទាហានឲ្យចេញទៅល្បាតមើលតាមផ្លូវមុខភ្នំ, ឃើញកងទ័ពធំដែលខុងបេងប្រើទៅ, ក៏នឹកសរសើរថា « គុយហ្វួយ មានសតិបញ្ញាស្រៀវស្រួចមែនណាស់, ដឹងច្បាស់ប្រ-មាណការមិនល្អៀងខុសទៅបាន, គ្មាននរណា ទីងប្រៀបផ្ទឹមឲ្យដល់», បម្រើ ក៏វិលទៅពន្យល់ចូជុនឲ្យដឹងការ, នោះចូជុន ចូពាន ក៏ស្រួតលើកទាហានទៅដល់បន្ទាយខុងបេង តាំងឲ្យពារទម្លាយបន្ទាយចូលទៅឃើញស្ងាត់សូន្យទាំងអស់ គ្មានមនុស្សនៅពិភ័ក្តិរក្សា, ក៏នាំគ្នាតក់ស្លុតរន្ធត់ចិត្តគិតថា មុខជាខុងបេងធ្វើកល, តាំងតែជ្រួលច្របល់ត្រឡប់ទ័ពថយចេញ, ភ្លើងក៏ឆេះពេញអណ្តាតស្កាត់ជុំវិញបន្ទាយ, ទ័ពចូជិន ក៏បាក់ភ្លាយប្រពាក់ប្រពូនជាន់លើគ្នា ។ នាយទាហាន ៤ នាក់ដែលពួន

បង្កប់ ក៏មីម្នាក់ឈ្មោះ តោះតង់ ទូងកើរ ស្រែកហៅ ចេញមកប្រឡូកកាប់ចាក់, ចូជុននិងចូបាន ក៏បែកបាក់កងទ័ពជាប់តែទាហានសេះ ១០០ ដោយនឹងខ្លួន រត់ប្រពួនចេញទៅតាមផ្លូវធំ ។ ជូឡុងស្ទុះចេញពីមុខភ្នំមកស្ទាក់ទទឹងផ្លូវហើយស្រែកថា : អាចោរ ! អាឯងទៅណា? ចូជុននិងចូបានភ័យខ្លាំងណាស់ ក៏បំផាយសេះប៉ះទម្លាយបន្ទាយចេញទៅ, អ៊ុយ-អៀននិងជូឡុង ក៏លើកទាហានដេញសម្លាប់ទៅពីក្រោយ ។

ឯទាហានចូជិនដែលនៅក្នុងបន្ទាយ ឃើញចូជុននិងចូបាននាំទា-ហានបំផាយសេះរត់តម្រង់ចូលមក ក៏ស្មានថា "ជាទាហានខុងបេងលើកមកលុកបន្ទាយ" ទើបនាំគ្នាប្រញាយដុតភ្លើងឡើងជាសម្គាល់, ចូជិននិងគុយហួយ ក៏នៅពិកាល់មិនទាន់ច្បាស់ ក្រឡាស់បរពៈណក់យប្រសព្វចូលមកទៀត, ទទួលគួនហ៊ុននិងតៀវប៉ៅដែកដៀត លើកទ័ពមកដល់ស្គាល់ជាក់ជាទ័ពចូជិនរង្វេងប្រឡល់ចាក់កាប់គ្នា, គួនហ៊ុននិងតៀវប៉ៅ ក៏លើកបំពារចូលទៅព្រួតនឹងទ័ពអ៊ុយអៀន, បានជា ៣ មុំ ក្ដុំគ្នាព្រួតចាក់កាប់សម្លាប់ទាហានចូជិនស្លាប់ច្រើនណាស់, ខ្លះស្ទុះរស់រួចជីវិត ក៏រត់ព្រាត់ព្រាយ ធ្លាយពីក្នុងបំណោមចេញទៅ ។ នាយទាហានខាងខុងបេងតាំងប៉ុន្មាន, លុះបានជ័យជម្នះហើយ ក៏នាំកងទ័ពត្រឡប់ទៅរកខុងបេងក្នុងបន្ទាយ ។

លុះព្រឹកព្រាងស្វាងអរុណោទ័យ, ចូជិននិងគុយហួយ ក៏ប្រមូល

ទាហានដែលសល់អំពីស្លាប់ លើកប្រញាប់ចូលទៅនៅក្នុងបន្ទាយវិញ, ហើយប្រឹក្សាគ្នាថា: យើងធ្វើសឹកសង្គ្រាមតនឹងខុងបេងម្ដងនេះ ក៏អស់កម្រិះដែលខ្លួនចេះដឹងប៉ុណ្ណឹងដែរ, តែថា ទៅគង់ចាញ់ប្រៀបរបស់គេផ្ទួរកលលើយើងទៀត, យើងនឹងគិតធ្វៀតត្រូវឧបាយយ៉ាងណា ឲ្យខុង-បេងខ្លាចរអាត្រឡប់ទ័ពទៅវិញបាន, គុយហួយ ឆ្លើយថា: ធម្មតាការសង្គ្រាមនេះ នឹងសម្គាល់តាមចេះគិតឲ្យបានតែឈ្នះមួយយ៉ាង មិនបានទេ, ពោះនឹងអាងថ្វីដៃខ្លាំងពូកែយ៉ាងណា ក៏គង់មានចុះការបរាជ័យមិនលែង, លោកកុំអាលបំបែងតូចចិត្ត, ខ្ញុំបាទនឹងគិតធ្វើឲ្យខុងបេងថយទ័ពទៅវិញ ។

(នៅមានត)

# រឿង

# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

## របស់លោក រ៉ាប៊ីន្ទ្រណាត តាហ្គរ

ប្រែសម្រួលដោយអ្នកស្រី ទេព-សល់

(តមកពីឆ្នាំ ១៩៦៩)

## វគ្គទី ៤០

លុះមិត្តអ្នកចេញផុតទៅ ជោជេន្ទ្រាក៏ឡើងទៅជួបនឹងលោកតាជាឪពុកអ្នក ដែលកំពុងតែប្រាស្រ័យជាមួយនឹងអ្នកស្រីក្នុងបន្ទប់ទទួលភ្ញៀវ ។

ឃើញជោជេន្ទ្រាដើរចូលទៅ លោកដូចជាអៀន ហើយខំនិយាយយ៉ាងរាក់ទាក់មកកាន់កូនប្រុសលោក ព្រមទាំងចង្អុលកៅអីឲ្យកូនអង្គុយក្បែរគាត់ផង ។

ជោជេន្ទ្រាចាប់និយាយ :

—ពុក! ពុកមិនដែលចេញទៅណានឹងគេ ហ្ន៎ ហិមណាលិនីក៏យ៉ាងហ្នឹងដែរ តើពុកនៅសម្ងំបានការអ្វី ?

—ទេ! ជោជេន្ទ្រា យើងធ្លាប់តែនៅផ្ទះដូច្នេះតាំងតែពីណាមកហើយ ហើយបើចង់ឲ្យប្អូនឯងចេញ ទាល់តែមានការអ្វីល្មមគេចេញ ទើបគេទៅ ។

-ពុកកុំទំលាក់កំហុសឲ្យខ្ញុំ (នាងហិមណាលិនប្រកែក) ពុកជ្រាបស្រាប់ហើយ តែពុកចង់ទៅណា ខ្ញុំតាមពុកទាំងអស់ ។

-នៃ! ល្ងាចស្អែកនេះ គេធ្វើសន្និសិទមួយ ពុកនឹងហិមណាលិនី គួរតែទៅស្ដាប់នឹងគេ (ជាជេត្រូនានិយាយ):

លោកតា អាណាជា បាប៊ូ ដឹងចិត្តកូនថា នាងមិនចូលចិត្តចូលរួមក្នុងទីប្រជុំជនជាសាធារណណាមួយសោះទេ ម្ល៉ោះហើយបានជាគ្រាន់តែឮជាជេត្រូនានិយាយដល់នេះភ្លាម លោកតាងើបមើលមុខកូនស្រីលោកភ្លាម មុននឹងធ្វើអ្វីទាំងអស់ ប៉ុន្តែនាងហិមណាលិនី ធ្វើជាស្រែកសួរយ៉ាងបន្ទាន់ ដូចជាពេញចិត្តនឹងដំណឹងនោះណាស់ ។

-សន្និសិទ-របស់លោកណាបង ?

លោកណាលិនណាក់ស្កា លោកជាអ្នកមានវោហារសម្បើមណាស់ មួយរយមួយពាន់នាក់ មិនទាន់គេមនុស្សណា មានសន្តានចិត្តនឹងនឹង ហើយអំណត់ដូចលោកនេះបានឡើយ ?

-ពុក យើងត្រូវទៅស្ដាប់ អ្នកវោហារឯកនោះកុំខានណា៎ ។

-ទៅក៏ទៅ បើតបឹងជាជេត្រូនាឯងត្រូវតែនាំពុកទៅស្ដាប់ផង ហើយប្រយ័ត្នកុំឲ្យទៅយឺតពេលឲ្យសោះណា៎ ។ ម្យ៉ាងទៀត ឯងស្គាល់លោកណាលីណាក់ស្កានោះទេ ?

ចូរឯងនិយាយប្រាប់ពុកបន្តិចមើល ព្រោះពុកឮគេនិយាយពីលោកនេះ ថាគីបេះដុះច្រើនបែបណាស់ មិនដឹងជាណាពិត ណាស្មែនទេ?

គ្រាន់តែឮឪពុកថាប៉ុណ្ណេះ ជោជេន្ត្រា បញ្ចេញយោបល់មិនពេញចិត្តនឹងមនុស្សខ្លះដែលចូលចិត្តនិយាយឈ្លានិសបំផ្លាញគេមួយរំពេច ថាមានមនុស្សខ្លះរក្សាតាំងសីលទៅហើយផង ក៏នៅតែចូលចិត្តពោលពាក្យមុសារាំងអ្នកផងស្ទើរតែគ្រប់គ្នា ។

—ពិតមែនហើយ មនុស្សខ្លះ ច្រើនមើលឃើញតែទោសគេ យូរៗទៅ គេញាតិមិត្តនឹងគេគ្មាន ទៅជានៅជិតខាងគេមិនចុះរស់នៅតែម្នាក់ឯង ។

—នែ ពុកចង់ដាក់ថ្លៃឲ្យខ្ញុំឬពុក ? ជោជេន្ត្រាសួរបែបចំអន់ តម្លើងក្អកដូចដោះតនមួយរំពេច ខ្ញុំមិនមែនធុនមនុស្ស ដូចពុកមានប្រសាសនោះទេណា៎ តែមានការអ៊ី ខ្ញុំច្រើនតែនិយាយនៅចំពោះមុខគេតែម្តងហើយ បើសិនជាគេមិនព្រមស្តាប់ខ្ញុំទេ ខ្ញុំលេងដៃដល់ក្លាមណា៎ពុក គ្មានដែលបណ្តាក់ទេ សូមពុកជ្រាប ។

ឃើញកូនខឹងខ្លាំង លោកតាបន្ទន់សម្តីមួយរំពេច ។

—កុំបានតែឆ្ពួតនោះ តាមពិតពុកគ្មានបានទិតៀនអ៊ីដល់ឯងបន្តិចណាសោះទេ ឯងកុំស្មានថា មកដល់ថ្ងៃនេះហើយ ពុកមិនស្គាល់ចិត្តឯងនោះ?

ជោជេន្ត្រាឈប់ប្រឡោត ក៏បន្តសេចក្តីសរសើរលើរូបណាលី-

ណាក់ស្ហានោះទៅទៀត ហើយបញ្ជាក់ថា :

—លោកណាលីណាក់ស្ហាស្រឡាញ់ហើយគាណិតម្ដាយលោកដែលឪពុកលោកបានលះបង់ពេលនោះណាស់ ទើបស៊ូលះបង់អ្វីទាំងអស់ដើម មកតាមម្ដាយ តែមិនដឹងជាមិត្តរបស់ពុកបេះឧប្បត្តិករឿងអ្វី ខុះបង្ខូចគាត់ទេ ។ ចំពោះខ្ញុំ ខ្ញុំកោតសរសើរចិត្តលោកនេះក្រៃលែង ចុះហិមណាលិនី អ្នកឯងមានយោបល់យ៉ាងម្ដេចទៅ ?

—ខ្ញុំក៏មានយោបល់ដូចបងដែរ ។

—បងយល់ថា ចិត្តអ្នកឯងក៏មិនខុសពីវេជ្ជបណ្ឌិតនោះដែរ ហើយបើប្រសិនជាមានការបែបនេះកើតឡើង ប្អូនមុខជានឹងសុខចិត្តធ្វើពលិកម្មដើម្បីសុភមង្គលឪពុកយើងមិនខានឡើយ ។

## វគ្គទី ៤១

លោកតាគាណាដាបាប៊ូនិងនាងហិមណាលិនី ត្រឡប់មកពីស្ដាប់សន្និសិទវិញ នៅវេលារសៀលហើយលាន់មាត់ថា :

—សន្និសីទនេះពីរោះពិសាមែន ?

នៅពេលធ្វើសន្និសិទនោះ លោកណាលីណាក់ស្ហា ដូចជាមានភាពក្មេងគួរឱ្យអស្ចារ្យណាស់ លោកមានចំណាស់បន្តិចទៅហើយ តែទឹក

មុខលោកនៅស្រស់បព្រឹម ហើយនៅពេលដែលលោកហាមាត់និយាយ មក ហាក់ដូចជាផ្កាយចេញនូវការពេលអ្វីមួយចេញពីដួងចិត្តលោកមកផង សន្និសិទនោះ មានចំណងជើងថា "អត្តប្រយោជន៍និងការបង់ទានរបស់យើង" ហើយគោលបំណងធំរបស់លោកគឺលោកបង់ បង្ហាញថា អ្នកណាមិនហ៊ានបង់ នឹងមិនបានទទួលផលល្អអ្វីទាំងអស់ ថាអ្វីដែលយើងបានដោយមិនបាច់ខំ មិនមានឈ្មោះថាបានប្រាកដទេ ម្យ៉ាងទៀត លោកបានពន្យល់ថា ទ្រព្យដែលយើងបានបរិច្ចាគទាំងអម្បាលម៉ាននេះហើយ ដែលនឹងវិលមកជាទ្រព្យកម្មសិទ្ធរបស់យើងវិញក្នុងអនាគតកាល ។ អ្នកខ្លះយល់ថាខ្លួនជាមនុស្សអកុសលណាស់ បើប្រសិនជាលះបង់ទ្រព្យសម្បត្តិក្នុងលោកនេះអស់ទៅ ? ប៉ុន្តែការពិតគឺទ្រព្យដែលលះបង់នេះហើយ ដែលទៅជាសំពាយទ្រព្យអនាគតរបស់យើង ។ ម្យ៉ាងទៀត បើសិនជាយើងបាត់បង់អ្វីមួយ ដែលជាទីស្រឡាញ់របស់យើង ហើយយើងបេះបន្ទូនចិត្តលះបោលជាទានតែម្តងទៅ ព្រមទាំងសេចក្តីសោកស្តាយ ទោះជាទ្រព្យដែលការលះនោះតិចតួចស្តួចស្តើងប៉ុនានក៏ដោយ ក៏អាចក្លាយទៅជាបិតបេរបាន វត្ថុដែលយើងប្រើប្រាស់ជាធម្មតា ក៏អាចក្លាយទៅ ជាវត្ថុឧត្តុង្គឧត្តមដែលពូនជ្រកនៅក្នុងបេះដូងយើង លុះគ្រាអវសាននៃជីវិត ។

សេចក្ដីអធិប្បាយវែកញែករបស់លោកណាលិណាក់ស្កា បានធ្វើឲ្យនាងហិមណាលិនី រំភើបអារម្មណ៍យ៉ាងក្រៃលែង ។

នៅលើលានជំបូលផ្ទះ ដែលនាងតែងពេញចិត្តឡើងទៅសម្បែណ្ដែតអារម្មណ៍តាមអាកាសល្ហល្ហុង តាមចន្លោះផ្កាយមេឃទឹងដី ក៏ក្លាយទៅជាមានន័យសប្បាយខុសពីកាលសព្វដងរៀងមក ។

បេញពីស្ដាប់សន្និសិទមក ជាជន្ទ្រានិយាយទៅកាន់អាក់ស្ហាយៈ

-យើងមិនស្មានថាឯងបេះបង្អុលមនុស្សត្រូវចិត្តយើង ដូចនេះសោះ ប៉ុន្តែដូចជាចូលក្នុងជំនឿពេក តាមយោបល់ខ្ញុំ ខ្ញុំយល់ថាលោកនិយាយតែការឥតប្រយោជន៍ ចង់អស់ពាក់កណ្ដាលសន្និសីទទៅហើយ ?

- ឯងត្រូវដឹងថា គេត្រូវកកខ្វៃងឈើឲ្យឃើញសិន សិមដាក់ថ្នាំទើបត្រូវ ។ ហិមណាលិនីឈឺអំពីការគាន់ប្រឡូលើរូបកមេស្ហ៍ ពាល់តែយកធម៌មកនិយាយ យកកម្មផលពីអតីតជាតិមកនិយាយ ទើបនាងស្ដាប់បាន បើប្រសិនជាមនុស្សគ្មានវិបត្តិដូចឯងនិងអញ ស្ដាប់ម្ដេចចូលត្រចៀកកើត? នៅពេលលោកនោះកំពុងតែបំពងសម្លេង តម្លើងសរសៃកឯងមានបានគន់មើលមុខនាងឬទេ ?

—មាន ភាពបែបពេញចិត្តទឹងភក្តិ្មទសម្លៀម ប៉ុន្តែ ទោះជានាងពេញចិត្តនឹងសន្និសីទ ក៏មិនមែនបានន័យថានាងសុខចិត្តរៀបការជាមួយ

ទឹងអ្នកធ្វើសន្ធិសីទនោះដែរ ។

-ខ ! បើសិនជាឯង ឬ អញឡើងនិយាយវិញ ប្រហែលជានាងមិនតាំងយកត្រចៀកស្តាប់ផង ឯងដឹងទេ តាប៉ុននឹងគាត់ចេះនិយាយត្រូវចិត្តស្រី ៗ ណាស់ ឯងយកមនុស្សដទៃក្រៅទៅដាក់ ច្បាស់ជានាងយកទៅប្រៀបផ្ទឹម នឹងកាមេស្ហគេឥឡូវ ឯងមុខជាទទួលសូន្យ ជាលទ្ធផលមិនខាន ប៉ុន្តែ ណាលីណាក់ស្ហា មិនមែនមានអ្នកណាផ្ទឹមបានទេ កម្រណាស់ ៗ ឯងមិនជឿ រកអ្នកណាដទៃ មកបង្ហាញនាងលមើល នាងដឹងខ្លួនមួយរំពេច ហើយប្រដាំងភ្លាមឥឡូវ ប៉ុន្តែ បើរកមធ្យោបាយទៅដឹកណាលីណាក់ស្ហាមកជួបនឹងនាង ឯងមុខជាចេញភ្លើងឥឡូវហ្នឹង ។

-ឯងកុំភ័យ ពីសេចក្តីគោតសរសើរទៅស្រឡាញ់ មានតែមួយជំហានទេ កុំបន្ទំ ។

-ទេ ! ខ្ញុំមិនចេះទំពាការឲ្យល្អិតល្អន់ដូចឯងទេ តែមានការអ៊ី ចង់តែនិយាយភ្លាម ៗ បើនិយាយឲ្យត្រង់ទៅ គឺរឿងកំប៉ុកកំប៉ុកបែបនឹងគ្នាឥតចូលចិត្តសោះទេវើយ

-នៃ! ឯងកុំអាលថាមុន ឯងត្រូវយល់ថា រឿងរ៉ាវអ្វីក៏ដោយ មិនមែនវាចេះតែដើរស្របតាមគំនិតយើងទេ ។

ឯងត្រូវចាំឲ្យច្បាស់ថា ឯងមិនអាចប្រើកម្លាំងបាយដើម្បីនឹងធ្វើឲ្យនាងហាមណាលិទី ភ្លេចកាមេស្ហបានទេ បើឯងចង់ឲ្យគោលបំណងឯងបាន

សម្រេច ឯងត្រូវធ្វើតាមពាក្យខ្ញុំគ្រប់ម៉ាត់ ទើបបានលទ្ធផលល្អ ។

តាមការពិត អញយល់ថាណាលីណាក់ស្ហានេះ ជាមនុស្សមានអាថ៌កំបាំងច្រើនពេក អញដូចជាមិនសូវពេញចិត្តសោះ ព្រោះថាមនុស្សបែបនោះ អ្នកណាហ៊ានគិតការអ្វីជាមួយនឹងវាកើត? ទុកចិត្តវាម្តេចបាន? បើវាក្រញិញក្រញ៉ុំ ខ្លួនជាពោះ ពោះជាខ្លួន ទៅគិតការជាមួយនឹងវា ក្រែងវាប្រានយើងចូលក្អើងតែម្តងទៅ អ្នកណាដឹងអី?

– ណ្ហើយ អាកញ្ញាស់អើយ (អាក់ស្ហាយនិយាយ) បើឯងចូលក្អើងក៏មិនមែនជាកំហុសរបស់ឯងដែរ ឯងឥឡូវដូចជាចង់ជ្រុលបន្តិចហើយ ស្អីក៏ខ្លាច បែបចង់ខ្លាចទាំងស្រមោលខ្លួនឯងផងណា ? កាលពីមេស្ហនៅឡើយ ពួកឯងពល់គ្នាលើសពីខ្លាក់ទៅទៀត ព្រោះអ្វី ? ព្រោះឯងមើលឃើញ តែល្អឃើញតែស្មោះ ឃើញតែត្រង់ ហើយនាំគ្នាទុកវាដូចជាព្រះសង្ឃមួយអង្គប្រកបដោយគុណសម្បត្តិគ្រប់យ៉ាង ។

មានតែអញមួយទេ ដែលចេះតែមានសង្ស័យលើរូបវា ព្រោះអាមនុស្សដែលចេះតែមានគំនិតខ្ពស់ជាងពេក បែបវាហ្នឹងអញធ្លាប់ប្រទះមកច្រើនណាស់ហើយ ប៉ុន្តែ អញមានទៅហ៊ានហើបមាត់និយាយអ្វីអំពីវា ទោះជាអញគិតឃើញយ៉ាងណា ខ្ញុំក៏ត្រូវតែបិទប្រអប់មាត់សិនដែរ ហើយបើសិនជាអញនិយាយវិញ ឯងមុខជាចោទថា ខ្ញុំប្រណែននឹងវាហើយ បានជារិះគន់វា ព្រោះឯងទុកវាជាអាទិទេពមួយអង្គទៅហើយ អ្នកណា

ហ៊ានប៉ះ ? តាល់តែដល់ថ្ងៃនេះ ទើបឯងនឹកស្តាយក្រោយ តែបើទោះជា ឯងយល់ឃើញថាវាល្អ ឯងក៏មិនគួរនឹងយកជីវិតប្អូនឯងទៅប្រគល់ឱ្យវា ហើយដេកសង្ឃឹមថា មុខជាបានសប្បាយនោះដែរ ។ ឆាកជីវិត តែខកម្តងគឺខកមួយជីវិត ឥឡូវនេះ ការវាហួសអស់ទៅហើយ ឯងធ្វើតាមអញម្តងទៅ កុំជជែកអី ឯងត្រូវចាំពាក្យចាស់មួយលោកពោលថា "តែវាយដែកគោលថ្មីចូល ដែកគោលចាស់ត្រូវតែខ្ទាតចេញ" ។

—នែ! ស្តាប់អញសិន (ចៅជេទ្រាឆ្លើយ) អញគ្មានត្រូវការជឿឯងគ្រប់មាត់ទេ ឯងចេះតែនិយាយដដែលៗ ប្រហែលជាមួយពាន់ដងហើយ ថាឯងជាអ្នកយល់មុនគេនូវគំនិតអាក្រក់របស់ពេស្ហ ការពិតគឺឯងចេះតែស្អប់វា ដែលគ្មានធ្វើអ្វីឱ្យឯងស្អប់សោះ ឥឡូវនេះឯងត្រូវកុំសង្ឃឹមថា អញចូលរួមគំនិតនឹងឯងទៀត ព្រោះថា បើឱ្យអញនិយាយថាអញពេញចិត្តនឹងណាលីណាក់ស្ហានេះ គឺអញមិននិយាយទេ ព្រោះអញគ្មានពេញចិត្តនឹងតាប៊ុនេះតាល់តែសោះ ។

នៅពេលដែលចៅជេទ្រានឹងអាក់ស្ហាយ ជជែកគ្នាបណ្តើរ ដើរបណ្តើរចូលដល់សាឡុង នាងហិមណាលីទក្រឡេកឃើញគេចចេញតាមទ្វារក្រោយបាត់មួយរំពេច ។ អាក់ស្ហាយ ឃើញអាកប្បកិរិយានាងហិមណាលិទីវាត់ញញឹមមួយភ្លែត ព្រោះគេយល់ចិត្តនាងអស់ហើយ រូប

និយាយទៅកាន់លោកតាអាណាថា បាប៊ូ :

—លោកអ៊ុំ សម្តីរបស់ណាលីណាក់ស្កា ដូចជាត្រូវចិត្តខ្ញុំណាស់ មកអំពីសម្តីទាំងនោះចេញអំពីដួងចិត្តរបស់គេមែន ។

—លោកឆ្លាតណាស់ មែនទេ? "លោកតាឆ្លើយ" ។

—លើសពីឆ្លាតបន្តិចទៅទៀត គឺជាអាទិទេព ទាំងមូលតែម្តង ។

—នែ កុំយកអាទិទេព មកនិយាយលេង (ដោះដោគ្រា ទប់មិនបាន ឆ្លើយ) ។

—ណាលីណាក់ស្កា មិនមែនចេះតែនិយាយទេ គឺគេមានការពិសោធន៍ជ្រៅជ្រះរបស់គេមែន (លោកតា ឆ្លើយ) ពុកយល់ថា ការដែលគេនិយាយនោះ គឺជាការផ្សុសគំនិតមួយល្អណាស់ បើមនុស្សមានពុកត្បុក មិនមែនអាចនិយាយបានល្អយ៉ាងនេះទេ ?

ប៉ុន្តែ ខ្ញុំខ្លាចក្រែងតែសុខភាពរបស់គាត់ធន់ទឹងការដែលគាត់ធ្វើ ដោយអត់បាយអត់ទឹកនោះមិនបានទេ ?

—ម្តេចអ៊ីចឹង គាត់មិនមានសុខភាព បរិបូណ៌ទេ ?

—បរិបូណ៌ម្តេចកើត បើមួយថ្ងៃ ៗ រវល់តែពីរៀន ទឹងសូត្រធម៌ បានពេលឯណារករបស់ឆ្ងាញ់ចំអែតកាយ ។

—ការធ្វេសខ្លួនបែបខឹងខុសស្រឡះ (លោកតានិយាយ)? យើងមិនត្រូវធ្វេសប្រហែសខ្លួនបែបនេះទេណា ព្រោះយើងមិនអាចធ្វើរូបកាង

កាយខ្លួនយើងកើតឯណា យើងត្រូវថែទាំខ្លួនយើងឲ្យមានសុខភាពល្អ ហើយត្រូវតែ . . . ។

ជោរជន្ត្រា ធុញនឹងសេចក្ដីអធិប្បាយរបស់ឪពុកអ្នកវែងពេក ឥតប្រយោជន៍ ឆ្លើយគាត់វិញ ។

– ពុកកុំទៅមានប្រសាសន៍បែបនឹងនោះ វាគ្មានទៅត្រូវស៊ីបន្តិចសោះទេ តាមដែលខ្ញុំបានឃើញពីល្ងាចមិញ ណាលិណាក់ស្ហាមានមាឌល្អសម្បើម ហើយខ្ញុំចេះតែស្ញើចថា រស់នៅរបៀបគាត់មានសាច់ដុំដូចជាអ្នកកីឡាដែរ គួរតែខ្ញុំខំធ្វើដូចគាត់លមើល !

–ឯងកុំថាអីចឹង ការដែលអាក់ស្ហាយនិយាយនោះ មានត្រូវខ្លះដែរ ព្រោះមានអ្នកប្រាជ្ញច្រើនណាស់ ដែលត្រូវស្លាប់ កំពុងតែពេញវ័យ នឹងកំពុងតែលូតលាស់ ហើយបើបណ្ដោយខ្លួនឲ្យជម្ងឺជាប់បាននៅពេលកំពុងតែពេញចរើនយ៉ាងនេះ ដូចជាធ្វើឲ្យខូចប្រយោជន៍ស្រុកទេសមួយយ៉ាងដែរ ? ប៉ុន្តែ ចំពោះរូបលោកណាលីណាក់ស្ហា ការយល់របស់ឯង ដូចជាមិនត្រូវទេ ព្រោះថា ប្រហែលជាមានអ្នកណាជួយរំលឹកដាស់តឿនពីរឿងនេះហើយ បានជាលោកមិនដូចអ្នកឯទៀត ។

–នែ ! លោកអ៊ុំ មិនអីទេ ចាំខ្ញុំទៅនាំលោកណាលីណាក់ស្ហាមកលេងនឹងលោកអ៊ុំម្ដង លោកអ៊ុំគួរតែនិយាយទូន្មានលោកឲ្យបានប្រាកដប្រជា ទៅនិយាយលេងអី ទឹកស្ងោរបន្លែដែលលោកអ៊ុំប្រាប់ខ្ញុំឲ្យទទួលទាន

នៅពេលជិតប្រឡងពីកាលមុននោះ បានជួយធ្វើឲ្យខ្ញុំមានកម្លាំងពលំសម្បើមណាស់ ហើយបើជាមនុស្សដូចណាលីណាក់ស្វាវិញ ប្រាកដជាជួយប៉ូវកម្លាំងខួរក្បាលគេមែនទែនផង ។

ឮដូច្នោះ ជាជេទ្រាស្ទុះក្រោកពីកៅអី ។

— អាក់ស្ហាយឯងកុំនាំអញឆ្កួតអី? អញមិនត្រូវការស្តាប់ពាក្យចំកួតនេះទៀតទេ ?

ថាហើយអ្នកដើរចេញពីបន្ទប់ទៅ ។

## វគ្គទី ៤២

កាលដែលនាងហិមណាលិទី មិនទាន់មានវិបត្តិក្នុងឆាកជីវិតរបស់នាងលោកតាអាណាជា បាប៊ូ ក៏មានសុខភាពមាំមួនដែរ ប៉ុន្តែ តាំងពីមានរឿងវិបត្តិស្នេហានាងហិមណាលិទីនេះកើតឡើង លោកចេះតែពិសាថ្នាំនេះ ថ្នាំនោះពប់មិនអស់ តាមតែគ្រូពេទ្យប្រាប់ ជម្ងឺរបស់លោកក៏ហាក់ដូចជាមាយាផង ឲ្យតែឮអ្នកណាថាថ្នាំអ្វី ពូកែ លោកទៅទិញមកពិសាភ្លាម ដល់ថ្នាំច្រើនមុខពេកទៅ ទៅជាឡប់ជម្ងឺ ហើយសុខភាពលោកក្នុងពេលនេះ គួរឲ្យបារម្ភមែនទែន ។

ថ្ងៃនោះ លោក សម្រាន្តទាំងអផ្សុក ព្រោះលោកអស់កម្លាំងពេក

លុះព្រឹកឡើងបងដើរឡើងមក នាងហិមណាលិនីដាក់ការដេរចុះ ស្ទុះលបៗ ទៅប្រាប់បងកុំឲ្យធ្វើឲ្យគាត់ភ្ញាក់ ។ នាងទើបនឹងបើកទ្វារឡើងគាត់លោកតាភ្ញាក់ព្រើត ព្រោះបងនាងមិនមកតែឯងថែមទាំងនាំណាលីណាក់ស្ហាមកផង នាងដកខ្លួនថយប្រុងនឹងរត់ តែជាដេគ្រាស្រែកហៅនាងភ្លាម ។

-ន្ហែ បងនាំលោកណាលីណាក់ស្ហាមកលេង (នាងទុចជ៏ក់ទាំងអៀនអន់) ។ លោកណាលិនីណាក់ស្ហា ដើរចូលទៅជិត ហើយឱនក្បាលគោរពនាង តែមិនបើកភ្នែកមើលមុខនាងទេ ។

លោកតាអាណាដាបាប៊ូ ភ្ញាក់ដោយឮសូរមាត់មនុស្ស រួចស្រែករកកូនស្រី នាងរត់ចូលទៅជិតហើយឱនខ្សឹបជម្រាបឪពុកថាមានភ្ញៀវមកលេងផ្ទះ ។

-ខ្ញុំត្រេកអរណាស់ ដែលលោកអញ្ជើញមកលេងនឹងខ្ញុំ “ន្ហែ ! ហឹម កូនកុំអាលទៅណា (លោកតាភ័កឃាត់កូនស្រីលោក) លោកជ្រាបទេ ពីម្សិលមិញ កូនខ្ញុំបានទៅស្ដាប់សន្និសីទរបស់លោកជាមួយនឹងខ្ញុំ ខ្ញុំពេញចិត្តណាស់ ហើយពាក្យដែលលោកបានមានប្រសាសន៍ថា “របស់អ្វីដែលយើងរកបានហើយមិនដែលបាត់វិញទេ បាត់មួយតែរបស់ណា ដែលបានមកយើងមិនទាន់ស៊ីប់ នោះគឺពេញជាមហាត្រូវ ហើយមានន័យជ្រៅទៀតលោក មែនទេកូន? សូមលោកឧស្សាហ៍អញ្ជើញមកលេងនឹងខ្ញុំផងលោកណាលិន ព្រោះខ្ញុំមិនសូវចេញទៅណាមកណានឹងគេ

ញឹកញយទេ លោកអញ្ជើញមកម៉ោងណា ក៏លោកអាចជួបខ្ញុំនឹងកូនស្រីខ្ញុំនេះបានដែរ ។

មុននឹងឆ្លើយ លោកណាលិនបោះភ្នែកទៅមើលមុខនាង ដែលកំពុងតែខ្វល់ទទឹសទទាស ។

—សូមលោកកុំយល់ថា ខ្ញុំជាមនុស្សវាយឫកធ្វើបេះ ដោយខ្ញុំបានបញ្ចេញសុទ្ធតែពាក្យវប្បធម៌ នៅពេលដែលខ្ញុំបាននិយាយ ព្រោះថាពួកនិស្សិតគេបង្ខាញ់ខ្ញុំ បានជាខ្ញុំដាក់ឲ្យទាល់តែដល់កម្រិត វាគេពាក្យសួរខ្ញុំមិនទាន់ដោយវាមិនបានគិតមុនជួបខ្ញុំ បានជាវាគ្មានហ៊ានលើកដៃសួរម្នាក់សោះ ។ ដោះដន្ទ្រាក៏នៅទីនោះនឹងគេដែរ អ្នកបានឃើញស្រាប់ហើយហើយអ្នកកុំស្មានថា ខ្ញុំមិនដឹងជាអ្នកធុញនឹងខ្ញុំនោះ ព្រោះអ្នកចេះតែមើលនាឡិកាដៃអ្នកជាញយ ៗ ខ្ញុំមិនមែនមិនឃើញទេ ។

— សុំលោកកុំយកចិត្តទុកដាក់នឹងកាយវិការខ្ញុំពេក ព្រោះថាបើខ្ញុំមិនសូវបានស្តាប់លោក គឺមិនមែនខ្ញុំធុញទេ គឺមកអំពីប្រាជ្ញារបស់ខ្ញុំគិតមិនដល់ ។

— មែនហើយ រឿងខ្វះ ទាល់តែអាយុច្រើនបន្តិច ទើបចូលចិត្តចង់ដឹង ។

— ពិតណាស់លោកអ៊ុំ អាយុខ្វះគឺមិនសូវចង់ដឹងអ្វីប៉ុន្មានទេ ។

– នែ! លោកណាលិន មានការមួយសំខាន់ ដែលខ្ញុំចង់និយាយជាមួយនឹងលោក គឺថាសង្ខារដែលបានបង្កើតរូបលោកមក គឺដើម្បីឲ្យបំពេញករណីយកិច្ចអ្វីមួយ ប៉ុន្តែ លោកមិនត្រូវគ្រាន់តែបំពេញបេសកកម្មនោះប៉ុណ្ណោះទេ លោកត្រូវថែទាំខ្លួនលោកផងដែរណា៎ បើលោកចង់បានប្រយោជន៍ឲ្យគេ ត្រូវបេះផ្លែម្ដេចកុំឲ្យបាត់ដើម ទើបប្រសើរ បើបាត់ដើមអស់ទៅហើយ បានអ្វីធ្វើខ្លួនយកប្រយោជន៍ឲ្យមានគេតទៅទៀត ?

– ចាំបន្តិចទៀតសិនលោកអ៊ុំ ចាំដល់យើងស្គាល់គ្នាមែនទែន លោកអ៊ុំនឹងជ្រាបថា ក្មួយមិនដែលធ្វើខុសទោសដល់សត្វលោកណាមួយឡើយ ។ ក្មួយបានកើតមកក្នុងលោកនេះ គឺជាកព្យ់សនាមួយដ៏ធំអស្ចារ្យណាស់ទៅហើយ គួរអ្វីឡើយក្មួយនឹងហ៊ានបំផ្លាញតែដែលក្មួយធ្វើខ្លួនក្មួយមិនកើត ណាលោកអ៊ុំ ដូចជាព្រះហើនហួសហេតុពេកណាស់ ។

–មែន ! អ៊ីចឹងមែន ! ក្នុងសន្និសីទរបស់ក្មួយ ក្មួយបាននិយាយ ...

( ជោះជេន្ទ្រា ថៃបធុញ ) សុំទោស ខ្ញុំបានណាត់ពេលជួបនឹងគេម្នាក់ ខ្ញុំសុំលាសិនហើយ ។

ណាលីណាក់ស្ហា.– ខ្ញុំទៅជាមួយនឹងប្អូនដែរ យើងដើរជាមួយគ្នាបន្តិចទៅ សឹមយើងបែកគ្នា ។

ជោះចេន្ទ្រា.– ទេ លោកកុំកាលអញ្ជើញក្វាម ! ខ្ញុំសុំចិត្តលោក កុំ

គិតពីរឿងខ្ញុំទៅ ឬមិនទៅនោះ តាមធម្មតា ខ្ញុំមិនសូវដែលនៅនឹងមួយកន្លែងបានយូរទេ ។

អាណាជា ប៉ាប៊ូ.- ទៅណាទៅ ៗ ក្មួយណាលីណាក់ស្ហានៅឯនេះហើយ មួយថ្ងៃ មួយថ្ងៃ មិនដឹងជាគេទៅណាមកណាទេក្មួយអើយ ឃើញតែទៅមក ទៅមក អ្នកណាចេះទៅបោះដែកគោលវាយ៉ាងម្ដេច..។

ចប់ពាក្យសឹងតែមិនទាន់ ជាដ្ត្រាបេញរឹង លោកតាសួរទៅណាលីណាក់ស្ហាថាក្មួយឯងនៅឯណា ឥឡូវនេះ ?

លោកវេជ្ជបណ្ឌិតសើច ហើយឆ្លើយ :

- ខ្ញុំគ្មានទីកន្លែងប្រាកដនឹងជម្រាបលោកអ៊ុំទេ ព្រោះមិត្តខ្ញុំគេចេះតែអូសខ្ញុំទៅលិច ទៅកើត អ្នកណាក៏ចូលចិត្តឲ្យខ្ញុំទៅនៅជាមួយគេដែរ ។ ការដែលគេហៅគេរបៀបនេះ មិនមែនថាខ្ញុំមិនសប្បាយចិត្តទេ ប៉ុន្តែមានពេលខ្លះ ខ្ញុំចូលចិត្តនៅម្នាក់ឯងជាជាងមានគ្នា មែនទេ ? លោកអ៊ុំយល់ចិត្តខ្ញុំ បានជួយរកជួលផ្ទះមួយ នៅក្បែរផ្ទះលោកអ៊ុំបង្កើយនេះ ផ្លូវមុខផ្ទះនោះធំទូលាយ បើកផ្លូវឲ្យមានខ្យល់អាកាសល្អ ចេញចូលច្រើនហើយមិនសូវអ៊ូអរពេកផង ខ្ញុំសុំអរគុណលោកអ៊ុំ ។

ឮសូរលោកវេជ្ជបណ្ឌិតនិយាយដូច្នេះ លោកតាសប្បាយចិត្តណាស់ ប៉ុន្តែបើសិនជាលោកក្រឡេកមើលមុខកូនស្រីលោក . . . ព្រោះផ្ទះដែលវេជ្ជបណ្ឌិតនិយាយនោះ ជាផ្ទះដែលកាមេស្ហានៅពីមុខ ។

នៅពេលដែលភ្ញៀវកំពុងសន្ទនាគ្នា អ្នកបម្រើចូលទៅជម្រាបលោកតាយើងថា ទឹកតែរៀបស្រេចហើយ លោកតាក៏អញ្ជើញភ្ញៀវទៅកាន់បន្ទប់ទឹកតែ ប៉ុន្តែលោកណាលីណាក់ស្ហា សុំមិនទទួលទានទឹកតែនឹងនំទេ ហើយដោយខ្មាចនាងហិមណាលីនិយល់ថា មកពីខ្លាសនាងបានជាលោកប្រកែក លោកក៏និយាយបន្ថែម:

—សុំលោកអ៊ុំកុំយល់ថា ក្មួយប្រកាន់ ឬថាក្មួយមិនចូលចិត្តនឹងការទទួលរាប់របស់លោកអ៊ុំនោះ មិនដូច្នោះទេ ពីដើម ខ្ញុំទម្លាប់ទទួលទានទឹកតែនៅពេលនេះដូចលោកអ៊ុំដែរ ប៉ុន្តែ លោកអ៊ុំមិនទាន់ជ្រាបទេ ម្តាយខ្ញុំផុះទេ គាត់មិនសូវចូលចិត្ត នឹងរបៀបរៀបរយ ហើយដោយគាត់គ្មានកូនណាក្រៅអំពីរូបខ្ញុំផុះទេ ទើបខ្ញុំព្រមសុខចិត្តធ្វើតាមគាត់ទាំងអស់ គឺធ្វើដូចម្តេច កុំឲ្យតែគាត់អន់ចិត្តនឹងខ្ញុំ ។

នាងហិមណាលីទព្វះរៀបណ្តិត ចេះគោរពម្តាយ នាងពេញចិត្តណាស់ នាងចង់សួរអំពីម្តាយលោក តែនាងមិនហ៊ានព្រោះទើបនឹងស្គាល់គ្នា ។

(នៅមានត)

# រឿងខ្លីៗ មានន័យវែង

## ដកស្រង់ពីអដ្ឋកថាជាតក

អ្នកនិពន្ធតែងសេចក្ដី **ផល-ទិត** នៅក្រុមជំនុំព្រះត្រៃបិដក

(ក)

បាបនោះក៏ធ្វើតាមគំនិតដែលគិត ទាល់តែសរីរៈរាងកាយស្គមកំព្រឹង នៅតែស្បែកនិងឆ្អឹង ។ ពួកអ្នកទិញ ឃើញបាបនោះស្គម ក៏ពុំមានអ្នកណាទិញយកសោះ ។ ឯព្រាន លុះលក់បាបឯទៀតអស់ ឃើញនៅសល់តែបាបស្គមនោះមួយ ក៏នឹកពិភាល់ ទើបបើកទ្រុងលូកចាប់បាបនោះមកដាក់លើបាតដៃពិនិត្យមើល ដោយគិតថា តើវាយ៉ាងម៉េចអេះ! បានជាពុំមានអ្នកណាទិញបាបមួយនេះសោះ ? ។ បាបដឹងថា ព្រានកំពុងធ្វេសស្មារតី ក៏ទទះស្លាបភិល ហើរប្រេចចូលព្រៃបាត់ទៅ ។

ហំសិវគ្គ

## ២៣- សសេះ និង រាជសីហ៍

អ្នកមិនធ្វើគុណ, មិនតបគុណ និងអ្នកដែលស៊ីនល្មើសគុណគេ
ប្រុសកុំសេពគប់ជាមិត្រមេ គ្មានប្រយោជន៍ទេ ជនពួកនេះ ។

ថ្ងៃមួយ រាជសីហ៍ចាប់បានម្រឹគមួយយ៉ាងធាត់ ហើយដោយស៊ីបន្ទំទាំងឃ្លានពេក ក៏ស្លាក់ឆ្អឹងមួយកំណាត់ទៅក្នុងបំពង់ក នាំឲ្យកឡើងហើមស្តុល មានការឈឺចាប់យ៉ាងខ្លាំងក្លា ពុំអាចឲ្យលេបអ្វីទៀតចូលពោះបានសោះឡើយ ។ ពេលនោះ សារសេះមួយ ទំលើមែកឈើក្បែរនោះ ឃើញរាជសីហ៍ដេកស្លុកស្តឹង ក៏ស្រែកសួរថា សំឡាញ់អើយ ! បងឯងកើតអី ? ។ រាជសីហ៍ ក៏យំរៀបរាប់ប្រាប់ អំពីគ្រោះថ្នាក់របស់ខ្លួន ។ សារសេះនឹកអាណិត ក៏និយាយថា ខ្ញុំអាចនឹងយកឆ្អឹងពីបំពង់កសំឡាញ់ឯងចេញបាន ប៉ុន្តែ ខ្ញុំពុំហ៊ានចូលទៅយកទេ ខ្លាចសំឡាញ់ឯងខាំខ្ញុំ ។ រាជសីហ៍អង្វរគេថា សំឡាញ់អើយ ! ខ្ញុំពុំខាំសំឡាញ់ឯងទេ, សូមមេត្តាជួយជីវិតខ្ញុំផង ! ។ សារសេះទទួលព្រម តែពុំទុកចិត្ត ក៏យកឈើមួយកំណាត់ទៅដាក់ទល់មាត់រាជសីហ៍កុំឲ្យបិទបាន រួចទើបចូលទៅក្នុងមាត់ ចឹកទាញឆ្អឹងដែលមុតជាប់បំពង់កនាំចេញមកក្រៅ រួចចឹកទាញឈើចន្ទល់មាត់ចេញ ហើយប្រញាប់ហើរទៅទំនៅលើមែកឈើខាងលើវិញ ។ រាជសីហ៍ លុះបានរួចខ្លួនពីគ្រោះថ្នាក់ ត្រេកអរសប្បាយណាស់ ហើយចោលចេញពីទីនោះទៅ ។ ថ្ងៃមួយ សារសេះឃើញរាជសីហ៍ចាប់បានក្របីព្រៃស៊ី ក៏គិតចង់ល្បងចិត្តមើល ទើបហើរទៅទំលើមែកឈើមួយជិតរាជ-សីហ៍ ហើយនិយាយថា សូមគោរព! លោកមិគរាជ! ខ្ញុំបាទសុំសាច់កម្ទេចកម្ទីខ្លះ ជាតម្លៃនៃកម្លាំង ដែលខ្ញុំបាទបានបំពេញកិច្ចជួយពីថ្ងៃមុននោះ ។ រាជសីហ៍ឮសារសេះស្រែកសុំ ក៏ឆ្លើយទៅវិញថា យើងជាសត្វមាន

សាច់និងឈាមជាភក្សាហារ ជាសត្វអ្នកប្រមាញ់, បើឯងរស់ដោយសារ សាច់ណា ចូរឯងដើរចូលមកតាមចន្លោះបក្ខយើង ហើយយកសាច់នោះ ទៅស៊ីឲ្យបានច្រើនចុះ ។ សរសេះពុង្ហ្លោះ ក៏និយាយថា "ការគប់រក សត្វដែលមិនដឹងគុណគេ, ដែលមិនធ្វើគុណ និងដែលល្មើសគុណគេ ជាការឥតប្រយោជន៍មែន", រួចហើយ ក៏ហើរចេញពីនោះបាត់ទៅ ។

កាលិង្គវត្ត

## ២៤- អ្នកល្មោភ លោភប្រជែងគេ

មេបក្សីណាប្រដៅគេ　　ប៉ុន្តែខ្លួនឯងងប់ហិច្ឆា (១)
នោះនឹងធ្លាក់ស្លាបស្លាប់ខ្លោចផ្សា　　ដូចមេសារិកាត្រូវកង់កិន ។

មេសារិកាមួយ ហើរត្រាច់ទៅរកចំណី បានឃើញគ្រាប់ស្រូវអង្ករ គ្រាប់សណ្តែក គ្រាប់ពោតជាច្រើន ដែលកំពប់ធ្លាក់ពីរទេះពួកឈ្មួញ តាមផ្លូវធំ ក៏គិតថា អញនឹងធ្វើកុំឲ្យពួកបក្សឯទៀតមកដណ្តើមរកស៊ីនៅទីនេះ ។ គិតហើយ មេសារិកានោះ កាលត្រឡប់ទៅទីលំនៅវិញ ក៏ឲ្យឱវាទដំបូន្មានដល់សារិកាទាំងពួងថា ផ្លូវធំរបស់ពួកឈ្មួញ ជាផ្លូវប្រកប ដោយភ័យគ្រោះថ្នាក់ណាស់ ព្រោះមានសេះ និងរទេះទឹមគោកាច ។

---

១ អានគំនិតចង់បានច្រើន ។

សព្វរបរទៅមកមិនដាច់ មិនអាចនឹងឲ្យបក្សីទាំងឡាយ ស្ទុះហើរយ៉ាងរហ័សគេចខ្លួនពីគ្រោះថ្នាក់បានឡើយ, ហេតុដូច្នេះ អ្នកពាល់គ្នា កុំទៅស្វែងរកចំណីនៅផ្លូវធំនោះឲ្យសោះ ៗ សារិកាទាំងអស់ ក៏ធ្វើតាមនុវាទ ពុំហ៊ានហើរទៅរកស៊ីនៅទីនោះឡើយ ៗ រីឯមេសារិកានោះវិញ បែរជាលួចទៅតែម្នាក់ឯង, លុះទៅដល់ផ្លូវធំ ស្រាប់តែឮស្នូររទេះបរសំដៅមក ប៉ុន្តែដោយអាងថានៅឆ្ងាយ ក៏ចុះទៅចឹកវាប់ចំណីលើផ្លូវធំនោះ ៗ មេសារិកាកំពុងតែឱនចឹក, ស្រាប់តែរទេះមួយលឿនដូចជាសន្ទុះខ្យល់ មកដល់ភ្លាម ៗ មេបក្សីភ័យកន្តុកាំង ស្ទុះហើរឡើងភ្លាម, តែជាអកុសលវាហើរពុំទាន់ ក៏ត្រូវកង់រទេះកិនបាក់ស្លាបស្រប៉ាប ដេកស្លាប់ នៅទីនោះយ៉ាងខ្លោចផ្សា ៗ

ហំសីវគ្គ

## ២៥ - ម្រឹគអភ័ព្វ ជាប់ព្រួញរះស្នេហ៍

យោធាក្លាហានត្រូវព្រួញមុត ប្រែជាតក់ស្លុតទន់ស្មារតី
និងជនដែលលុះអំណាចស្ត្រី បណ្ឌិតកវីគួរតិះដៀល ។ –

ម្រឹគព្រៃកំមួយ បានជាប់ចិត្តប្រតិព័ទ្ធនឹងនាងម្រឹគព្រៃជិតស្រុក ៗ

លុះដល់ពេលរដូវដែលពួកម្រឹគត្រូវចុះពីខ្នងភ្នំ ដើម្បីទៅរកស៊ីល្បាស់ខ្ចី នៅតាមព្រៃជិតស្រុក , នាងម្រឹគ និយាយនឹងសង្សារថា សូមបង កុំចូលទៅរកស៊ីជិតស្រុក ព្រោះព្រៃជិតភូមិស្រុក ជាទីប្រកបដោយភ័យអន្តរាយ និងសេចក្ដីរង្កៀសច្រើនណាស់ ។ ម្រឹគភ្នំ ពុំព្រមស្ដាប់ ព្រោះពុំអាចដកចិត្តស្និទ្ធប្រតិព័ទ្ធពីមេម្រឹគបាន ក៏បរចេសទៅតាម ។ លុះបណ្ដើរគ្នាទៅដល់តំបន់មួយ , មេម្រឹគធុំក្លិនមនុស្ស ក៏ដឹងច្បាស់ថា មានព្រាននៅពួនចាំធ្វើសេចក្ដីអន្តរាយ ទើបបកដើរពីក្រោយម្រឹគភ្នំវិញ ។ ព្រានប្រមាញ់ ឃើញម្រឹគក្ញើនោះដើរមកដល់ជិត ក៏យឹតធ្នូលែងព្រួញទៅត្រូវចំម្រឹគភ្នំដួលស្លាប់ក្នុងទីនោះ ។ ឯនាងម្រឹគវិញ គ្រាន់តែឮសំឡេងព្រួញភឹង ក៏ប្រាសស្ទុះបោលបោះរត់គេចពីទីនោះ ចូលព្រៃជ្រៅបាត់ទៅ ។

សីលវត្ត ·

## ២៦- ចាប់ឈ្លូស ដោយរសជាតិ

ការញ៉ាមជាមចិត្តស្អិតទាំងអស់ ឥតអ្វីជាងរសជាតិទាំងឡាយ
ឈ្លូសព្រៃក្រៃថ្លាងយ៉ាងផ្អើលឆាយ ឆាយសូនចាប់ងាយដោយសាររស ។

មានសត្វឈ្លូសមួយ អាស្រ័យនៅក្នុងឧទ្យាន ។ ព្រះរាជាទ្រង់

ឃើញឈ្លូសនោះ ក៏សព្វព្រះហឫទ័យ ប៉ុន្តែចាប់ពុំបាន ព្រោះឈ្លូសនោះជាសត្វផ្អាំងរអើលណាស់ ពុំដែលឲ្យជិតជនណាម្នាក់ឡើយ ទើបទ្រង់បញ្ជាឲ្យឧយ្យានបាល(១)រកវិធីចាប់ឈ្លូសនោះ ។ ឧយ្យានបាល ក៏ប្រើឧបាយកល ដោយយកទឹកឃ្មុំទៅប្រស់បាចសាចលើស្មៅដែលឈ្លូសបំណាំតែចូលទៅស៊ី ។ ម្រឹគឈ្លូសនោះ លុះមកស៊ីស្មៅនោះហើយ ជាប់ចិត្តនឹងមធុរសនៃទឹកឃ្មុំ ក៏លែងទៅរកស៊ីនៅទីណាទៀត ហើយចេះតែហ៊ានបន្តិចម្តង ៗ រហូតដល់ហ៊ានទទួលស៊ីស្មៅដែលឧយ្យានបាលកាន់ហុចផ្ទាល់នឹងដៃ ។ លុះដឹងថា ឈ្លូសនោះមានការស្និទ្ធស្នាលអស់ពីចិត្តហើយ នាយឧយ្យានបាល ក៏ឲ្យគេយកកន្ទេលកម្បាំងជារបាំងតាមបណ្តោយសងខាងផ្លូវយ៉ាងជិត តាំងពីឧទ្យាន រហូតដល់ខាងក្នុងព្រះរាជវាំង, កាប់មែកឈើដាក់ពង្រាយហែផ្លូវ រួចយកស្មៅមួយបាច់ដែលប្រឡាក់ដោយជាតិទឹកឃ្មុំមកលីដើរពីមុខឈ្លូស ហើយចេះតែបោចស្មៅនោះទម្លាក់ហូរហែទៅមុខ ៗ ដោយការឆ្ងាញ់នឹងរសជាតិស្មៅប្រឡាក់ដោយទឹកឃ្មុំ, ម្រឹគឈ្លូសនោះ ក៏ដេញតាមស៊ីស្មៅទៅ រហូតដល់ចូលក្នុងព្រះរាជវាំង ។ លុះងាកមើលជុំវិញ ឃើញគេខ្ទប់បិទទ្វារជិតអស់ ទើបឈ្លូសដឹងថា “ខ្លួនលង់ក្នុងកលឧបាយគេ ចូលមកនៅក្នុងវាំងហើយ” ក៏កិតភ័យញាប់ញ័រ ឆ្វេឆ្វារកច្រកចេញ តែពុំបានសម្រេចដូចបំណងឡើយ ។

---

១- អ្នករក្សាឧទ្យាន ។

សីលវត្ត

# ២៧- ម្រឹគពីរក្បួននិនាយក

ត្រូវគប់រកម្រឹគឈ្មោះនិគ្រោធ កុំឆោតគប់ម្រឹគឈ្មោះសាខៈ
ស្លាប់ក្នុងនិគ្រោធសមឋានៈ ស្លាប់ក្នុងសាខៈពុំសមឡើយ ។

សម័យនោះ ព្រះពជាពារាណសី ទ្រង់ជាប់ព្រះហឫទ័យនឹងការបរបាញ់ រហូតដល់ព្រះស្ងោយដែលពុំមានសាច់ម្រឹគ ក៏ទ្រង់ពុំសោយទាល់តែសោះ ។ ដើម្បីសម្រួបនឹងការណ៍នេះ ពួកអ្នកនគរ ក៏នាំគ្នាដាំស្មៅនិងដីកថ្នុកត្រពាំងក្នុងបរិវេណឧទ្យាន បញ្ឆោតឲ្យពួកម្រឹគជាច្រើនចូលទៅនៅក្នុងនោះ រួចនាំគ្នាហ៊ុមព័ទ្ធរបងជុំជិត ។ កាលនោះ មានប្រើសមាសពីរគឺប្រើសឈ្មោះនិគ្រោធមួយ, ប្រើសឈ្មោះសាខៈមួយ ដែលជាប្រើសមេខ្វាង មានម្រឹគជាបរិវារប្រមាណប្រាំរយៗដូចគ្នា ត្រូវជាប់ក្នុងឧទ្យាននោះ ។

លុះធ្វើការនេះបានសម្រេចហើយ ពួកអ្នកនគរក៏នាំគ្នាទៅក្រាបទូលព្រះពជាឲ្យស្តេចចេញទៅក្រសាលបរបាញ់ ។ ព្រះពជាទ្រង់ស្តេចទៅដល់ឧទ្យានទ្រង់ឃើញប្រើសមាសជាមេខ្វាងទាំងពីរ ក៏មានព្រះទ័យស្រឡាញ់ទើបព្រះពជទានអភ័យ ពុំឲ្យជនណាធ្វើអ្វីប៉ះពាល់ដល់ប្រាណ នៃសត្វប្រើសទាំងពីរនោះឡើយ ។ ប៉ុន្តែ ទ្រង់បាញ់ប្រើសឯទៀតយកទៅធ្វើព្រះស្ងោយ ដោយព្រះអង្គឯងខ្លះ ជួនកាលនាយពិសេសទៅសម្លាប់ខ្លះជារៀងរាល់ថ្ងៃ ។ ម្ល៉ោះហើយ ប្រើសទាំងឡាយ ក៏ក្រាក់ផ្អើលខ្វាច

សេចក្ដីស្លាប់ នាំគ្នាគេចរត់ប្រួលប្រចល់ ហើយខ្លះដែលត្រូវនឹងគ្រឿងប្រហារហើយ ក៏រងការឈឺចាប់ រត់ទៅទាំងទុក្ខវេទនា ។ ឃើញព្រឹត្តិ-ការណ៍ដែលពុំមានផ្លូវដោះស្រាយបានដូច្នេះ ទើបប្រើសមេខ្លោងទាំងពីរប្រឹក្សាស្រុះស្រួលគ្នាចាត់ឲ្យប្រើសមួយៗតាមវេនឲ្យគេសម្លាប់ដោយស្រួលជារៀងរាល់ថ្ងៃ ដើម្បីចៀសវាងការភ័យផ្អើល និងទុក្ខវេទនា ដល់ម្រឹគទាំងពួង ដូចពីពេលមុន ។ ដូច្នេះ ប្រើសណាដែលត្រូវវេន , ប្រើសនោះ ត្រូវទៅដេកផ្កាប់មុខឲ្យគេសម្លាប់ដោយស្រួល ជារៀងរាល់ថ្ងៃ ។ លុះថ្ងៃក្រោយមក វេនស្លាប់ ក៏ត្រូវមកដល់មេប្រើសមួយ ដែលមានផ្ទៃពោះ ។ មេប្រើសនោះ មានសេចក្ដីតក់ស្លុត ក៏ទៅអង្វរករប្រើសសាខៈ ដែលជាមេខ្លោងរបស់ខ្លួន សុំឲ្យពន្យារពេលចូលវេន ទម្រាំនាងកើតកូនសិន ។ ប្រើសសាខៈពុំយល់ព្រម ដោយអាងលេសថា ពុំអាចនឹងបង្វែរវេននាងទៅដាក់លើគេដទៃបានឡើយ ។ មេប្រើសអភ័ព្វអស់សង្ឃឹមយំសោករត់ទៅរកប្រើសនិគ្រោធឲ្យជួយដោះទុក្ខ ។ ប្រើសនិគ្រោធ ក៏សុខចិត្តធានាជួយ ដោយករុណា ទើបឲ្យមេម្រឹគនោះ វិលទៅនៅជាសុខវិញ ហើយចូលខ្លួនឯងទៅដេកផ្កាប់មុខត្រង់កន្លែងដែលគេសម្លាប់ ។ នាយពិសេស ឃើញដូច្នេះ ក៏រត់ទៅបង្គំទូលព្រះរាជាថា ប្រើសមាសដែលព្រះអង្គទ្រង់ឲ្យអភ័យនោះ ស្រាប់តែមកដេក ឲ្យគេសម្លាប់ខ្លួនទៅវិញ ។ ព្រះរាជាទ្រង់យាងទៅទតផ្ទាល់ ហើយទ្រង់សួរប្រើសមាសអំពីព្រឹត្តិការណ៍នោះ ។ ប្រើសមាសនិគ្រោធ ក៏ក្រាបទូលតាមរឿងហេតុ

ដោយសព្វគ្រប់ ៗ ព្រះរាជាទ្រង់ជ្រះថ្លាចំពោះចិត្តដែលប្រកបដោយខន្តីមេត្តាអាណិតរបស់ប្រើសនិគ្រោធនោះ ទើបទ្រង់ព្រះរាជទានអភ័យ ដល់ម្រឹគទាំងនោះថា តាំងពីពេលនេះតទៅ លែងឲ្យជនណាម្នាក់មកប្រហារម្រឹគក្នុងឧទ្យាននេះទៀតហើយ ៗ តាំងពីនោះមក ម្រឹគទាំងនោះ ក៏មានសេរីភាព រួចចេញពីសេចក្តីស្លាប់ ដោយសារប្រើសមាស ឈ្មោះនិគ្រោធនោះឯងហោង ៗ

សីលវត្ត

# ២៨- មេម្រឹគ ដឹកនាំហ្វូង

បម្រើនតែងកើតពុំវេចវិល ដល់អ្នកមានសីល បដិសណ្ឋារៈ
ចូរមើលពួកញាតិហែលក្ខណៈ ចូរមើលកាឡៈ ដើរម្នាក់ឯង ។

សម័យមួយ ក្នុងរដូវដែលចង្អៀតចង្អល់ ខ្វះខាតល្បាស់ខ្ចីចំណីអាហារ, ម្រឹគពោធិសត្វ ក៏បែកពួកម្រឹគជាបរិវារឲ្យដល់ម្រឹគជាកូនពីររូប គឺ ម្រឹគឈ្មោះលក្ខណៈមួយ, ម្រឹគឈ្មោះកាឡៈមួយ, ឲ្យនាំបរិវារប្រាំរយៗម្នាក់ ចុះពីលើខ្នងភ្នំ ទៅស្វែងរកល្បាស់តាមព្រៃជិតភូមិស្រុក ៗ ម្រឹគឈ្មោះកាឡៈ ជាសត្វល្ងង់ខ្លៅ ពុំស្គាល់កាលគួរពុំគួរ ក៏នាំបរិវារ

ចូលស៊ីសន្ទូងអ្នកស្រុក ក្នុងពេលព្រឹកព្រហាមខ្លះ ក្នុងពេលល្ងាចខ្លះ ក្នុងពេលព្រលប់ខ្លះ ដែលជាពេលត្រូវម្ចាស់សន្ទូងកំពុងនៅចាំថែរក្សា , ម្ល៉ោះហើយ ម្រឹគជាបរិវារដ៏ច្រើន ក៏ត្រូវវិនាសស្លាប់ ដោយស្នុះអន្ទុង មុតចម្រូង ត្រូវទីងព្រួញ ជាប់អន្ទាក់ជាដើម របស់ពួកអ្នកស្រុក ។ រីឯម្រឹគឈ្មោះលក្ខណៈវិញ ជាសត្វមានប្រាជ្ញាឈ្លាសវៃ ស្គាល់កាលគួរ កាលពុំគួរ តែងនាំបរិវារចូលលបស៊ីសន្ទូង ក្នុងពេលពាក់កណ្ដាលអធ្រាត្រជាពេលដែលពុំមានម្ចាស់នៅការពាររក្សា , ម្ល៉ោះហើយ ក៏ឥតមានគ្រោះថ្នាក់អ្វីដល់ពួកម្រឹគជាបរិវារណាមួយឡើយ ។

លុះរដូវល្បាស់ខ្ចីនៅលើខ្នងភ្នំលូតលាស់ឡើងហើយ ម្រឹគទាំងពីរក៏នាំគ្នាឡើងទៅលើភ្នំវិញ ។ ម្រឹគលក្ខណៈ នាំបរិវារឡើងទៅដល់គ្រប់ចំនួនដោយសួស្ដី ឥតមានបេះបាត់មួយឡើយ ។ ឯម្រឹគកាឡៈវិញបានទៅដល់ទីកន្លែងមាតាបិតា តែម្នាក់ឯងគត់ ព្រោះបរិវារខ្លួន ត្រូវវិនាសស្លាប់អស់ឥតមានសេសសល់ឡើយ ។

សីលវគ្គ

## ២៩- ឈ្មួញអាងឈ្មោះ

អ្នកឯងឈ្មោះ“ប្រាជ្ញ”ទើបឧត្ដម ល្អជាងកូនខ្ញុំឈ្មោះ“លើសប្រាជ្ញ”
ខ្ញុំរងទុក្ខធ្ងន់ដោយអំណាច លើសប្រាជ្ញកូនខ្ញុំនាំចូលភ្លើង ។

មានឈ្មួញពីរនាក់, ម្នាក់ឈ្មោះប្រាជ្ញ ម្នាក់ទៀតឈ្មោះលើសប្រាជ្ញ ជាអ្នករកស៊ីចូលហ៊ុនគ្នា ។ ថ្ងៃមួយ ឈ្មួញទាំងពីរនាក់ ផ្ទុកទំនិញពេញរទេះ៥០០ ទៅលក់ដូរនៅស្រុកជនបទ, លុះលក់អស់អីវ៉ាន់ហើយ ក៏នាំគ្នាត្រឡប់មកវិញ ។ ក្នុងពេលដែលត្រូវចែកចំណេញគ្នា លើសប្រាជ្ញ និយាយនឹងប្រាជ្ញថា “នែសំឡាញ់! ភណ្ឌៈទាំងអស់នេះ ត្រូវចែកជា៣ចំណែក ហើយត្រូវឲ្យខ្ញុំ២ចំណែក, សំឡាញ់ឯងត្រូវយកតែ១ចំណែកបានហើយ ព្រោះខ្ញុំឈ្មោះលើសប្រាជ្ញ ជាឈ្មោះធំលើសអ្នកឯងឈ្មោះប្រាជ្ញ ។ ប្រាជ្ញ ពុំយល់ព្រម ដោយសម្អាងថា យើងចេញប្រាក់ដើមទុនប៉ុនគ្នា ហើយកម្មករគោរទេះ ក៏ស្មើ ៗ គ្នាដែរ មិនត្រូវចែកចំណេញឲ្យតិចច្រើនជាងគ្នា ដោយអាងលើឈ្មោះតូចធំទេ ។ កាលបើគិតចែកពុំចុះសម្រុងនឹងគ្នាដូច្នេះ លើសប្រាជ្ញ ក៏គិតឧបាយមួយ គឺយកឪពុករបស់ខ្លួន ទៅបញ្ចូលឲ្យពួននៅក្នុងរន្ធឈើមួយដើមឲ្យចាំកាត់សេចក្តី រួចទៅនិយាយនឹងប្រាជ្ញថា នែសំឡាញ់! រឿងដែលត្រូវចែកចំណែកឲ្យខ្ញុំ ២ ភាគនេះ ត្រឹមត្រូវឬពុំត្រឹមត្រូវ គួរយើងទៅប្តឹងរុក្ខទេវតានៅដើមឈើនោះឲ្យវិនិច្ឆ័យចុះ, មក! យើងទៅសួរល្បងមើល ។ ប្រាជ្ញ ក៏សុខចិត្តទៅតាម, លុះទៅដល់ដើមឈើដែលបំពួនឪពុកនោះ លើសប្រាជ្ញក៏ផ្តើមនិយាយប្តឹងទេវតាថា “បពិត្ររុក្ខទេវតា! សូមលោកមេត្តាកាត់សេចក្តីឲ្យយើងខ្ញុំបន្តិច! ។ ទេវតាក្លែងក្លាយ ក៏បញ្ចេញសម្លេងថ្លែងស្រែកពីរន្ធឈើមកថា ឲ្យកាត់យ៉ាងម៉េច ? និយាយមកមើល! ។ លើស-

ប្រាជ្ញ កំនិយាយថា លោកទេវតា ! ខ្ញុំបាទនេះឈ្មោះលើសប្រាជ្ញ, ឯសំឡាញ់ខ្ញុំម្នាក់នេះឈ្មោះ ប្រាជ្ញ, យើងខ្ញុំធ្វើជំនួញចូលជាមួយគ្នា, តើយើងខ្ញុំត្រូវចែកភាគចំណេញដល់គ្នាយ៉ាងណា ទើបត្រូវ ? ។ រុក្ខទេវតាឆ្លើយថា ត្រូវចែកចំណេញជា ៣ ភាគ ហើយឲ្យប្រាជ្ញមួយភាគ, ឲ្យលើសប្រាជ្ញ ២ ភាគ ទើបត្រឹមត្រូវតាមយុត្តិធម៌ ។ ប្រាជ្ញឮដូច្នោះ កំនិយាយថា ឈប់សិនសំឡាញ់ ! ចាំខ្ញុំបញ្ជាក់នឹងទេវតានេះសិន ! ។ ប្រាជ្ញ កំទៅប្រមូលកងចំបើងមួយកងធំ មកដាក់ត្រង់រន្ធឈើនោះ រួចដុតភ្លើងឲ្យឆេះទ្រលោមឡើង ។ ទេវតាក្លែងក្លាយ លុះត្រូវអណ្តាតភ្លើងឆាបដល់ កំពេលអស់ពាក់កណ្តាលខ្លួន ក្តៅក្រហល់ក្រហាយ ស្ទុះកញ្ឆ្រោលតាមប្រហោងឈើ ទៅតោងមែកឈើ ហើយលោតទម្លាក់ខ្លួនមកដី រួចស្រែកថា ប្រាជ្ញ ចែកត្រូវ, ចែកតាមលើសប្រាជ្ញ មិនត្រឹមត្រូវទេ, ព្រោះវាំនាំឪពុកចូលភ្លើង ឲ្យឆេះពេលអស់ពាក់កណ្តាលខ្លួនទៅហើយ ! ។ ទាល់តែជួបនឹងព្រឹត្តិការណ៍យ៉ាងធ្ងន់ដូច្នេះ ទើបលើស-ប្រាជ្ញព្រមចែកចំណែកស្មើគ្នាទៅវិញ ។

លិគ្គវគ្គ

# ៣០- បក្សីប្រហែស ត្រូវភ្លើងឆេះស្លាប់

ពពួកបក្សីនៅធម្មតា នឹងដើមឈើណាលើផែនដី
ដើមឈើនោះឯងមានប្រក្រតី បញ្ចេញរស្មីភ្លើងផ្កាព្រាយ ។
ម្នាលពួកអ្នកមានអរិយវៈល្អ គឺក្បាលនិងករៀបចាំងឡាយ
ចូរឆាប់គប់រកទិសសប្បាយ អន្តរាយមានពីទីពឹងហើយ ។

*សម័យមួយ ដើមឈើធំមួយដើម ដែលបក្សីជាច្រើននៅអាស្រ័យ, កាលណា មានខ្យល់បក់មកត្រូវ មែកឈើពីរមែក បេះតែសង្កៀតគ្នា បណ្ដាលឲ្យជ្រុះផង់លម្អិតហុយជាផ្សែង ។ បក្សីពោធិសត្វ ឃើញហេតុដូច្នោះ ក៏គិតថា មែកឈើពីរនេះ កាលណាសង្កៀតគ្នាញយៗ ទៅ នឹងចេញជាផ្សែង ក្ដៅហែងឡើងចេញជាភ្លើង, ភ្លើងនោះ ធ្លាក់ទៅឆេះស្លឹកស្ងួតៗខាងក្រោម ហើយនឹងបណ្ដាលឲ្យឆេះដើមឈើនេះ ពុំខាន ។ លុះយល់ដូច្នេះហើយ ពោធិសត្វប្រាប់ហេតុការណ៍នេះដល់គ្នា រួបរួមពួកបក្សីដែលជឿស្ដាប់ លើកទីកន្លែងទៅរកនៅទីលំនៅដទៃទៀតវិញ ។ ឯពួកបក្សីដែលពុំជឿស្ដាប់ មិនរវល់ហើរចេញពីដើមឈើនោះឡើយ ហើយថែមទាំងនិយាយចំអកឲ្យពោធិសត្វថា ពោធិសត្វឃើញក្រពើក្នុងទឹកមួយតំណក់ ។*

*មិនយូរប៉ុន្មាន ភ្លើងក៏បណ្ដាលអំពីមែកឈើពីរមែកដែលសង្កៀតគ្នានោះមែន ។ បក្សីពាលទាំងនោះ លុះផ្សែងភ្លើងគ្រលគ្រុបចូលក្នក*

ចូលប្រមុះ រកផ្លូវស្ទុះហើរចេញពុំទាន់ ក៏ត្រូវអណ្ដាតភ្លើងឆាបឆេះស្លាប ពេលកលប្រាណ បានសេចក្ដីវិនាសស្លាប់អស់ពុំមានសល់ ។

កុណាវិកវិត្ត

## ៣១- កូនម្រឹគច្នឹកមាយា

អូនអើយ! កូនម្រឹគ ជាសត្វផឹកទឹក ក្នុងពេលរាត្រី
មានជំនាញបី ក្របកប្រាំបី បានរៀនទ្រឹស្ដី
មាយាគ្រប់យ៉ាង ។ ម្រឹគក្ដួយនឹងដេក ធ្វើស្មើតស្ងង់ភ្នែក
ដាក់ប្រមុះម្ខាង ផ្ទប់ដីដោយប្រើ កលប្រាំមួយយ៉ាង
ឲ្យព្រានគេងគាង រួចខ្លួនពុំលែង ។

មេម្រឹគមួយ នាំកូនទៅឲ្យម្រឹគជាបងជួយបង្ហាត់បង្រៀនទូវម៉ិគមា-យា(១) ។ ម្រឹគបង ក៏ព្រមទទួល ហើយកំណត់ពេលវេលាឲ្យម្រឹគក្មួយនោះចូលមកសិក្សា ។ កូនម្រឹគ ក៏មកសិក្សាយ៉ាងទៀងទាត់តាមពេលកំណត់ ។ ថ្ងៃមួយ កូនម្រឹគនោះ ត្រាច់ទៅរកស៊ីល្បាស់ក្នុងព្រៃ ក្លាត់ស្នៀតជាប់អន្ទាក់ព្រានព្រៃ ។ ម្រឹគឯទៀតដែលទៅជាមួយ ភិតភ័យរត់ចោលអស់ ហើយទៅប្រាប់មេម្រឹគជាម្ដាយ ។ នាងម្រឹគមានការព្រួយបារម្ភណាស់ ក៏ទៅរកបង ហើយសួរបញ្ជាក់ថា បងបាន

---

១- ការលាក់ពុត, បិទបាំងពុត នៃម្រឹគ ។

បង្រៀនមិគមាយាដល់ក្មួយដែរឬទេ ? ។ ម្រឹគបងប្រាប់វិញថា នាង
កុំភ័យបារម្ភអ្វីឡើយ , កូននាងបានសិក្សាមិគមាយាសព្វគ្រប់អស់ហើយ
ពានឹងដោះខ្លួនរួចរត់មកដោយសួស្ដីពុំខាន ។

ឯកូនម្រឹគដែលជាប់អន្ទាក់នោះវិញ លុះឃើញព្រានដើរមក ក៏ពុត
ធ្វើជាស្លាប់ ។ ព្រានគិតពុំដល់ ក៏នឹកថា ម្រឹគនោះស្លាប់ពិតឥតសង្ស័យ
ទើបដោះអន្ទាក់ចេញ ដើម្បីនឹងបាត់ការវះពន្លះយកសាច់ទៅផ្ទះ ។ ម្រឹគ
ឃើញឱកាសល្អ ក៏ស្ទុះបោលចូលព្រៃ រួចខ្លួនពេលនោះហោង ។

សីលវគ្គ

## ៣២- មយូររះរាំ

ខ្នងអ្នកក្រុងរៀងរាងក្រពុំ សំឡេងយាសយំ ស័ព្ទមធុរ
ផ្តកកពណ៌ដូចកែវពៃទូរ្យ ភ្លឺដូចគំនូរវិចិត្រល្បី ។
ឯស្លាបទាំងឡាយវែងលលាម ប្រមាណមួយព្យាមមានរស្មី
តែយើងពុំត្រូវឲ្យកូនស្រី ទៅរៀបក្សីឥតខ្មាសទេ ។

ថ្ងៃមួយ រាជហង្សជាស្ដេចបក្សី ចេញប្រកាសប្រាប់ឲ្យពួកបក្សីទាំង
អស់ ក្នុងសាកលលោកឲ្យមកប្រជុំគ្នា ដើម្បីនឹងឲ្យនាងហង្សកញ្ញាជាបុត្រី
ជ្រើសរើសរកស្វាមី ។ លុះសត្វស្លាបគ្រប់ប្រភេទ មកជួបជុំគ្នាហើយ

រាជហង្សក៏ហៅរាជបុត្រីឲ្យចេញទៅជ្រើសរើសមើលដោយសេរី ៗ ហង្សកញ្ញា សម្លឹងមើលបក្សីទាំងអស់ដែលបង្គំគាល់នៅត្រៀបត្រា ក៏គាប់ព្រះហឫទ័យនឹងក្ងោកកម្លោះមួយ ដែលមានផ្ទួតកពណ៌ដូចកែវមណី ហើយក៏ក្រាបទូលព្រះបិតាថា ខ្ញុំម្ចាស់ ត្រូវចិត្តនឹងក្ងោកនោះ ៗ បក្សីទាំងអស់ នាំគ្នាសរសើរដោតកសនាក្ងោកនោះលាន់ឮខ្ទៀវខ្ទារ ។ រីក្ងោកកម្លោះនោះវិញ មានចិត្តត្រេកអរដោរដោយអំណួត ក៏គិតថា " ក្នុងថ្ងៃនេះ អញនឹងបញ្ចេញថ្វីដៃឲ្យពួកបក្សីទាំងនេះបានឃើញម្តង " ហើយក៏លែងគិតអៀនខ្មាស , ត្រដាងស្លាបរាំរពើតរពើន ក្នុងកណ្តាលហ្វូងបក្សីដែលកំពុងប្រជុំគ្នានោះ ៗ រាជហង្សជាបិតា ឃើញកិរិយាពុំគប្បីរបស់ក្ងោកដូច្នោះ នឹកខ្មាសបរិស័ទយ៉ាងក្រៃលែង ដោយគិតថា ក្ងោកក្មេងនេះ ជាសត្វឥតអៀនខ្មាសអីបន្តិចបន្តួចទាល់តែសោះ ៗ លុះគិតហើយ រាជហង្សក៏ប្រកាសផ្តាច់បុត្រី លែងឲ្យក្ងោកនោះទៅវិញ ៗ ក្ងោកអភ័ព្វ ត្រូវត្រឡប់ទៅទីលំនៅវិញទាំងអាម៉ាសមុខ ៗ

កុណាវកវគ្គ

# ៣៣- ជ្រូកឈ្មោះរាជសីហ៍

ហៃជ្រូកគះម្រូកប្រឡាក់អាចម៍ សាយក្លិនស្អុយផ្តាច់ហួសវិស័យ
បើអ្នកចង់ច្បាំងតាំងតដៃ យើងសូមជូនជ័យទៅអ្នកចុះ ។

រាជសីហ៍មួយ ដើរចុះទៅផឹកទឹកក្នុងស្រះ ដួនជាឆាកទៅឃើញជ្រូកស្លាវមួយយ៉ាងធាត់ធំកំពុងដើរចុះទៅពីក្រោយដែរ ក៏គិតថា ថ្ងៃនេះអញចាប់ម្រឹគបានស៊ីសាច់ឆ្អែតណាស់ទៅហើយ ចាំថ្ងៃក្រោយចុះ សឹមអញនឹងមកចាប់ជ្រូកនេះស៊ី ។ គិតហើយ រាជសីហ៍ ក៏ដើរសរសៀរអំ-ពីស្រះទៅតាមផ្លូវម្ខាងវិញ ដើម្បីកុំឲ្យជ្រូកគិតភ័យរអើលខ្លាច ក្រែងថ្ងៃក្រោយក៏ពុំហ៊ានមកទីនោះទៀត ។ ឯជ្រូកវិញ ឃើញកិរិយារាជសីហ៍ដូច្នោះ ក៏យល់ថា អៃយ៉ា ! រាជសីហ៍កំសាកនេះ ខ្លាចអញទេតើ ! បានជាគេចវេះខ្លួនមិនឲ្យជួបមុខអញ , ថ្ងៃនេះ គួរតែអញគម្រាមថែម ឲ្យរាជ-សីហ៍នេះរឹតតែរអាខ្លាចទៅទៀត ។ គិតរួច ជ្រូកកម្មៅ ក៏ងើបក្បាលអួតដាក់រាជសីហ៍ បញ្ចេញអាការៈប្រុងប្រៀបនឹងប្រយុទ្ធ ដោយសម្តីក្អេងក្អាងថា អឺ ! សំឡាញ់ ! យើងជាសត្វជើងបួន , សំឡាញ់ឯងក៏ជាសត្វជើងបួនដែរ , មក ! ចូរបកមកវិញ ! ហេតុអ្វីបានជាប្រញាប់ភ័យគេចខ្លួនម្ល៉េះ? ។ រាជសីហ៍ឆ្លើយថា ណ្ហើយចុះជ្រូកអើយ! ថ្ងៃនេះ យើងពុំធ្វើសង្គ្រាមនឹងអ្នកទេ , ចាំដល់ប្រាំពីរថ្ងៃទៀត យើងនឹងមកធ្វើសង្គ្រាមតទល់នឹងសំឡាញ់ឯងត្រង់កន្លែងនេះ, ចូរសំឡាញ់ឯងមកកុំខាន ។ និ-យាយរួច រាជសីហ៍ក៏ដើរចេញទៅ ។

ជ្រូកល្ងង់ ឃើញរាជសីហ៍ពុំហ៊ានតទល់ មានសេចក្តីកែកយណាស់ ហើយគិតទន្ទឹងថា នៅតែប្រាំពីរថ្ងៃទៀតទេ អញនឹងបានធ្វើសង្គ្រាមយ៉ាងក្លាហានជាមួយនឹងរាជសីហ៍ ឲ្យដឹងថ្មីដៃម្តង ។ កាលទៅ

ជួបជុំគ្នា ជ្រូកនោះក៏ញញឹមញញែមប្រាប់តាមព្រឹត្តិការណ៍ដល់ពួកញាតិមិត្រ ៗ ឯពួកជ្រូកជាញាតិមិត្រវិញ គ្រាន់តែឮជ្រូកនោះប្រាប់ ក៏នាំគ្នាកើតភ័យញ័ររន្ធត់ ស្តីបន្ទោសថា គាត់ឯង មកធ្វើឲ្យពួកយើងវិនាសហិន-ហោចជាន់នេះហើយ ! គាត់ឯងភ្លើណាស់ ពុំស្គាល់កម្លាំងខ្លួន ហ៊ានទៅចង់ធ្វើសង្គ្រាមជាមួយនឹងរាជសីហ៍ , រាជសីហ៍ មុខជានឹងមកផ្តាច់ផ្តិលជីវិតយើងនេះអស់គ្មានសល់ ពុំខានឡើយ, វរហើយគាត់ឯង! មិនសមទៅធ្វើអំពើសហ័សអីចឹងសោះ! ៗ ជ្រូកនោះ ឮគេបំភ័យ ក៏តក់ស្លុតរន្ធត់ចិត្ត សួរទៅពួកញាតិមិត្រវិញថា បើយ៉ាងហ្នឹង, ឥឡូវនេះ ឲ្យខ្ញុំគិតធ្វើយ៉ាងម៉េចទៅវិញ? ៗ ជ្រូកទាំងឡាយ ក៏ជួយឲ្យយោបល់សម្រាប់កែខៃដោះជីវិតថា ចូរសំឡាញ់ឯងទៅឯបន្ទប់របស់ពួកតាបស ដែលនៅអាស្រមជិតនុ៎ះ ហើយត្រូវដេកត្រាំនរទៀលខ្លួននឹងអាចម៍ឲ្យប្រឡាក់សព្វរួចទៅឈរហាលខ្លួនឲ្យស្ងួត រៀងរាល់ថ្ងៃ ដរាបគ្រប់ប្រាំពីរថ្ងៃ, លុះដល់ថ្ងៃទីប្រាំពីរ ត្រូវទៅប្រមៀលខ្លួននឹងទឹកសន្សើម ឲ្យទទឹករីកណាមក ហើយទៅឈរនៅខាងដើមខ្យល់ ត្រង់កន្លែងដែលណាត់គ្នាធ្វើសង្គ្រាម ឲ្យបានមុនពេលរាជសីហ៍មកដល់, រាជសីហ៍ ជាពូជសត្វស្អាត កាលបើធុំក្លិនស្អុយគគ្រុកពីសរីរៈអ្នកហើយ មុខជាឲ្យជ័យជម្នះដល់អ្នកពុំខាន ៗ ជ្រូកកម្សត់ ក៏សុខចិត្តទៅធ្វើតាមពាក្យញាតិមិត្រ គ្រប់ទាំងប្រាំពីរថ្ងៃ ហើយទៅឈរចាំរាជសីហ៍ នៅខាងដើមខ្យល់ ត្រង់កន្លែងដែលណាត់គ្នានោះ ៗ

ឯគជសីហ៍ មកដល់ គ្រាន់តែធុំក្លិនស្អុយអសោចអំពីសរីរៈជ្រូក ក៏ដឹងថា "ជ្រូកប្រឡាក់អាចម៍" ទើបនិយាយទៅកាន់ជ្រូកថា "ហៃបងជ្រូកសំឡាញ់អើយ ! បងឯងបេះរកលេសល្អណាស់, ប្រសិនបើបងឯងកុំតែប្រឡាក់លាមក ម៉្លេះសមបងឯងក្ស័យជីវិតរលត់សង្ខារ ក្នុងទីនេះឯងពុំខាន, ប៉ុន្តែ ឥឡូវនេះ យើងសូមចុះចាញ់បងឯងហើយ ព្រោះយើងពុំអាចនឹងយកមាត់ទៅខាំ យកជើងទៅទះឲ្យប៉ះនឹងសរីរៈដ៏អសោចរបស់បងឯងបានទេ, យើងសូមឲ្យបងឯងទទួលយកជ័យជម្នះទៅចុះ" ។ និយាយតែប៉ុណ្ណោះ គជសីហ៍ ក៏ដើរចេញពីទីនោះបាត់ទៅ ។ ជ្រូកកម្ទៅនោះក្តី ពួកជ្រូកជាញាតិមិត្រក្តី មានសេចក្តីត្រេកអរណាស់ ប៉ុន្តែដោយគិតខ្លាចក្រែងគជសីហ៍នឹងវិលត្រឡប់មកធ្វើឲ្យអន្តរាយវិញ ក្នុងថ្ងៃណាមួយទៀត ទើបនាំគ្នាលើកគ្រប់គ្រួ ជំលៀសចេញទៅនៅទីដទៃផ្សេងទៀត ហើយនៅជាសុខសាន្តរៀងមក ។

ទទ្ហវិត្ត

-ចប់-

"រឿងខ្លី ៗ មានន័យវែង" នេះ មានបោះពុម្ពរួមគ្នាជាសៀវភៅមួយហើយ ។

# ការសង្កេត-ស្រាវជ្រាវចំពោះរឿងវរវង្សសូរវង្ស

## ១- អំពីអ្នកនិពន្ធ និង កាលបរិច្ឆេទ.–

រឿង **វរវង្ស សូរវង្ស** នេះ ជារឿងល្បីល្បាញ ក្នុងអក្សរសាស្ត្រខ្មែរសម័យបុរាណ ។ យើងស្តាយជាបំផុត ព្រោះច្បាប់ដើមទាំងប៉ុន្មានដែលយើងរកឃើញ ពុំមានដាក់ឈ្មោះអ្នកនិពន្ធសោះ ប៉ុន្តែយើងសង្កេតបានថា អ្នកនិពន្ធនេះ មិនមែនជាដៃថ្មីទេ ពិតជាមានការពិសោធន៍ច្រើន ការសរសេរពាក្យកាព្យ និងការតាក់តែងជារឿង ៗ បានជាហ៊ានសន្និដ្ឋានដូច្នេះ ព្រោះពិនិត្យឃើញ សម្រស់ពាក្យពេចន៍, សំនួនវោហារ និងល្បិចតែងរឿងជាសិល្បវិធីនោះ ពុំចាញ់ពុំថយជាងរឿងដទៃទៀតដូចជា ជិនវង្ស, លក្ខណវង្ស, សង្ខសិល្បជ័យ ដែលជារឿងល្បី ៗ នោះឡើយ ។

ចំណែកកាលបរិច្ឆេទ ដែលតែងរឿងនេះសោត ក៏គ្មានចារឹកទុកសោះ ជាហេតុនាំឲ្យពិបាកស្រាវជ្រាវរកអ្នកនិពន្ធនោះផង និងពិបាកកំណត់អាយុកាលនៃអត្ថបទនេះឲ្យបានច្បាស់ផង ។ បើដូច្នេះ យើងមានវិធីតែមួយទេ ដែលអាចវាស់ប្រមាណ ឃើញអាយុកាលនៃអត្ថបទរឿងនេះ គឺការធៀបប្រៀបនូវពាក្យពេចន៍-ឃ្លោងឃ្លា សិល្បវិធី ដែលអ្នកនិពន្ធប្រើក្នុងរឿងនេះ ។ តាមវិធីធៀបប្រៀបវាស់ប្រមាណនេះ

នាំឲ្យយើងយល់ថា រឿងនេះឯង តែងឡើងក្នុងរវាងសតវត្សទី ១៩ ភាគខាងចុង គឺជិតមកដល់សតវត្សទី ២០ យើងនេះ ព្រោះតែពាក្យសម្ដីយើងស្ដាប់បានឆាយ ប្រហាក់ប្រហែលតែសម្ដីយើងសព្វថ្ងៃ ។ ឯរបៀបតែងសោតក៏ប្រហាក់ប្រហែលនឹងរឿងជាច្រើនទៀត ដែលយើងធ្លាប់ស្គាល់ច្បាស់កាលបរិច្ឆេទ ដូចរឿង ជិនវង្ស,លក្ខណវង្ស ។ល។

ដូច្នេះ នាមអ្នកនិពន្ធ យើងរកមិនឃើញទេ គ្រាន់តែដឹងថា ជាស្នាដៃរបស់អ្នកកវីមានការពិសោធន៍ម្នាក់ ដែលគាត់តែងឡើងក្នុងរវាងខាងចុងសតវត្សទី ១៩ ។

២- អំពីប្រភពដើមនៃរឿង.—

សេចក្ដីបញ្ជាក់ពីប្រភពរឿងនេះ មានច្រើនផ្នែកដូចតទៅ ៖

ក.) តាមសេចក្ដីផ្ដើមនៃអត្ថបទរឿងនេះ បានបញ្ជាក់ថា " ជារឿងជាតក " ដែលនិទានពីព្រះពោធិសត្វត្រាច់រង្គាត់ក្នុងវដ្ដសង្សារកសាងប្រមែប្រមូលនូវបារមីជាពោធិសម្ភារ សម្រាប់ជាការត្រាស់ដឹង ដូចជាមានកាព្យមួយវគ្គថា :

" . . . ខ្ញុំនិទានថ្លែង ដំណើរដំណែង ពីព្រះភគវា
កាលនៅពោធិ- សត្វសេសណា សាងបារមីតា
លះលែងបាបបង់ ។

តេជតេជៈអញ    លំអុតលំតេញ    ត្រេកចិន្តាផ្គង់

ត្រិះត្រាបសរសើរ    ដំណើរព្រះអង្គ    កាលពុំទាន់ទ្រង់

បារមីញេយ្យញាណ    ។ . . .”

ដែលមានប្រែថា ៖ សេចក្តីនេះដំណាលឡើងវិញ នូវរឿងរ៉ាវរបស់ព្រះពុទ្ធ ដែលកាលនៅជាពោធិសត្វនៅឡើយ កំពុងតែខំកសាងបារមី ពុំទាន់បានត្រាស់ ។

បើនិយមតាមន័យនេះ ឃើញថាមានសេចក្តីបញ្ជាក់ថា ជារឿងជាតកហើយ ។ យើងនៅតែទទូចរកតាមដានទៅទៀតថា តើជាតកនេះជាជាតកប្រភេទណា ព្រោះថាបណ្តារឿងជាតកនោះ លោកអ្នកប្រាជ្ញបូរាណបានចងក្រងដោយឡែក ៗ ពីគ្នា ដែលអ្នកសិក្សាស្រាវជ្រាវសម្គាល់ឈ្មោះមួយពួក ៗ ដោយខ្លួន ៗ ពីគ្នាទៅទៀត ដូចជាទស-ជាតក បញ្ញាសជាតក ជាតកអដ្ឋកថា ឬ ៥០០ ជាតក ជាដើម ។

១ ) ប៉ុន្តែ ក្នុងសៀវភៅប្រជុំរឿងព្រេងខ្មែរភាគទី ៦ ដែលបោះពុម្ពផ្សាយពីពុទ្ធសាសនបណ្ឌិត្យ ត្រង់ទំព័រ១១១-១១២ បានបញ្ជាក់សេចក្តីថា “រឿងវរវង្សសូរវង្ស ជារឿងព្រេងខ្មែរ ប្រចាំនៅភូមិភាគមួយដែលលាតសន្ធឹងយ៉ាងវែងកាត់ខេត្តកំពង់ស្ពឺ កោះកុង និងជាយម្ខាងដល់ទៅខេត្តពោធិសាត់ ។ អ្នកស្រុកចាស់ ៗ នៅហៅភ្នំនេះថា ភ្នំវរវង្សសូរវង្ស ជាប់រហូតមក” ។ មិនតែប៉ុណ្ណោះ សៀវភៅដដែល បានបញ្ជាក់ខាង

ចុងរឿង ត្រង់ទំព័រ ១៦៦-១៦៧ ថា "អ្នកស្រុកនៅតែជឿថា រឿងនេះពិតជារឿងព្រេងប្រចាំភូមិភាគនេះមែន ព្រោះសំអាងទៅលើរូបអ្នកតាស្រីកំបុតក្បាលនៅភូមិចំបក់ (ក្នុងសង្កាត់ស្វាយតក្រុងគិរីរម្យ) សម្គាល់ថាជារូបនាងមិនាដែលគេផ្ដន្ទាទោសកាប់កចោល ។ កំពូលភ្នំមួយហៅកម្ទ-ជ្ឈាក ថាជាកន្លែងខ្យល់កួចផ្ដាច់ក្បាលឥសីដែលលួចកែវរបស់រាវង្ស និងកន្លែងមួយទៀតជាកន្លែងមាត់សមុទ្រដែលបាំងនាងកេសកេសីរង់ចាំប្ដី ហៅជាថ្មបាំង (សព្វថ្ងៃចូលក្នុងខេត្តកោះកុង) ។ល។

បើតាមសេចក្ដីបញ្ជាក់ទាំងនេះ រឿងរាវង្សសូរវង្ស ទៅជារឿងប្រចាំស្រុកខ្មែរយើងពីបុរាណមកអង្វែងហើយ ។

គ-) តាមយោបល់អ្នកស្រាវជ្រាវជាតិបារាំងសែស ឈ្មោះប៉ាវី បានសរសេរទុកក្នុងសៀវភៅ(១)របស់លោកថា ៖

ក្នុងឆ្នាំ ១៨៩០ លោបានធ្វើដំណើរទៅភូមិភាគជួរភ្នំដែលឃាតឆ្ងាយពីទន្លេមេគង្គ ហើយលោកសន្ទឹងទៅដល់ឈូងសមុទ្រសៀម វេលាយប់មួយ លោកបានស្ដាប់អ្នកស្រុកនិទានរឿងរាវង្សសូរវង្សព្រមទាំងបានជូនលោកទៅមើលដល់ទីកន្លែង ដែលកើតហេតុក្នុងរឿងនេះផង ដូចជារូបសំណាកនាងមិនា, ទីកន្លែងកប់ខ្មោចនាងមន្ទា ដែលមានផែនថ្មស្រោប

---

១- Mission Pavie, Etudes diverses Tome 1 : Recherches sur la littérature du Cambodge, du Laos et du Siam; Paris, Ernest Leroux éditeur, 1898, pp. 30-41.

បិទបាំង ។ល។

លោកប៉ារី បានតាំងចម្លងយកសាស្ត្រានេះមួយចប់ ទៅបោះពុម្ពជាអក្សរខ្មែរ និងសេចក្ដីប្រែជាភាសាបារាំង ក្នុងសៀវភៅនោះជាបទសិក្សាស្រាវជ្រាវរបស់លោកទៀតផង ។

ឃ. តាមលោក សូឡង់ ប៊ែរណា ធៀរី(១) ជាសមាជិកសាលាបារាំងសែសនៅចុងបូព៌ាប្រទេស បានសរសេរអត្ថបទមួយ ស្ដីពីអក្សរសាស្ត្រខ្មែរ លោកបានចុះយោបល់មួយថា:

"ដោយសារមានរឿងរ៉ាវកថារបស់ឥណ្ឌា ចូលមកកាន់ស្រុកខ្មែរ រឿងព្រេងប្រពៃណីខ្មែរ ក៏ក្លាយខ្លួនទៅតាមបែបឥណ្ឌាអស់ទៅ តាំងដំណើររឿងតាំងចំណងជើង ដូចជា រឿងវរវង្សសូរវង្ស ជាដើម" ។

យោបល់នេះ ជាសំយោគ គឺផ្សំគំនិតពីរផ្សេងគ្នាខាងលើនេះ បានន័យថា រឿងវរវង្សសូរវង្ស ជារឿងព្រេងខ្មែរ ប៉ុន្តែបំភ្លៃទៅតាមបែបបទរឿងឥណ្ឌា ដែលតួអង្គជាអវតារនៃវិស្ណុ ឬអង្គពោធិសត្វ ក្នុងបណ្ដារឿងជាតក ដែលនិយមលើកយកទ្រឹស្ដីកម្ម-ផល ធ្វើជាគោលធំ ។

### ៣– អំពីគោលគំនិត និង គោលវិធីនៃរឿង:

អំពីគោលគំនិតធំក្នុងរឿង ប្រហាក់ប្រហែលទៅនឹងរឿងជាតក

១- Solange Bernard-Thierry, France-Asie Numéro spécial, Présence du Cambodge, Nov.-Déc. 1955. P. 447.

នានាដែរ ព្រោះបានលើកយកកម្មផល ព្រមទាំងវៀរវេរយកមកបង្ហាញឲ្យជាក់ស្តែង ។ ឯគោលវិធីវិញ ឃើញមានលើកយកបញ្ហាវិបត្តិទំនាស់ក្នុងគ្រួសារ រវាងប្រពន្ធដើមប្រពន្ធចុង កូនដើមម្តាយចុង ដែលជាបញ្ហាដែលគេធ្លាប់ឃើញមានមែនទែនក្នុងសង្គមនីមួយ ៗ ។ ចំពោះការក្លួចក្លាំងការបញ្ចើចបញ្ចើរ ឬ សេចក្តីក្រេវក្រោធខុសរឿងខ្វះវិចារណញ្ញាណរបស់ស្តេច ក៏មានលើកយកមកពោលយ៉ាងច្បាស់ណាស់ដែរ ដូចជាស្តេចវៃវង្ស បិតាវរវង្សសូរវង្ស ។ ឯចិត្តមានះប្រទូស្តរាយចងអាឃាតព្យាបាទគ្នាក៏មានពន្យល់ច្បាស់ដែរ លើរូបតួអង្គនាងមន្ទា ឬ នាងម៉ិនា ។ ចំណែកអ្នកកាន់សីលសិក្ខា មិនបានហ្មត់ចត់នោះក៏មាននិយាយដែរ គឺទៅលើតួអង្គឫសី . . . ។ តពីនេះទាំងនិយាយអំពីស្នេហាបរិសុទ្ធ ដែលជាលំអក្នុងរឿងប្រលោមលោកបែបពុទ្ធនិយមផង និងជាគោលបំណងនៃអ្នកអក្សរសាស្ត្រទូទៅ ដើម្បីបណ្តុះសុភមង្គលបរិសុទ្ធក្នុងគ្រួសារ ដែលទុកជាតម្លៃពិសេស ឧទាហរណ៍គឺតួអង្គវរវង្សនិងសូរវង្ស តួអង្គវរវង្សនិងនាងកេសកេសី ។ល។

## សេចក្តីសន្និដ្ឋាន

រួមសេចក្តីទៅ រឿងវរវង្សសូរវង្ស ជាមត៌កអក្សរធម៌ដើមរបស់ខ្មែរមុនពេលដែលអក្សរធម៌លទ្ធិព្រាហ្មណ៍ ឬ ពុទ្ធសាសនាចូលមកកាន់ប្រទេសយើង ឯនោះទៅទៀត ។ ដូច្នេះ គឺជាកេរ្តិ៍នៃអក្សរធម៌របស់ជនជាតិអ្នក

ស្រុកដើមបានបង្កើតឡើង ដែលអ្នកស្រាវជ្រាវសព្វថ្ងៃឲ្យឈ្មោះថា " អារ្យធម៌មន-ខ្មែរ "

ហេតុដែលនាំឲ្យយើងបញ្ជាក់ថា រឿងនេះជាអក្សរសាស្ត្រ មន-ខ្មែរ ដូច្នេះមកពីមានសំអាងច្រើនយ៉ាងល្មមទុកជាការបានដូចជា៖

១- រឿងនេះ មានដំណើររឿងស្របតាមសង្គមខ្មែរ គឺមានជំនឿ មានការប្រតិបត្តិក្នុងគ្រួសារ ក្នុងសន្ទាប់ឋានៈមនុស្ស ។

២- មានអ្នកស្រុក នៅចាំច្បាស់នៅឡើយ ថាជារឿងព្រេងប្រចាំភូមិស្រុកពិតប្រាកដរបស់ខ្មែរយើង ថែមទាំងចង្អុលកន្លែង រូបសំណាកកិនភាគស្រុកជាភស្តុតាងទៀតផង ។

៣- គ្មានឃើញឈ្មោះរឿង ឬឈ្មោះតួអង្គទាំងនេះ នៅក្នុងជាតកណាមួយសោះ តោះក្នុងទសជាតកក្តី បញ្ញាសជាតកក្តី ឬអដ្ឋកថាពង្សក្តី ។

៤- មកពីធ្លាប់ឃើញថា មានអ្នកប្រាជ្ញបេះបាលីច្រើនណាស់ ធ្លាប់កាឡៃរឿងព្រេងក្នុងប្រទេសពិត ៗ ទៅជារឿងជាតក ហើយយកទៅបញ្ចូលក្នុងបញ្ញាសជាតកផង ដូចជារឿងនាងកង្រី (រឿងព្រេងនៅកំពង់ឆ្នាំង) រឿងសុវត្ថិ ក្នុងប្រពៃណីជនជាតិថៃនៅប្រទេសចិន ទៅជារឿងព្រះសុធននាងកែវមនោហរ , . . . ជាដើម ។

ដូច្នេះ រឿងវរវង្សសូរវង្ស ក៏មានកំណើតពិតនៅក្នុងស្រុកខ្មែរ គ្រាន់តែអ្នកចេះបាលី យកទៅតុបតែងបន្ថែជារឿងពោធិសត្វ (Bouddhisé) មានគន្ថជាភាសាបាលីលាយឡំ ព្រមទាំងថែមថយសាច់រឿងតាមបែបជាតកតែប៉ុណ្ណោះ ។ ប្រហែលជាមកពីការឲ្យរបស់ដើមគេដូច្នេះទេដឹង បានជាអ្នកនិពន្ធនេះមិនដាក់ឈ្មោះ ?

លី - ធាមតេង

អ្នកស្រាវជ្រាវនៅពុទ្ធសាសនបណ្ឌិត្យ

# រឿង ចរចេញ-សូរចេញ

(ចម្លងពីសាស្ត្រាស្លឹករឹត)

លោក លី-ធាមតេង ស្រាវជ្រាវ-ពិនិត្យផ្ទៀងផ្ទាត់

---

## បទកាកគតិ

៙ អញខ្ញុំទូនអគ្គ  វរវន្ទាទ្រង់  តាំងទសករកាយ(១)
ជុំជិតដាក់ដល់  មណ្ឌលសិរសាយ  លើកលុតថ្វាត់ថ្វាយ
ក្រួញក្រាបត្រឹកត្រង់(២) ។
សរសើរសម្ភារ  គតកុលវេហាស៍  រីករុងរឿងរុង
ការកេត្រាត្រាប់  សំពៅជហ្មត់ហ្មង  ផ្ទល់ផ្ទុកផ្កាស់ថ្កង
សត្វសែនសំខ្យា ។
គម្ពីរជ្រាលជ្រៅ  បើកចាត់ទៀងទៅ  ត្រាប់ត្រង់សួគ៌ា
ជុនដោមដាក់ដល់  មណ្ឌលនាយណា  និព្វានហៅមហា
កុសលកន្ទង ។
រីព្រះធម៌ធារ  ខ្ពង់ខ្ពស់ក្រាសក្រាល  នានាំសត្វផង
រីព្រះសង្ឃសុទ្ធ  ព្រឹទ្ធព្រតម៉ត់ហ្មង  ជាស្ពានចម្លង
សព្វសត្វនិករ ។

---

១- សាស្ត្រាខ្លះថា "ទើបតាំងទសកាយ" ។ ២- ត្រឹកត្រង់ : ដំបូន្មានដែលគួរគោរព ។

ទើបទុនអភិ- វាទវរវន្ទីយ៍ ព្រះសង្ឃសុន្ទរ
ស្មឹងស្មាធិអស់អញ អារញ្ញសុករ ជ្រោមជ្រែងសាទរ
ពាក្យពេចន៍វាចា ៗ

ខ្ញុំនិទានថ្លែង ដំណើរដំណែង ពីព្រះភគវា
កាលនៅពោធិ សត្វវិសេសណា សាងបារមីតា
លះលែងបាបបង់ ៗ

តេជតេជៈអញ លំអុតលំគេញ ត្រេកបន្តាផ្គង់
ត្រិះត្រាប់សរសើរ ដំណើរព្រះអង្គ កាលពុំទាន់ទ្រង់
បារមីញាណញេយ្យ ៗ

អញខ្ញុំសូមពរ ទេពតាំងនិករ សុខសួគ៌ាល័យ
នៅតាំងទិសទស សោឡសព្រហ្មនៃ ខ្ពង់ខ្ពស់ក្រាស់ក្រៃ
សុខសួគ៌ថ្ងៃថ្លា ៗ

ទោះខុសគាប់ក្តី បើកបទបាលី លើសលោះកាព្យ
ឆ្គាំឆ្គងពាក្យពេចន៍ ពុំស្របក្តីណា ពុំពិរោះថា
លែងច្បាប់វិស័យ ៗ

ទោះអ្នកឯណា ចេះចងកាព្យ ប្រុះប្រាជ្ញញាណញេយ្យ
សូមជួយតម្រង់ ផ្ចិតផ្ចង់ហឫទ័យ ឲ្យល្អមពាក្យពី-
រោះរាបរាប ៗ

កាលអង្វែងលង់ មានក្សត្រមួយទ្រង់ នាមនៃពជា
ហៅឈ្មោះព្រះបាទ វង្សជាតិសុរិយា ស្ដែងស្ដេចនៅនា
ក្រុងនគរ ៗ
ស្ដេចមានមហេសី ឆោមឆាយហាក់ស្រី ទិព្វទេពអប្សរ
ស្រស់ស្រេចអស់អង្គ ទ្រើសទ្រង់នាមករ នាងនាថបវរ
ទេពីវង្សបុប្ផា ៗ
នាងនាថយល់សប្ដ ត្រកាលតាំងគ្រប់ អស្ចារ្យមហិមា
យល់ដូចតាបស សប្បុរសក្ដាត់ណា ហោះពីសួគ៌ា
តុសិតថ្វាថ្វៃ ៗ
កាន់កែវមួយនោះ ស្មើក្ដីប្រុះ ថ្លាស់ធ្លុះប្រពៃ
ចូមហុចឲ្យនាង នាថអរពេកក្រៃ ទទួលហើយនៃ
ឫសីថ្វៃងប្រាប់ ៗ
នាងអើយកែវនេះ ស្មើល្អម្ល៉េះ លោកពុំដែលរាប់
សិងមានតម្លៃ ថ្លៃក្រៃទឹងទ្រព្យ កាត់ថ្លៃដោយច្បាប់
នគរមួយបាន ៗ
កែវមួយនាងអើយ ល្អឥតផ្ទឹមឡើយ ថ្លៃក្រប្រមាណ
នគរនីទេស សោឡសសួគ៌ស្ថាន ផ្ទឹមស្មើពុំបាន
ថ្លៃឥតគណនា ៗ

ថាបើនាងចង់ អញ្ជើញនាងទ្រង់ រក្សាសីលា
អញនឹងឲ្យនាង ដូចនាងប្រាថ្នា តាំងពីឯងណា
ឥឡូវនេះម្តង ៗ

ឫសីសីលា ករកាន់កែវជា ហុចមកទៀតហោង
នាងអរទទួល ស្រាកស្រួលឥតហ្មង ឫសីហោះផ្សង
វិលវិញស្ថានស្ថិត ៗ

នាងនាថវង្សត្យា នាងបានកែវជា តាំងពីរដូចចិត្ត
នាងបួមដាក់ដល់ មណ្ឌលសិរសិត ស្រឡាញ់ស្នេហ៍ស្និទ្ធ
ឥតឯគណនា ៗ

នាងនាថក្សត្រី នាងភ្ញាក់ឡើងពី បន្ទំនិទ្រា
នាងសោយព្រះស្ងួន ជម្រះកាត្វា ទើបនាងយាត្រា
ទៅទូលក្សត្រថ្លៃ ៗ

មហាក្សត្រស្តេចស្តាប់ នាងនាថថ្លែងប្រាប់ សព្វគ្រប់ប្រពៃ
មានព្រះអំណរ សាទរពេកក្រៃ ត្រេកអរហឫទ័យ
ឥតឯផ្ទឹមបាន ៗ

ទើបស្តេចទាយថា វិសប្តិនេះណា អស្ចារ្យមែនមាន
បើដោយតំនិត អញគិតរិះឲ្យាន សមយើងនឹងបាន
បុត្រពីរអង្គា ៗ

តែអង្គបុត្រនោះ ព្រាញព្រាណប្រុស មែនមានចេស្តា
ដូចយើងបំណន់ ប៉ុនប៉ងព្រាថ្នា ពុំឃ្លាតឡើយណា
បានដូចបំណន់ ។

ពីកាលនាងបាន យល់សប្តិ៍នាងមាន គភ៌ស្រេចឯងហោង
សម្តេចក្សត្រា រក្សាស្ងួនគ្រង ពុំឲ្យមានហ្មង
នៃនាងនោះឡើយ ។

លុះអម្ពុងជា ទៀងទសមាសា គភ៌នាងល្មមហើយ
ស្រេចនាងប្រសូត កជបុត្រជាត្រើយ ពិតពុំលង់ឡើយ
ប្រសូតហោងណា ។

ហេតុទេពនិមន្ត មកយកបដិសន្ធិ៍(១) ជាបុត្រក្សត្រា
តែឆាមឆាយស្រស់ស្រី ប្រិមប្រិយសោភា បម្រើនជន្មា
ឆ្នាំមួយកន្លង ។

ទើបទេវបុត្ត ប្អូនមិញប្បុត ចុះចាកសួគ៌ហោង
មកយកបដិ- សន្ធិដូចផ្គង ដួចចូលនឹងបង
រួមឯកឧទរ ។

---

១- អានថា "បដិសន់" ។

ប្អូននោះឯងណា　គឺអង្គឥន្ទ្រា　ព្រហ្មានាជករ
គឺអង្គសម្តេច　សរពេជ្របវរ　ចិត្តស្មគ្រស្មោះសរ
　សេពសាន្តបារមី　ៗ

ដល់ដប់ខែហើយ　ពិតពុំលង់ឡើយ　គភិពជក្សត្រី
ប្រសូតកពជបុត្រ　បរិសុទ្ធក្សប្រើយ　គឺអង្គពោធិ-
　សត្វលោកឧត្តម　ៗ

ហេតុពុទ្ធង្កុរ　ពន្ទកបន្ទូល　ស្តេចអាចសខ្យំ
សែបសាន្តក្រវែទ　ចម្រើនបុណ្យបំ-　ពេញកិខស្រ្កមណ៍
　ក្រឹត្យពុទ្ធញេយ្យញាណ　ៗ

ឆោមឆាយប្រពៃ　ស្រស់ល្អលើសក្រៃ　ឥតឯផ្ទឹមបាន
ព្រះវរបិតា　ករុណាកេរ្យមក្យាន្ត　រួមក្សប្រាណ
　បុត្រពីរអង្គា　ៗ

សម្តេចព្រះវរ　បិតាសាទរ　ឲ្យព្រះនាមា
បុត្រច្បងព្រះអង្គ　ទ្រើសទ្រង់ហៅជា　ហៅសូរវង្សា
　នាមនៃប្រាកដ　ៗ

រីឯអណុជា　ព្រះវរបិតា　សែ្តងស្តេចសន្មត
ឲ្យព្រះនាមករ　បវរកំណត់　ឲ្យហៅប្រាកដ
　ហៅវរវង្សា　ៗ

អស់មុខមន្ត្រី សេនាបតី រដ្ឋរាស្ត្រប្រជា
សោកសឹងមិត្តមូល អនុកូលស្នេហា ស្រឡាញ់ស្ងួនភ្ងា
រាជបុត្រពីរពង្ស ៗ

លំដាប់នោះណា នាងនាថមន្ទា ទេពីដួចទ្រង់
គភ៌ព្រះរាជបុត្រ បរិសុទ្ធវង្ស សមសួនតួជពង្ស
អម្ពរមហាក្សត្រ ៗ

ដល់ដប់ខែហើយ ពិតពុំលង់ឡើយ ប្រសូតបុត្ររតន៍
ព្រះវរបិតា ករុណាប្រតិពទ្ធ ឲ្យនាមប្រសិទ្ធ
បុត្រពៅពុំផា ៗ

រីឯនាមឈ្មោះ រាជកុមារនោះ ហៅវៃវង្សា
ចម្រើនអាយុ លុះប្រាំឆ្នាំណា ព្រះជនកក្សត្រា
ពេញព្រះហឫទ័យ ៗ

ត្បិតបានរាជបុត្រ ទាំងបីប្រាកដ សឹងប្រាណប្រុសថ្លៃ
ប្រដាប់គ្រឿងលេង បរិទ្ធសព្វថ្ងៃ ពេញព្រះហឫទ័យ
គគងមានហ្នង ៗ

រំនាងមន្ទា ហេតុបិត្តបុស្សា ទ្រុះទ្រឹស្ដឃ្មើសឃ្មង
ពុំឲ្យគេមាន ពីរប្រាណលេង ខឹងក្រែកន្ទង
ចិត្តបង់ប្រកួត ៗ

នាងមន្ទាគិត　　រិះឯងក្នុងចិត្ត　　ផាលផល់ស្ងប់ស្ងួត
រិះហើយវិលយល់　　វិលខ្វល់តែត្រួត　　ហាក់ដូចគេឆ្កួត
ផាលផល់ថប់ថា　　។

រីចៅចាំងពីរ　　ស្អែកហើយចំណោរ　　អន្លែងទៅណា
ដណ្តើមសម្បត្តិ　　ភដរដ្ឋរដ្ឋា　　កូនអញឥតគ្នា
កំដរជាគូ　　។

បងប្អូនគេមាន　　ប្រាប់ទឹងគេបាន　　នាកាលឥឡូវ
ខ្វះប្រាំងខ្វះតែង　　តំណែងពលព្យូហ៍　　ដឹកស្រះដឹកគូ
ប្រាំងផងបានឡើយ　　។

គួរគេកលគាប់　　ឲ្យបានសម្លាប់　　ពីតូចឲ្យហើយ
បើស្លាប់ចាំងពីរ　　ចំណោរឥតត្រើយ　　អញមិនគិតឡើយ
ស្រាន្តស្រាកហឫទ័យ　　។

កាលនោះចៅសូរ-　　វង្សាអម្បូរ　　ពូជពង្សក្សត្រថ្ងៃ
ចម្រើនធំឡើង　　ប្រាំពីរឆ្នាំនៃ　　ចៅវរវង្សថ្ងៃ
ប្រាំមួយឆ្នាំហោង　　។

ដើរទៅរកលេង　　ទឹងបងប្អូនឯង　　ចាំងពីរស្នេហ៍ស្និទ្ធ
នាងមន្ទាយល់　　អរសល់កន្ទួង　　ស្រែកហៅទងវង
អង្គរអភិប្រាយ　　។

ហៅទៅវរវង្ស សួរវង្សកំបង់ មកក៏កូនម្ដាយ
ម្ដាយតែងទទួន មើលផ្លូវអ្នកកាយ អញ្ជើញមកអាយ
ម្ដាយនឹងជេបអ្នក ។

កុមារទាំងពីរ ស្ដាប់ហើយមើល លង់លុះភ្ញាក់
នាងមន្ទាហៅ ឈោមទៅឥតអាក់ អៀនទុទឯងដាក់
មុខហើយចូលទៅ ។

នាងមន្ទាឱប ថ្នាក់ថ្នមក្រសោប តៀតដាក់ក្នុងក្ដៅ
គៀបខ្លាប់ទាំងពីរ ហើយស្រែកហៅពើ អាក្រោសថាចៅ
ទាំងពីរនេះណា ។

យកគ្នាបាប់អញ អញពុំស្រឡាញ់ អញជាមាតា
ប្រពន្ធពុក លោកដែលយកគ្នា ប្រួតបាប់អញណា
អ្នកកើយជួយអញ ។

បពិត្រក្សត្រា វង្សជាតិសុរិយា ព្រះអង្គស្រឡាញ់
អាសួរមិញតើ ម្ដេចអ្នកស្អប់វិញ អ្នកមកបំពេញ
ឲ្យប្រូនខ្ញុំផ្សារ ។

ឲ្យកូនព្រះអង្គ យកគ្នាមកបង់ ព្រួតបាប់ខ្ញុំណា
បើមិនស្រឡាញ់ បណ្ដេញទៅក៏ ម្ដេចឲ្យខ្ញុំផ្សា
រកស្រូវបង់គេ៍ ។

អ្នកផងផ្អើលនោ- ឡោតមករក៍ ដោររោមមើលមីរ
ឯព្រះនរបតី ចេញពីមន្ទីរ យល់បុត្រទាំងពីរ
ប្រហាប់ទឹងនាង ។

ស្ដេចខ្ញាល់មហិមា ទ្រង់ព្រះក្រោធា ទះក្តៅប៉ផាង
បន្ទូលក្រទ្ធ គន្ធឧបំភ្លាង មិនអើយនេះម្រាង
ទឹងរស់ឥឡូវ ៗ

វត្តប៉ុណ្ណោះ ម្ដេចកល់វាចេះ ហិនក្បត់អញក្បូ
ថើធំហើយណា សមជាសត្រូវ ទឹងអញឥឡូវ
មិនលែងឡើយណា ៗ

ស្ដេចក្រេវក្រោធខ្លាំង ខ្ញាល់ក្រៃក្រពាំង ពន្ទឹកមហិមា
មិនគិតគកបុត្រ បរិសុទ្ធវោហារ ពុំពិចារណា
ផល់តិចឡើយហោង ៗ

បន្ទូលត្រាស់ស្រេច ថាវិនអស់ពេជ្រ. ឃាតអ្នកផង
ដោះឡើងម្នា នាំគ្នាតាប់ចង ទាំងពីរជាមួង
នាំចេញទៅក្រៅ ៗ

យកគ្នាប្រគ្គកាប់ សម្លាប់ឲ្យឆាប់ កប់ក្នុងរណ្ដៅ
ក្យណានោះអ្នកផង ត្រសង់រត់ទៅ ចូលរោមតាប់ទៅ
ទាំងពីរអង្គា ៗ

កាសូរបុត្រថ្លៃ　ពុំដឹងទុក្ខភ័យ　ដូចដល់អាត្មា
ហេតុតៀវអ្នកឯង　ពីព្រេងហោងណា　និងនាងមន្ទា
ទេពីនោះហោង　ៗ

ស្រែកយំកេក្តាយ　ទុក្ខមេកាយ　កាសូរយើងផង
យើងក្មេងសេចក្តី　ឥតបីធ្នាំធ្ងន់　អ្នកជួយរងហោង
សូមព្រះបិតា　ៗ

យើងឥតទោសឡើយ　ឈោមយើងមកហើយ　គៀបខ្ទាប់ហើយថា
ថាយើងមានទោស　កាក្រោសឃោសនា　ឲ្យព្រះបិតា
ក្រោធក្រៃកន្ទង　ៗ

កាលនោះពេជ្ឈឃាដ　ពុំហ៊ានប្រមាថ　បុត្រក្សត្រឥតហ្មង
លើកដៃបង្គំ　ប្រណម្យយំផង　អាជ្ញាប្រើហោង
និងលែងពុំបាន　ៗ

ទើបនាំព្រះអង្គ　ទាំងពីរគេចត្រង់　ព្រះព្រៃសមសាន្ត
ឯនាងវង្សធ្យា-　ជាយាកល្យាណ　នាងឮពតិមាន
ពីព្រះរាជបុត្រ　ៗ

នាងគិតសន្ទប់　ដាលដល់ចំប្រប់　ហឫទ័យរន្ធត់
នាងភ្ញាក់ស្មារតី　ម្នីម្នារួតរត់　តាមព្រះរាជបុត្រ
ដល់ព្រៃសមសាន្ត　ៗ

តាមទាន់ហើយនៃ ក្សត្រីគន់ថ្លៃ នរគក់ប្រះប្រាណ
ទ្រង់ព្រះកន្ទ្រៃង ថ្លែងថ្លឹងពុំបាន ដួលដេកនាហាន
ដីជិតអង្គា ។

## បទព្រហ្មគីតិ

ក្សិណានោះនាងទុបគង់ បុត្រពីរពង្សទៀងទូញថា
ទុក្ខនគន់ពុំផា ពៀររវេកស្ងួនឥតគូ ។
ម្តាយថ្នមស្ងួនពន្លក ពីកើតមកដល់ឥឡូវ
ពុំដែលដើរឲ្យត្រូវ ថ្ងៃក្តៅក្រូវម្តាយប្រណី ។
ដេកយប់ម្តាយទុបអ្នក ពុំដែលអាក់មួយរាត្រី
បារម្ភខ្លាចអ្វី ៗ មួយភារលើស្ងួនពុំផា ។
ឥឡូវដល់ពិបាក ដល់គោកយ៉ាកដូច្នេះណា
គេនាំមាសស្ងួនក្លា ដល់ព្រឹក្សាព្រៃសមសាន្ត ។
គេទីងសម្លាប់បង់ តាំងពីរអង្គកប់នាហាន
ម្តាយឮគេព្រមាន ម្តាយមកប្តានបានយល់មុខ ។
មាសអើយទ្រូងម្តាយផ្សា បានយល់បារែងជាទុក្ខ
ទ្រូងម្តាយដូចគេគក់ ដូចគេបុកអស់អង្គា ។
ថាបើគេសម្លាប់ សមម្តាយស្លាប់ផងឯងណា
រស់នៅថ្វីកំព្រា កូនពុំផាប្រាសដំណើរ ។

| | | |
|---|---|---|
| ឱមាស ៗ បណ្តូល | ម្តាយកាសូរបាទាំងពីរ | |
| ផ្កាបលេងលើមន្ទីរ | នៅស្និទ្ធស្នេហ៍ទឹងម្តាយណា | ៗ |
| ផ្កាប់ដេក ៗ សុំសល់ | លើខ្នើយខ្នល់មាសមាលា | |
| ក៏លៀងតែងក្បា | បន្ទន់ជាប្រក្រតី | ៗ |
| ម្តេចស្លាប់ ៗ ឥសារ | នៅកណ្តាលប្រថពី | |
| មាសអើយម្តាយប្រណី | កាសូរជីវិតបាក្រៃ | ៗ |
| ឱស្លាប់ ៗ អភ័ព្វ | ឥតគេកប់កំណើតខៃ | |
| កើតជាមហាក្សត្រថ្លៃ(១) | ហៅប្រពៃឥតស្មើឡើយ | ៗ |
| ឱស្លាប់ ៗ វិស័យ | កាលក្នុងផ្ទៃនោះឲ្យហើយ | |
| ម្តេចស្លាប់ ៗ ឥតត្រើយ | ទឹងសហ័សដូច្នេះណា | ៗ |
| ខាងសោក ៗ រាជបុត្រ | ញ័ររន្ធត់អស់អង្គា | |
| ព្រះនេត្រដោរជលជា | ជលធារាដួចដល់ដី | ៗ |
| គក់ទ្រូងជាលដួចមរ | ស្ងួនទាំងករបាត់ស៊ុរេល | |
| សន្លប់បាត់ស្មារតី | ពុំរលឹកអង្គអាត្មា | ៗ |
| អង្គឯព្រះរាជបុត្រ- | ពីរបរិសុទ្ធសឹងសោកា | |
| ហៅសូរវង្វេងញញា | ព្រះមេណាឥសារសល់ | ៗ |

---

១- ចាប់តាំងពីឃ្លាថា «ឱមាស ៗ បណ្តូល» រហូតដល់ «ហៅប្រពៃឥតស្មើឡើយ» ក្នុងសៀវភៅ Mission Pavie រលុងបាត់ ។

ស្រឡាញ់យើងសល់ខ្នាត អ្នកសង្ក្រាតមុះមកដល់
ខំមកឲ្យបានយល់ ម្តេចឡើយមកក្បែយជន្មា ៗ
យើងឥតគួរសងគុណ ព្រះមេធ្ងន់ក្រាស់ក្រៃ
យើងស្លាប់ឥឡូវណា គុណព្រះមេឥតសារហោង ៗ
ឱប្អូនមាសព្រលឹង មកយើងនឹងប្រតិស្ឋផ្សង
អង្វរទេព្តាផង ក្រែងព្រះមេយើងបានរស់ ៗ
បពិត្រអស់ទេព្តា ស្ថិតនៅនាតាំងទិសទស
រួចកល់តាល់សោឡស ព្រហ្មខ្ពង់ខ្ពស់ឆ្ងាយក្រាស់ក្រៃ ៗ
យើងតាំងពីរនេះណា ស្ងួនមាតាបិតាក្រៃ
គេជះបារមីថ្លៃ ជួយចម្រើនព្រះមាតា ៗ
ឲ្យអ្នកមានព្រះជន្ម ដូចពីមុនទោះឯងណា
គេជះយើងសច្ចា សូមទេព្តាជួយផ្តិតផ្តល់ ៗ
ឯចៅវរវង្ស ប្អូនពុំអាខ្លួញសោកសល់
ព្រះហស្តថ្វីមង្គល ថ្នមឱបអង្គព្រះមាតា ៗ
អ្នកទ្រង់ព្រះកន្សែង ខ្សួញខ្សួលថ្លែងឥតគណនា
ព្រះឧស្សថ្លែងខ្សួញថា ឱព្រះមេស្លាប់អសារ ៗ
ហេតុអ្នកអាល័យបុត្រ ដើររួតរត់ឥតស្រយាល
ព្រះកក្តិទុំរន្ទាល ដួចដល់ផាលដូចលោហិត ៗ

ព្រះមេអាល័យខ្លាំង ឈឺត្រឡាំងពិតពុំគិត
សោកហើយនឹកនាំគិត ជាលដល់ក្ស័យព្រះជន្មា ៗ
ឯគុណព្រះមាតាថ្លៃ ក្រាស់ក្រៃក្រៃឥតគណនា
សមុទ្រគម្ភីរ សុមេរុមហាប្រថពី ៗ
យកមកផ្ទឹមពុំស្មើ គុណលើសលើថ្លៃឥតបី
ផ្ទឹមនឹងព្រះគម្ពីរ អភិធម្មនៃស្មើបាន ៗ
ឥឡូវយើងក្ស័យសូន្យ នាព្រះព្រៃព្រឹក្សាសាន្ត
មកយើងនូវប្រតិស្ឋាន អង្វរករទេវតាផង ៗ
បពិត្រអស់ទេវតា ស្ថិតនៅនាជ្រោះជ្រលង
សឹងសព្វបពិតផង ប្រថពីភូមិកពព្រៃ ៗ
ទេពតាំងទសទិសា សោឡសមហាសួគ៌ាល័យ
ព្រហ្មព្រឹទ្ធខ្ពង់ខ្ពស់ក្រៃ សូមអ្នកស្តាប់យើងខ្ញុំផ្សង ៗ
រីយើងតាំងពីរណា ស្ងួនមាតាឥតឯហ្នង
គេជះបារមីផង ជួយបម្រើនព្រះមាតា ៗ
ឲ្យអ្នកមានព្រះជន្ម ដូចពីមុននោះឯងណា
សូមកុតបំហុតប្រា- កជកបកាលឥឡូវម្តង ៗ
គេជះបារមីថ្លៃ មាតាក្ស័យរស់វិញហោង
ក្លាក់ះឡើងដូចបំណង ប្រាថ្នាផ្សងពុំឃ្លាតឡើយ ៗ

ទើបនាងទូលប្រាប់ បុត្រពុំងាកាំងពារហើយ
ថាអម្ចាស់ម្ដាយហើយ ម្ដាយដេកលក់ឈឺជ្រងំ ។
កុមារកាំងពារថា ឱមាតាអម្ចាស់ខ្ញុំ
មិនដូចព្រះអង្គផ្ទុំ ព្រះអង្គក្ស័យជីវិតប្រាណ
យើងផ្សងបារមីតា ទើបមាតាព្រះអង្គមាន
ជីវិតរស់ឡើងបាន ឱបអង្គយើងកាំងពារណា ។
នាងស្ដាប់កូនប្រាប់ហើយ ទើបនាងឆ្លើយហៃសួនក្ងា
ម្ដាយស្លាប់ ៗ ទៅជា ទឹងរស់ថ្វីប្រាសកូនហើយ ។
បើបាមានបារមី រស់ជីវីបានទៅឡើយ
នោះនៃទើបម្ដាយស្បើយ ម្ដាយរស់នៅទន្ទឹងបា ។

## បទកាកគតិ

ពេជ្ឈឃាតនោះនៃ មើលយល់នាងក្ស័យ ជីវិតមរណា
យល់ព្រះរាជបុត្រ ប្រាកដសព្វា ផ្សងអស់ទេព្ដា
នាងយល់វិញហោង ។

អង្គរងសិរសី គោតព្រះបារមី ក្សត្រក្សាន្តកន្លង
ពុំហ៊ានប្រមាថ ពិឃាតឡើយហោង បង្គំទូលស្នង
សរសើរសម្ភារ ។

បពិត្រក្សត្រថ្ងៃ យើងយល់បារមី រតន៍រាជកុមារ
ពិសេសប្រពៃ ច្រើនក្រៃពិស្ដារ ប្រាកដនាកាល
នេះឯងហោងណា ។

ដោយព្រះសណ្ដាប់ ប្រើយើងសម្លាប់ បំបាត់ជន្មា
យើងពុំប្រមាថ ពិឃាតបុត្រា សូមរាជជាយា
បណ្ដោះឲ្យរត់ ។

សឹមយើងទូលប្រាប់ ថាបានសម្លាប់ ពីរព្រះរាជបុត្រ
ដល់ក្រៅសីមា យកគ្នាធ្វើគត ខ្លាចនោះយើងផុត
បង់សៀតហើយហោង ។

កុំម្ចាស់គិតក្រែង ចាំយើងខ្ញុំឯង លាក់ពុំឲ្យហ្មង
ម្ចាស់ឲ្យដំណើរ ឆាប់ ៗ ដូចផ្គង ដោះចេញជាម្ដង
ទៅស្រុកនានា ។

នាងមាថទេវី បានឮសម្ដី ពេជ្ឈឃាដរាជា
ហឫទ័យសាទរ អរគេតឯងថា ស្រាកស្រាន្ដទុក
ទុក្ខនាងបានស្បើយ ។

ទើបនាងថាផង ហៃពេជ្ឈឃាដបង . គួរអញរស់ហើយ
គុណបងមហាថ្លៃ ក្រៃគតផ្ទឹមឡើយ បងឯង ស្មើ ត្រើយ
សមុទ្រជលសា ។

ពោះសត្វនិករ ត្រាច់ត្រង់ចេរចរ ដើរដោយគេត្រា
បេរិបាកព្រេង វេទ្ធនមាតា លិចលង់អាត្មា
ហែលហាត់លិកលាន ។

គាប់ឃើញត្រើយគោះ សង្ឃាតហែលផ្ទោះ ឥតឯប្រមាណ
បាទពឹងពំនាក់ សំណាក់អង្គប្រាណ រស់រួចឡើងបាន
ដល់ដូចបំណង ។

ពុំនោះសោតណា ដូចអង្គតថា- គតគាប់ឯងហោង
ជានាប្រោសប្រស់ សត្វត្រៀបផង នានាំសត្វធ្ង
ដាក់ដល់និព្វាន ។

គេស្ងាប់នោះហោង ដោយសារគុណបង ប៉ះបាតវិញ្ញាណ
ថាបើអញរស់ របស់អញមាន អញឲ្យបងបាន
ពេញបរិបូណ៌ក្រៃ ។

បងឯងសោតទឹង ពិតពុំកំជឹង ត្រង់ក្តិតភ័យ
ចតុរាបាយ នរកនោះនៃ ចៀសចាកឆ្ងាយក្រៃ
ដូចក្តីប្រាថ្នា ។

ទឹងបានសម្បត្តិ ក្រៃត្រឹងស្ងួតថាត់ តុសិតសួគ៌ា
រៀនរួចលុះបាន និព្វានថ្ងៃថា កម្រមកក្រ នូវសុខស-
ប្បាយបរិបូណ៌ក្រៃ ។

នាងនាថវង្សា ទេវីសោកា អតេតសង្ស័យ
ម្ចាដើរដល់ មណ្ឌលហើយខែ នាងតែទាខែ
អង្គប្រេកស្រេច ៗ
ហើយទើបនាងយក បិញ្ចៀនពីរមក ត្បូងស្បូវកាន្តពេជ្រ
ជាងដៅជា ៗ រចនាស្រស់ស្រេច ឆ្លាក់ផ្ទៅក្បូរក្បាច់
ល្អឥតផ្ទឹមឡើយ ៗ
ទើបនាងលីលា យាងយាសយាត្រា ដើរដល់កូនហើយ
នាងឲ្យដំណឹង ឥតឯខ្វះឡើយ ផ្តាំថាកូនអើយ
បិញ្ចៀននេះណា ៗ
ម្តាយឥតទ្រព្យអ្វី គ្រកាលអស់ក្តី ម្តាយទឹងឲ្យប៉ា
មានតែបិញ្ចៀន ត្បូងស្បូវកាន្តជា លោកកាត់ថ្លៃថា
នគរមួយខែ ៗ
បើប៉ាឥតភ្លើង ប៉ាលើកដុះឡើង មានស្មើថ្លៃ
ហើយយកសម្រាម ស៊ីកឈើស្ងួតព្រៃ ឈើទឹងបាតដៃ
ត្រងវេងពីក្រោម ៗ
បើភ្លើងដូច្នេះ ភ្លើងស្រកចុះឆេះ ឆេះឡើងទ្រលោម
ហើយយកកំណាត់ ឈើពុកមកជ្រោម បង្កាត់ដាក់ក្រោម
ចំអិនធាប់ក្រៃ ៗ

បើយប់សោកណា ឥតក្វើនបូរបា យកពាក់នៅដៃ
វាមានពន្លឺ យល់ភ្លឺប្រពៃ ដូចក្វើនវិស័យ
ពិត ៗ ក្តាត់ហោង ៗ

ហៃកូនពិសេស កុំបាប្រហែស ដើរដោយប្រុលង
ជនព្រៃស្រងាត់ ក្រែងសត្វយង់ឃ្នង ហឹង្សាបាហោង
កុំបាប្រហែស ៗ

ហៃកូនពុំងា ម្ដាយមត់ទឹងបា បើបាដើរទេស
ក្រែងបុណ្យបាមាន បុកណពិសេស កុំបាក្រអៃះ
បាត់បង់លង់ឡើយ ៗ

ម្ដាយមត់តែជប់ ឆ្នាំផគំរប់ ពីរឆ្នាំនេះហើយ
រលង់ពីនោះ ទុក្ខម្ដាយឥតស្បើយ សមស្លាប់កូនអើយ
មិនលែងឡើយណា ៗ

ក្បៀណនោះក្សត្រី រួមរ័កបេតី ផ្ដាំកូនពុំងា
នាងថ្មមខុបអង្គ ប្រតិយង់អង្គា កូនសោកក្រាបលា
ចាកចេញទៅហោង ៗ

នាងស្រែកផ្ដាំសព្វ ទេព្ដាផងគ្រប់ ដោយជ្រោះជ្រលង
បពិតបព្វតា ព្រៃព្រឹក្សាផង ឲ្យរក្សាគ្រង
មើលកូនពុំងា ៗ

| | | |
|---|---|---|
| ទើបនាងក្រឡាប់ | វិលវិញមកឆាប់ | ដល់ផ្ទះហើយណា |
| នាងសោកសញ្ជប់ | ស្ងួតស្ងប់ក្រោ | តានតឹងនឹក |
| | ទ្រង់ព្រះកន្សែង | ៗ |
| ឯពេជ្យឃាត | ក្រាបទូលព្រះបាទ | ក្សត្រក្សាន្តថ្លែង |
| បពិត្រខ្ញុំកាប់ | សម្លាប់ពុំលែង | ខ្មោចនោះខ្ញុំតែង |
| | ដុតបាត់បង់ហើយ | ៗ |
| ស្ដេចស្ដាប់ថាអើ | បើដោយអំពើ | ដុតវាចុះឡើយ |
| គួរគួរនៅចុះ | សូមស្រោះឥតត្រើយ | ពុតពាលហើយ |
| | បន្ទោសទៅណា | ៗ |
| ស្ដេចឮនាងយំ | សង្រេងទូរគមន៍ | ទៀនទួញបុត្រា |
| ស្ដេចទ្រង់ព្រះក្រោធ | សន្ធឹកមហិមា | បន្ទូលដេរថា |
| | ពះហោរកំណាច | ៗ |
| កូនវាឥតច្បាប់ | វាយរះថាគាប់ | ពុំយល់ជាកាច |
| វាយំវាស្រែក | ចិត្តវាមិនខ្លាច | អួតអាងអំណាច |
| | បុណ្យស៊ីត្រឡាំង | ៗ |
| មិនចេញទៅក្រៅ | កុំបីមិននៅ | ក្នុងព្រះរាជវាំង |
| បើមិនមិនចេញ | អញឲ្យកើតខ្លាំង | ក្អែកសស្មើតស្វាំង |
| | កញ្ញក់កញ្ញែង | ៗ |

នាងឮស្តេចខ្ញាល់ ព្រះហឫទ័យញ័រ ឥតឯថ្លឹងថ្លែង
នាងតាំងភិតភ័យ ហឫទ័យស្ញប់ស្ញែង ពុំអាចតាស់តែង
ទូលពិតឡើយណា ។
នាងចេញទៅនៅ បិតនាបាំងក្រៅ ពិតពុំនាំពារ
នាងនៅស្ងៀមឯង តាមព្រេងវេរ នាងគិតអនិច្ចា
សង្វេគអង្គប្រាណ ។
ស្តេចខ្ញាល់ហ្នឹងហើយ បង់សៀតគោះតើយ ពិតពុំកប់អាន
ពុំមានសំនួរ សាកសួរមកថ្កាន ផ្តេកនាងកល្យាណ
បង់សៀតចោះបង់ ។

## បទកុជង្គលីលា

ទីងថ្ងៃសម្តែងកាលនោះ កុមារពីរផ្ទុះ ចរចេញយាត្រា ។
ត្រមោចលទោចក្តាត់ណា ស្ងប់ស្ងួតក្រោ ដើរដោយផងព្រៃ ។
រលឹកសន្ទឹកសន្ធៃ អាឡោះអាល័យ តែព្រះមាតា ។
ពុំគិតអាណិតអាត្មា ត្រមោចកំព្រា ដល់តិចឡើយហោង ។
ដើរត្រេចលុះលេចរលង ស្រុកធំកន្ទង ដល់ស្រុកមួយណា ។
ស្រុកនោះឱ្យឈ្មោះនាមា បស្ចិមទិសា នាមនៃសន្ធត ។
ចម្ងាយផ្លូវឆ្ងាយប្រាកដ ហុកសិបយោជន៍គត់ ចម្ងាយមាគ៌ា ។

គេជះព្រះបារមីថា ថ្ងៃមួយវេលា ដើរដល់ប្រាកដ ។
មានចៅមឿងនៅកំណត់ នាមថៃសន្ធត ហៅជេតមាណព ។
មានផ្កាត្រកាលផងគ្រប់ ឈ្មួញឆ្ងាយសាយសព្វ ចុះផ្សារដោយផល់ ។
កុមារត្រកាលដើរដល់ អ្នកផ្កាផងយល់ ស្រដីផងគ្នា ។
មៀងមើលសរសើររូបា ទាំងពីរគន្ធា កើតគួរស្រឡាញ់ ។
គ្នាមើលដើរមកម៉ិញ ៗ បើគេឲ្យអញ អញយកជាកូន ។
ពីរនាក់សមបងសមប្អូន ពាក់ដូចគេសូន ល្អ ៗ ដូចគ្នា ។
ហើយគេដណ្តឹងអ្នកថា មាសមកពីណា មាសដើរតែឯង ។
មាសមករំរែកដើរលេង ឬមាសវង្វេង ទីងម្តាយជីងអើយ ។
មាសប្រាប់យើងបាប់មាសអើយ កុំមាសលាក់ឡើយ យើងចង់ដឹងក៏ ។
អ្នកស្តាប់ពុំប្រាប់ឡើយណា ពិតពុំនាំពា ធ្វើជាមិនដឹង ។
ដើរសៀមកបរៀងផ្កាធ្ងឹង អ្នកផងដណ្តឹង ពិតពុំស្រដី ។
ខ្លះឱបក្រសោបក្បាប្រិយ៍ ខ្លះហុចចំណី បង្អាន់ដោយដៃ ។
បបក់ព្រលឹងទទៃ ខ្លះដោះយកស្បៃ ទទូរឲ្យអ្នក ។
អ្នកសោកអរមោកឥតអាក់ ទឹកភ្នែកស្រក់ សស្រោកដោយផ្លូវ ។
អ្នកគិតអាណិតឯងកូវ ថាយើងឥឡូវ ពុំគិតអាត្មា ។
គិតត្រង់ឯអង្គមាតា សមសោយសោកា សរស្រេងសង្រែ ។
សមគិតអាណិតតៃ ៗ សមតែកាល័យ យើងទាំងពីរហោង ។

កាលនោះអ្នកឆ្ពោះចេញផ្គង ដើរត្រាច់រំលង ស្រុកនោះឯណា ។
ដល់ទៃព្រះព្រៃព្រឹក្សា ទូរគមអញ្ញា ស្ងប់ស្ងាត់ឈប់ឈឹង ។
មានអសូរបក្សីជ្រោះស្អឹង រាលវែងបូរបឹង ស្រះស្រង់ផលសា ។
ព្រះអង្គពីរពង្សក្សត្រា ត្រាច់ត្រង់មាគ៌ា ជិតជើងគីរី ។
មើលល្បាស់លូតលាស់ខៀវខ្ចី អម្រឹតបក្សី ដើរដោយផ្លូវភ (១) ។
ប្រើសក្រោយទន្សាយប្រមាំ ចចកស្វានស្វា រមាសរមាំង ។
គោខ្លាធំខ្សាន់ខ្ទះខ្នាំង ព្រះព្រៃខ្ទឹងខ្ទាំង ប្រឡាំងញាញង ។
ងើយងួចងួរង្អៀងង្អង ជាញផល់លេងលង វិលវៃភត់គ្នា ។
ត្រាច់ត្រង់ឯកអង្គបក្សា ភ្ញាទុងទទា ទោចទោមប្រវឹក ។
អុកអកកុកក្រកគគឹក ចចាតមាន់ទឹក មាន់ទោក្រសា ។
ទៀងទៀវក្រួចក្រៀលទទា សត្វផងច្រើនគ្រា ដោយពារទីទៃ ។
ព្រះអង្គពីរពង្សក្សត្រថ្ងៃ វង្វេងផ្លូវព្រៃ ពុំដឹងតែដើរ ។
រលឹកសន្ធឹកផ្អូកផ្អើល ក្រឡេកមៀងមើល ហាក់ដូចមាតា ។
ស្រមៃសព្វព្រៃព្រឹក្សា ទង្គឹះទុក ភានគឹងស្មើរធ្លាយ ។
នេត្រអ្នកសស្រាក់ហូរខ្លាយ ផ្អេសផ្អេកយមាយ ពុំចេញសូរសង ។
លីលាយាត្រាទៅហោង ទាំងប្អូនទាំងបង បណ្ដើរគ្នាទៅ ។

---

១- ចាប់ពីកេះទាំងល់ “ភានគឹងស្មើរធ្លាយ” សៀវភៅ Mission Pavie រំលងបាត់ ។

ដោយផ្លូវតាប់ត្រូវថ្ងៃក្តៅ សម្រាកឈប់នៅ សព្វម្លប់ព្រឹក្សា ។
អ្នកឧបត្រៃសោបកៀកគ្នា ដាក់ដេកនិទ្រា សម្រាន្តខ្លួនហោង ។

## បទកាកគតិ

វីរជកុមារ បុត្រគន្ធសង្គ្រារ ក្សត្រក្សាន្តកន្ទង
ធ្លាប់នៅស្រណុក ឥតទុក្ខឡើយហោង ពុំដែលមានហ្មង
ព្រួយព្រះហឫទ័យ ។
ហេតុពៀរអ្នកឯង អំពើពីព្រេង តាមមកទាន់នៃ
វិបាកបុកណា មែនមានវិស័យ ជួបចង់ពៀរភ័យ
ពុំមានឃ្លាតឃ្លា ។
វីកាលនោះហោង ព្រះរៀមស្នេហ៍ស្នង នូវព្រះអណុជា
ដើរត្រាំលំបាក ចេញចាកព្រឹក្សា លុះលេចអធ្វា
ដើរដល់គិរី ។
មៀងមើលយល់ភ្នំ ស្កឹមស្កៃស្កុសធំ ចំពេញអស់ក្ដី
ស្ងប់ស្ងាត់ជ្រងំ ទូរគមឥតបី ជួបបូលកត្រី
ព្រលប់សន្ធ្យា ។
ស្ដែងស្ដេចចូលបត និត្យនៅចំណត នាដើមព្រឹក្សា
និគ្រោធមួយធំ គ្រសុំសាខា ចូលបតនិទ្រា
សម្រាកខ្លួនហោង ។

អ្នកឡើងទៅផ្ទុំ លើមែកជ្រៃធំ ទាំងពីរស្នេហ៍ស្នួន
ស្ងប់ស្ងួតព្រះភក្ត្រ អួលអាក់កន្ទួង តែប្អូនទិនបន
សែនសោយសោកា ។
ផ្អកផ្អឹះសន្ទឹក រំងៃរងរលឹក ព្រះវរមាតា
ពិតពុំភ្លេចឡើយ យំហើយទួញថា យើងកំព្រា
ពេកពន់ប្រមាណ ។
ទោះគាប់ទោះខុស ទោះស្លាប់ទោះរស់ យើងមិនគិតប្រាណ
គិតតែអ្នកមេ ឥតល្ហែស្រាកស្រាន្ត ម្ដេះសមអ្នកមាន
ទុក្ខទៀនសោកា ។
កាលឲ្យដំណើរ អ្នកយំបណ្ដើរ ហើយអ្នកផ្ដាំថា
ទុកកូនកម្សត់ ម្ដាយមត់ទឹងប្ញា ដល់ឆ្នាំទៀតណា
ទល់ទុក្ខកន្ទួង ។
បើបាមិនដល់ ម្រាងម្ដាយនឹងយល់ សម្លាប់ឯងហោង
ឥឡូវនេះសូន្យ តែប្អូនទិនបន គ្រាប់សព្វជ្រលង
ដេកដោយព្រឺក្សា ។
ក្រែងតែសត្វធាតុ មុះមកប្រមាថ ហឹងព្យាពាធា
យើងស្លាប់អសារ ឥតការទេណា អាសូរមាតា
អ្នកតែងទទួង ។

ថាបើយើងរស់ យើងបានជាមនុស្ស នោះពុំទាន់ដឹង
យើងនឹងក្រឡាប់ ធាប់ៗមករឹង សមអ្នកម្ដាយនឹង
ស្រាលស្រាន្តសោក ។

លុះដល់យាមមួយ នឿយណាស់ដោយព្រួយ យាងយាសយាត្រា
ព្រះអង្គឧត្ដម ផ្ទំនៅព្រឹក្សា បងអង្គអាត្មា
នឹងមែកជ្រែខ្នាប់ ។

រីអស់សត្វផង សាហាវទ្រើសឃ្នង យង់យំពួសព្វ
កុមារទាំងពីរ ត្រអាលស្ដែងស្ដាប់ ពុំលង់លុះតាប់
អគ្រាគ្រងងណា ។

បទពំនោល

តេជៈព្រះបារមីតា ក្ដៅដល់អាសនា ព្រះឥន្ទឥសូរធិបតី ។
ហាក់ដូចអ្នកយកអគ្គី អុជពោលគំពី ក្រោមបាទប្រាសាទមណ្ឌល ។
ព្រះឥន្ទគន់គិតហើយធ្ងល់ អស់អង្គកល អស្ចារ្យកើតប្រត្យក្សមាន ។
ទៀងទេព្រះឥន្ទប្រែក្រ្ដ បរបើកទិពចក្ខុ សហស្សព្រះនេត្រាត្រេច ។
យង់យល់ពួជពង្សពេជ្ញ ល្បែងយល់សេចត្រេច ដោយនូវតំណើរឆាប់ក្រៃ ។
ព្រះឥន្ទគិតក្នុងហឫទ័យ នាំអ្នកនេះនៃ ពន្លកពន្លឺសម្ពុទ្ធ ។
បរបីរីលរឹងចំហុត ត្រាស់ត្រេចប្រាកដ នានាំអស់សត្វនិករ ។
ធ្លាស់ធ្ងន់រលងសាគរ រួបរៀងបានប- រិបូរណ៍ដល់នគរនិព្វាន ។

គួរអញបំពេញឲ្យបាន ជាស្តេចស្តែងមាន សម្បត្តិសម្បូរច្រើនក្រៃ ។
ព្រះឥន្ទ្រគិតហ្នឹងហើយនៃ បន្ទូលថាហៃ ព្រះពិស្ណុកាចូរបា ។
ហោះហួសវៀលវួសរហោស ប្រាណប្រែកាឡា បំពេញកុមារពីពង្ស ។
ឲ្យបានស្ថិតឋានមែនម- ង្គលគាប់ជ្រើសទ្រង់ សោយរាជ្យជាស្តេចស្តែងជាក់ ។
ឲ្យមានឫទ្ធិសិទ្ធិស័ក្តិ ជោគជ័យប្រត្យក្ស ចេស្តាប្រាសបរិបូណ៌បាន ។
ព្រះពិស្ណុការស្តែងស្តាប់ ព្រះឥន្ទ្រថ្លែងប្រាប់ ក៏ចូលទូលចិត្តត្រេកអរ ។
ស្រេចលុតបាទបត់កាយករ អញ្ជលីថ្វាយវរ បង្គំប្រណម្យក្រាបលា ។
ហោះឆ្ពោះចុះចាកសួគ៌ា ដល់ដើមជ្រៃណា ក៏ឃើញកុមារពីរផ្ទុំ ។
លើមែកជ្រៃជិតជើងក្ដុំ ស្ងប់ស្ងាត់ជ្រងំ ត្រមោចតែពីរនេត្រា ។
ព្រះពិស្ណុការកាឡា និម្មិតប្រែជា មាន់ពីរសម្ដែងឲ្យយល់ ។
មាន់ខ្មៅទិត្យនៅមណ្ឌល ក្រោមជ្រៃអួតផល់ រងាវបន្ទឺសូរសម ។
មាន់សហើរមកពីក្ដុំ បន្ទាបទៀបទំ នូវចុងជ្រៃលើមណ្ឌល ។
ស្រេចស្រែកសប្រែកសោភសល់ រងាវអួតផល់ សន្ធាប់នូវសព្ទឥតគុណ ។
មាន់ខ្មៅជៀលទៅមាន់ស ថាព្រះស្តែងមក ក៏មកទំនៅលើក្បាល ។
មឹងនេះលះលែងអនុពាល ដូរជាតិបណ្ដាល បង្កើតជម្លោះជាញដល់ ។
ជ្រៃនេះជាតិជាមណ្ឌល ម្ដេចមឹងបីកហល់ ក៏ហើរមកទំទៀបស្ថាន ។
យល់មឹងពន់រឹងហាវហាន មុះមកបំពាន ពុំកោតពុំក្រែងទៀតណា ។

(នៅមានត)